ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- គ្មានច្បាប់ គ្មានវិបុលភាព
- គ្រាក់ការផ្តាច់ព្រលឹង

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣១ ខែកក្កដា ឆ្នាំ២០០២


## មាតិកា


◆ សំបុត្រៈ គ្មានច្បាប់ គ្មានវិបុលភាព........................................១

### ផ្នែកឯកសារ

◆ ឈ្លេចយកចម្លើយដើម្បីតាមកម្ទេចខ្មែរយៈ..........................២

◆ ទីតាំងវាលពិឃាតខេត្តពោធិ៍សាត់........................................៤

◆ បញ្ជីឈ្មោះជនរងគ្រោះបរទេស........................................១០

◆ ឯកសាររូបថត..........................................................១២

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ........១៥

◆ ក្បួនទ័ពព្រៃខ្មែរក្រហម.........................................................១៧

◆ កត្តាដែលធ្វើឲ្យសង្គ្រាមប្រជាជនទទួលបានជ័យជម្នះ..............២១

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ ប្រជុំជីវភាព “ទិតៀន-ស៊ុយទិតៀន”..................................២២

◆ សម្លេងពីមន្ទីរស-២១ .....................................................២៥

◆ ចាប់ពីទួលដែនមកដាក់នៅមន្ទីរស-២១ .............................២៩

◆ ខ្មែរកម្ពុជាក្រោមក្នុងគំនិតខ្មែរក្រហម.................................៣២

◆ ការជួបជុំគ្នាឡើងវិញរបស់អតីតយុទ្ធជនមន្ទីរស-២១............៣៥

◆ ភ្នាក់ងារផ្កាច់ព្រលឹង........................................................៤០

### ផ្នែកច្បាប់

◆នីតិវិធីសម្រាប់ការកំណត់យកភ័ស្តុតាង ..............................៤៨

### វេទិកាពិភាក្សាសាធារណៈ

◆ គ្មានយុត្តិធម៌សម្រាប់ជនរងគ្រោះក្នុងរបបខ្មែរក្រហម.............៥១

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ អតីតយុទ្ធនារីខ្មែរក្រហមសុំទោសប្រជាជនកម្ពុជា...................៥២

◆ គ្រូទាយថា បងប្រុសខ្ញុំនៅរស់..........................................៥៣

◆ ជីវិតលោកគ្រូលៀង ក្នុងរបបខ្មែរក្រហម.............................៥៥

### សិល្បៈខ្មែរក្រហម

◆ ស្មារតីឈ្លាសវៃរបស់កុមារឃ្វាលក្របី...................................៥៩

◆ ចម្រៀងៈ អត្តភាពបដិវត្តកម្ពុជា.................................គ្របក្រោយ






# រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩
(រូបថតគ្របមុខផ្តល់ដោយៈ ចូសេហ្វ កុហ្វម៉ាន់)
រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**វាគ្មិនលេខនេះៈ** ដេវ ពន្សូវ៉ាស៊ី, យិន នាន, លីម គី, ហ៊ុយ វណ្ណៈ, ឡុង ដានី, អែម សុខឃីម, គីម កែវកន្និដ្ឋា, អៀ ម៉េងទ្រី, ដេវីដ ឆេនដល័រ, អាឡិច ហ៊ីនតុន, ហេន កូវែល, អេលីហ្សាប៊ែត វ៉ាន់ស្កាក់ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងទី១ៈ** សួ ប៊ុនស៊ូ **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** សុខ វណ្ណៈ

*សំបុត្រ៖*

# គ្មានច្បាប់ គ្មានវិបុលភាព

*បញ្ហានៃការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ត្រូវបានលើកឡើងជាច្រើនឆ្នាំមកហើយ ដោយក្រុមអ្នកផ្តល់ជំនួយអន្តរជាតិ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាផ្តល់យោបល់ ប៉ុន្តែស្ថិតនៅក្នុងកម្រិតមួយដ៏តិចតួចប៉ុណ្ណោះ ។ បណ្តាប្រទេសអ្នកផ្តល់ជំនួយដល់កម្ពុជាគួរតែយកចិត្តទុកដាក់ទៅលើបញ្ហានេះឲ្យបានខ្ពស់ ជាពិសេសក្នុងខណៈដែលមានការបដិសេធរបស់អង្គការសហប្រជាជាតិ មិនបន្តការចរចាជាមួយនឹងរដ្ឋាភិបាលក្នុងការបង្កើតតុលាការចម្រុះមួយដើម្បីវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមទាំងឡាយ ។*

*តាមទ្រឹស្តី ធនាគារពិភពលោកមិនលូកដៃចូលក្នុងកិច្ចការនយោបាយទេ ។ ប៉ុន្តែពុំមានន័យថាធនាគារពិភពលោកមិនអាចយល់បានថា បញ្ហានយោបាយមួយចំនួនបានជះឥទ្ធិពលអវិជ្ជមានទៅលើការអភិវឌ្ឍរបស់ប្រទេសមួយនោះឡើយ ។ នៅប្រទេសកម្ពុជា ការបាត់បង់ច្បាប់ទម្លាប់យ៉ាងសន្ធឹកសន្ធាប់ និងភាពលម្អៀងនៃប្រព័ន្ធតុលាការ គឺជាឧបសគ្គដ៏ធ្ងន់ធ្ងរដល់វឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គម ។ ប្រទេសអ្នកផ្តល់ជំនួយខ្លះបានបញ្ជាក់អំពីចំណុចនេះជាច្រើនលើកច្រើនសាមកហើយដែរ ។*

*វប្បធម៌នៃការរួចទោសនៅប្រទេសកម្ពុជា មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងការមិនបានកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប្រជាជនខ្មែរពិបាកនឹងជឿទុកចិត្តទៅលើតុលាការដែលដាក់ទោសឧក្រិដ្ឋជនតូចតាច ប៉ុន្តែបែរជាទុកឲ្យអ្នកដែលទទួលខុសត្រូវចំពោះការស្លាប់បង់ជីវិតមនុស្សរាប់លាននាក់នៅក្រៅច្បាប់ទៅវិញ ។*

*ប្រជាជនខ្មែរមួយចំនួនពេញចិត្តនឹងអនុវត្តច្បាប់ដោយផ្ទាល់ដៃ ដូចជាករណីសម្លាប់ឧក្រិដ្ឋជននៅតាមចិញ្ចើមថ្នល់ជាដើម ។ បញ្ហានេះក៏បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សីលធម៌សង្គមជាតិទាំងមូល ។*

*ឥទ្ធិពលអាក្រក់ទៅលើសេដ្ឋកិច្ចដែលបណ្តាលមកពីអវត្តមាននៃតុលាការមួយដែលគួរឲ្យទុកចិត្តបានគឺជាក់ស្តែងណាស់ ហើយដែលអាចកត់សម្គាល់បានរួមមានជាឧទាហរណ៍ ដូចជាកំណើនសេដ្ឋកិច្ចដ៏ស្លួចស្លេង ភាពពុករលួយនៅស្ទើរគ្រប់ជាន់ថ្នាក់ ការវិនិយោគដ៏តិចតួចពីបរទេស និងភាពឥតការងារធ្វើជាដើម ។*

*នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០២ ក្នុងឱកាសរំឭកខួបអនុស្សាវរីយ៍លើទី៥១ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា សម្តេច ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជាបានថ្លែងថា៖ «ចំពោះការអនុវត្តច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនោះ គណបក្សប្រជាជនសំណូមពរដល់រាជរដ្ឋាភិបាលបន្តជំរុញអនុវត្តឲ្យបានសម្រេចនូវការអនុវត្តច្បាប់នេះ ដើម្បីផ្តល់យុត្តិធម៌ជូនប្រជាជនកម្ពុជា ជនរងគ្រោះរាប់លាននាក់ លើមូលដ្ឋានធានាបាននូវសន្តិភាព ការបង្រួបបង្រួមជាតិនិងអធិបតេយ្យជាតិ ។ ជាមួយគ្នានេះ សូមអំពាវនាវដល់អង្គការសហប្រជាជាតិបន្តនូវកិច្ចសហការដ៏ល្អជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញឲ្យដំណើរការកាត់ទោសនេះបានសម្រេចយ៉ាងឆាប់រហ័ស» ។*

*នៅថ្ងៃទី២ ខែកក្កដា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា «អ្វីដែលយើងចង់បានគឺការស្រុះស្រួលគ្នាមួយ ជាមួយនឹងអង្គការសហប្រជាជាតិ ដើម្បីឲ្យដំណើរការតុលាការអាចប្រព្រឹត្តទៅមុខបាន ។ ដូចនេះទោះបីត្រូវធ្វើវិសោធនកម្មច្បាប់ក៏យើងអាចធ្វើបានដែរ» ។*

**ឆាំង យុ**

*(សូមអានទំព័រទី៥១ស្តីអំពីជំហររបស់អង្គការសហប្រជាជាតិ)*

# ឈ្លបយកចម្លើយដើម្បីតាមកម្ទេចខ្មាំងរយ:


ណុប នួន

ណុបនួន ហៅ នួន បានស្ម័គ្រចិត្តចូលធ្វើជាកងទ័ពបដិវត្តខ្មែរក្រហមយ៉ាងស្មោះស្ម័គ្រនៅឆ្នាំ១៩៧៣ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ត្រូវអង្គការជ្រើសឲ្យចូលទៅក្នុងក្រុមយុទ្ធជនសួរចម្លើយនៅមន្ទីរស-២១ ឬ គុកទួលស្លែង ។ ក្រោយមក នួន ត្រូវបានអង្គការចាប់ខ្លួនមកសួរចម្លើយ និងមិត្តរួមការងារជាច្រើននាក់ទៀត ។ ណុប នួន ត្រូវបានកម្ទេច នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៧ ។

ណុប នួន បានបន្សល់ទុកនូវចម្លើយសារភាពមួយច្បាប់ដែលមានខ្លឹមសារដូចតទៅ÷

*តើមូលហេតុអ្វីបានជា ណុប នួន ត្រូវអង្គការកម្ទេច?*

ណុប នួន មានអាយុ២១ឆ្នាំ ស្រុកកំណើតនៅភូមិស្រីជ័យ ឃុំបឹងត្រាញ់ ស្រុក៥៤ តំបន់៣៣ ខេត្តតាកែវ ។ ណុប នួន មានបងប្អូន៤នាក់ (ប្រុសពីរនាក់និងស្រីពីរនាក់) ឪពុកឈ្មោះ ទិត្យ ណុប ម្តាយឈ្មោះ ឌី តែម (ស្លាប់) ។

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៣ ណុប នួន បានចូលធ្វើឈ្លបនៅឃុំបឹងត្រាញ់ ក្នុងខេត្តតាកែវ អស់រយៈពេល៨ខែ ក្រោមការដឹកនាំរបស់ សារិន ហៅ កុយ ប្រធានឈ្លបឃុំបឹងត្រាញ់ ។ បន្ទាប់ពីនោះមក នួន បានផ្លាស់មកនៅក្នុងវរសេនាតូច ១១៦រហូតដល់ថ្ងៃរំដោះក្រុងភ្នំពេញឆ្នាំ១៩៧៥ ។ ខែឧសភា ឆ្នាំ១៩៧៥ នួន បានទាក់ទងជាមួយនឹងអតីតទាហាន លន់ ណុល ម្នាក់ឈ្មោះ ឈិន ។ ក្រោយពីស្គាល់ចិត្តថ្លើមគ្នាហើយ អ្នកទាំងពីរតែងតែទៅណាមកណាជាមួយគ្នារហូត ។ នួន ក៏បានទទួលការណែនាំយ៉ាងច្រើនពីឈ្មោះ ឈិន អំពីការលំបាករស់នៅក្នុងសង្គមបដិវត្តន៍ ដោយប្រៀបធៀបរបបបដិវត្តន៍ទៅនឹងរបបសង្គមចាស់ អំពីរបៀបរបបរស់នៅ ការស្លៀកពាក់ អាហារហូបចុក និងសេរីភាពក្នុងការដើរហើរ ។ ណុប នួន គិតថា ខ្លួនមិនដែលរស់នៅពិបាកដូចសង្គមបដិវត្តន៍ទេ ហេតុនេះត្រូវតែសម្រេចចិត្តទៅតាម ឈិន ។ ណុប នួន ទទួលភារកិច្ចពី ឈិន នូវផែនការបំផ្លាញសម្ភាររបស់បដិវត្តន៍និងខ្ទេចខ្ទីកម្លាំងនៅក្នុងអង្គភាព ១១៦របស់ ឈិន ។

នួន និង ឈិន បានបន្តផែនការបំផ្លិចបំផ្លាញនេះ នៅ "បន្ទាយដាបឈូន" ទៀត ដោយយកអាវុធមួយចំនួនរបស់អង្គការទៅទម្លាក់ចូលទៅក្នុងទឹកខាងលិចបឹងត្របែក ។ ថ្ងៃទី១៥ ខែឧសភា ១៩៧៥ អង្គការបានដក នួន ចេញពីនីរសា បញ្ជូនឲ្យទៅរៀននៅសាលាបច្ចេកទេសកងពល៧០៣វិញ ។ នួន មិនបានលះបង់ការធ្វើសកម្មភាពជាមួយឈ្មោះ ឈិន ទេ ទោះបីជាត្រូវអង្គការដកទៅទីណាក៏ដោយ ។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៧៥ នួន បានទទួលការចាត់តាំងធ្វើជាអ្នកសួរចម្លើយនៅស-២១ ជាមួយ ហ៊ី និង នឿន (យុទ្ធជនសួរចម្លើយ) ។ ពីដំបូង នួន និង នឿន គ្រាន់តែជាមិត្តរួមការងារប៉ុណ្ណោះ ។ ក្រោយពីស្ទាបស្ទង់ទឹកចិត្តគ្នាហើយ នួន ដឹងថា នឿន ក៏មានផែនការប្រឆាំងនឹងបដិវត្តន៍ដូចគ្នាដែរ ។

ក្នុងគោលបំណងនិងទិសដៅតែមួយ នួន និង នឿន បានស្រុះស្រួលបង្កសកម្មភាពនៅក្នុងមន្ទីរស-២១ជាមួយគ្នា ដោយមិនស្តាប់តាមបញ្ជាអង្គការ មិនស្តាប់ការណែនាំរបស់អ្នកទទួលខុសត្រូវ និងដេកក្នុងពេលសួរចម្លើយអ្នកទោស ។ ការសួរចម្លើយម្តងៗត្រូវចំណាយពេលយូរ តែលទ្ធផលសរុបមិនអាចយកជាការបាន ។ ក្រៅពីនេះ នួន អប់រំនិងអូសទាញបានមនុស្សពីរនាក់ឈ្មោះ នី និង បាន (អង្គការចាប់) ចូលជាកម្លាំងរបស់ខ្លួនថែមទៀត ។ នួន បានទាក់ទងឈ្មោះ ទុយ, លិញ, គង់ និង កុយ

(ឈ្មោះទាំង៤នាក់នេះអង្គការចាប់ហើយ) ។ ការងារបន្តមកទៀត នួន, បាន, គង់ និង នី បានធ្វើឲ្យបែកការណ៍សម្ងាត់របស់អង្គការ លួចប្តូរនាឡិការបស់អង្គការដោយគ្មានការចាត់តាំង ។ ចំណែក គង់ និង បាន ដើរនិយាយបរិហារកេរ្តិ៍ពីកម្មាភិបាលទំនាស់គ្នា ។ នឿន បានប្រាប់ពីកម្លាំងរបស់ខ្លួនដែលបានប្រមូលមានឈ្មោះ សាយ, សុខ, ញ៉ាញ, រត, កន, ជា និង នឿន ឲ្យបង្កសកម្មភាពការងារជាមួយគ្នា ។

នៅខែធ្នូ ឆ្នាំ១៩៧៦ នួន ត្រូវបាន នឿន ចាត់តាំងឲ្យបំពេញភារកិច្ចបួនៈ ១) សម្លាប់ពួកសួរចម្លើយ ដើម្បីរាំងស្ទះការងារសួរចម្លើយ ២) សម្លាប់ ឌុច និង ហ៊ី ដោយសម្ងាត់ ៣) អ្នកសួរត្រូវវាយខ្មាំងឲ្យស្លាប់ជាបន្តបន្ទាប់ និង ទី៤) ដាក់ដែកគោល លួស ដីខ្សាច់ ក្នុងបាយសម្ល ។

នៅចុងខែមេសា និងដើមខែឧសភា ឆ្នាំ១៩៧៦ នួន មកធ្វើសកម្មភាពនៅសាលាទួលស្វាយព្រៃ ។ សកម្មភាពនៅកន្លែងនោះពុំទាន់មានជាដុំកំភួននៅឡើយទេ ។ មិនដល់មួយខែផង នីរសាទាំងអស់ត្រូវអង្គការបញ្ជូនទៅធ្វើស្រែ ។ នួន និង ទុយ ចាប់ផ្តើមប្រជុំលើកផែនការសម្ងាត់ក្នុងពេលកំពុងធ្វើស្រែនៅឯព្រៃស ដែលចូលរួមដោយឈ្មោះ នី, បាន, ទុយ, លិញ, គង់ និង កុយ ។ ផែនការនោះគឺ ១) ធ្វើឲ្យបែកការណ៍សម្ងាត់របស់អង្គការក្នុងពេលធ្វើស្រែ ២) សម្លាប់ ហ៊ី និង ហ៊ុយ និង ៣) អូសបន្លាយពេលវេលាធ្វើស្រែ ។ ចាប់តាំងពីពេលនោះមក នួន តែងតែទាក់ទងជាមួយបក្សពួក ដើរឆ្វេចឆ្វាចរហូតដល់បែកការណ៍សម្ងាត់ ។ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៦ អង្គការបានដក នួន មកយាមអ្នកទោសឈ្មោះ ចក្រី មេបញ្ជាការកងពលលេខ១៧០ នៅភូមិភាគបូព៌ា អស់រយៈពេល៦ថ្ងៃ ទើបបញ្ជូនមកឲ្យសួរចម្លើយអ្នកទោសវិញ ។ មកដល់ខែតុលា និង ខែវិច្ឆិកា ឆ្នាំ១៩៧៦ បក្សពួកទាំងអស់របស់ នួន បានត្រូវអង្គការដកចេញពីអង្គភាពធ្វើស្រែ ។ ពេលនោះ នួន និងបក្សពួកមានឱកាសទាក់ទងគ្នាបន្ត និងធ្វើសកម្មភាពលួចដូរសម្ភារល្អៗ ដូចជានាឡិកាដៃរបស់អង្គការជាដើម ។

ខែមករា ឆ្នាំ១៩៧៧ នួន បានអប់រំឈ្មោះ គង់, ខុម, ផនលី និង អ៊ិន ដែលជាយុទ្ធជនសួរចម្លើយ ឲ្យធ្វើសកម្មភាពជាមួយខ្លួន ដោយណែនាំថា ចំពោះការសួរចម្លើយ ប្រសិនបើពិបាកពេកវៃឲ្យងាប់ខ្លះទៅ ហើយបើអប់រំអ្នកណាបានគឺអប់រំអ្នកនោះឲ្យធ្វើជាកម្លាំងរបស់យើងនិងធ្វើឲ្យស្ទះចលនាបដិវត្តន៍ជាបន្តបន្ទាប់ ។

ក្នុងអំឡុងខែកុម្ភៈនិងខែមីនា ឆ្នាំ១៩៧៧ ក្រោយពីព្រឹត្តិការណ៍ភ្លើងឆេះផ្ទះមួយបានកើតឡើង នឿន, ញ៉ាញ, រត, សុខ, សាយ, កន, ជា និង នឿន (សេដ្ឋកិច្ច) ត្រូវអង្គការចាប់ទាំងអស់ ធ្វើឲ្យខ្សែទាក់ទងមួយចំនួនត្រូវដាច់ នៅសល់តែ បាន, គង់, អ៊ិន, ខុម និង នី ។ នួន ក៏បានទៅទាក់ទង គេង ជាយុទ្ធជនសួរចម្លើយនៅក្នុងក្រុមកាច ឲ្យជួយធ្វើសកម្មភាពប្រឆាំង ។ ខែមេសា នួន បានទៅបញ្ចុះបញ្ចូលឈ្មោះ ផល កងការពារអ្នកទោសឲ្យចូលរួមបំផុសចលនាក្នុងក្រុមឲ្យមានទំនាស់គ្នា ដោះលែងអ្នកទោសឬសម្លាប់ចោលខ្លះ នៅពេលដែលអ្នកទោសណាមួយពិបាកសួរយកចម្លើយ ។ ថ្ងៃមួយ គេង បានធ្វើឲ្យអ្នកទោសម្នាក់ឈ្មោះ ហាក់ មកពីសេនាធិការស្លាប់មែន ។ ចំណែក នួន បានវាយអ្នកទោសម្នាក់ឈ្មោះ សូ ឡាង ឲ្យស្លាប់នៅក្នុងពេលដែលអង្គការវាយសម្រុកពួក១៥២ (កងវរសេនាធំរបស់សេនាធិការ ទទួលបន្ទុកទូរស័ព្ទ កាំភ្លើងធំ ភស្តុភារ និងតម្លើងកប៉ាល់) ។ គង់ ក៏បានវាយអ្នកទោសស្លាប់ម្នាក់ ។ ក្រោយមកទៀត គង់ បានសួរចម្លើយអ្នកទោសម្នាក់មកពីកងពល១៧០ ។ នៅពេលសួរមិនចេញ គង់ បានដុតអ្នកទោសនោះស្លាប់ទាល់តែដាច់ចម្លើយ ។ សកម្មភាពបន្តទៀតរបស់ នួន គឺនិយាយតែពីកម្មាភិបាលនេះតឹង កម្មាភិបាលនោះធូរ ធ្វើដើម្បីឲ្យកម្មាភិបាលទាំងនោះមានទំនាស់ជាមួយយុទ្ធជន បង្កឲ្យមានបាតុភាពមិនចេះចប់នៅក្នុងក្រុម ។

ខែមិថុនា-កក្កដា ឆ្នាំ១៩៧៧ ផនលី ជាយុទ្ធជនសួរចម្លើយនៅស-២១ បានបបួល នួន រត់ទៅស្រុកយួន ដើម្បីកុំឲ្យអង្គការចាប់ខ្លួនទាន់ ពីព្រោះអង្គការកំពុងតាមរកចាប់យុទ្ធជនដែលក្បត់ជាបណ្តើរៗ ។ ក្រោយពីនិយាយគ្នារួច ផនលី ក៏រត់ទៅមុនទាំងយប់ធ្វើឲ្យមិត្តយុទ្ធជនភ្ញាក់ផ្អើលគ្រប់គ្នា ។ ក្រោយមក ផនលី ត្រូវអង្គការចាប់ខ្លួន ។ នួន ក៏មានផែនការរត់ដែរ ប៉ុន្តែមិនបានសម្រេច ហើយត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧ និងសួរចម្លើយនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៧ ។

**លី សុផល**

# ទីតាំងវាលពិឃាតខេត្តពោធិ៍សាត់

ខេត្តពោធិ៍សាត់ស្ថិតនៅភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា មានចម្ងាយ១៦៥គីឡូម៉ែត្រពីទីក្រុងភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៥ ។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ឆ្នាំង ខាងលិចជាប់នឹងខេត្តបាត់ដំបង ខាងជើងជាប់នឹងបឹងទន្លេសាប និងខាងត្បូងជាប់នឹងខេត្តកំពង់ស្ពឺនិងខេត្តកោះកុង ។ ខេត្តពោធិ៍សាត់មានស្រុកចំនួន៥គឺ ស្រុកកណ្តៀង ស្រុកពោធិ៍សាត់ ស្រុកបាកាន ស្រុកក្រគរ និងស្រុកភ្នំក្រវាញ ។ ក្នុងស្រុកទាំង៥នោះមានឃុំចំនួន៤៤ និងភូមិចំនួន៤៦៤ ។ ប្រជាជនភាគច្រើនជាអ្នកប្រកបរបរធ្វើស្រែចម្ការនិងលក់ដូរ ។ ខេត្តពោធិ៍សាត់មានផ្ទៃដីសរុបប្រមាណ ១.១៥៨.៨០០ហិកតា ស្មើនឹង១១.៥៨៨ ម៉ែត្រការ៉េ ។ ដីទាំងនោះត្រូវបានបែងចែកជាសណ្ឋានដីព្រៃចំនួន៨៧៩.៩០០ហិកតា ដីបង្កបង្កើនផលចំនួន១១៤.២០០ហិកតា ដីចម្ការចំនួន២.១០០ហិកតា និងដីសល់ទំនេរចំនួន១៦៤.៧០០ហិកតា ។

ក្រោមការគ្រប់គ្រងនៃរបបកម្ពុជាប្រជាធិបតេយ្យ ខេត្តពោធិ៍សាត់មានការប្រែប្រួលកំណើនមនុស្សយ៉ាងច្រើនដែលហូរចូលពីទីក្រុងភ្នំពេញនិងពីកន្លែងដទៃទៀតទូទាំងប្រទេស ក្រោមផែនការ“ជម្លៀស”របស់ខ្មែរក្រហម ។ ទឹកដីខេត្តពោធិ៍សាត់ពេញព្រៀបទៅដោយប្រជាជនជម្លៀស ។ ក្នុងសភាពការណ៍នៃការជម្លៀសភ្លាមៗបានធ្វើឲ្យប្រជាជនមួយចំនួនត្រូវស្លាប់នៅតាមផ្លូវដោយសារជំងឺ ការសម្លាប់ និងអត់អាហារ ។

ក្នុងរយៈពេលជាង៣ឆ្នាំក្រោមការកាន់អំណាចនៃរបបកម្ពុជាប្រជាធិបតេយ្យ ខេត្តពោធិ៍សាត់មានមន្ទីរឃុំឃាំងនិងទីតាំងវាលពិឃាតរីកដុះដាលជាច្រើនកន្លែង ។ ប្រជាជនជម្លៀសភាគច្រើនត្រូវបានបង្ខំឲ្យក្លាយទៅជាឧបករណ៍សម្រាប់ធ្វើទារុណកម្មនិងកាប់សម្លាប់មនុស្ស ។

ដើម្បីជាឧទាហរណ៍ជាក់ស្តែងនិងកាន់តែច្បាស់ក្នុងការស្វែងយល់អំពីអ្វីដែលខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជននៅខេត្តពោធិ៍សាត់ ខ្ញុំសូមលើកយកការសិក្សាស្រាវជ្រាវអំពីការស្វែងរកទីតាំងវាលពិឃាតមកធ្វើអធិប្បាយដូចខាងក្រោម÷

**១) ស្រុកកណ្តៀង**



ក្រុមអ្នកស្រាវជ្រាវកំពុងសាកសួរសាក្សីនៅវត្តកណ្តាល (អតីតគុកនៅរបបខ្មែរក្រហម)

***ទីតាំងសម្លាប់និងមន្ទីរសន្តិសុខនៅភូមិក្បាលឈើពុក***
***លេខកូដភូមិសាស្ត្រ: ១៥០២០២***
***ចំណុចខ្សែស្រប: (N) ១២° ៣៩’ ២១”***
***រយៈបណ្តោយ: (E) ១០៤° ០១’ ២១”***

ជនរងគ្រោះភាគច្រើនដែលត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ ខេត្តតាកែវ ខេត្តព្រៃវែងនិងខេត្តស្វាយរៀង បាន

ស្លាប់នៅក្នុងភូមិក្បាលឈើពុក ឃុំស្បា ស្រុកកណ្តៀង ។

ញឹក ប៉ាន់ អាយុ៥៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិបឹងចក ឃុំស្បា ស្រុកកណ្តៀង បាននិយាយថា ទោះជាការធ្វើទារុណកម្មទាំងនោះមានកម្រិតធ្ងន់ឬស្រាលខ្លះក៏ដោយ ក៏ជនរងគ្រោះនៅតែស្លាប់ដូចគ្នា ។ ការសម្លាប់មនុស្សនៅក្នុងភូមិក្បាលឈើពុកប្រើរយៈពេលតែមួយថ្ងៃគត់ ។ ញឹក ប៉ាន់ បានបន្តថា ក្នុងរយៈពេលតែមួយថ្ងៃគត់ កងឈ្លបខ្មែរក្រហមបានសម្លាប់មនុស្សអស់ជាង៨០០នាក់ ។ ញឹក ប៉ាន់ បានបន្ថែមថា ក្មួយស្រីគាត់ម្នាក់ឈ្មោះ ម៉ុក នី ក៏ត្រូវបានកងឈ្លបខ្មែរក្រហមវាយនឹងដំបងទម្លាក់ក្នុងរណ្តៅរួមជាមួយអ្នកដទៃទៀតដែរ ។ ប៉ុន្តែសំណាងល្អក្មួយស្រីម្នាក់នេះមិនស្លាប់ ហើយបានរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ។ បច្ចុប្បន្ន ម៉ុក នី រស់នៅទីក្រុងភ្នំពេញ ។ ញឹក ប៉ាន់ បានរំឭកអំពីក្មួយគាត់ថា «វា(ម៉ុកនី) បានធ្វើពុតជាស្លាប់នៅពេលដែលកងឈ្លបខ្មែរក្រហមបានវាយនឹងដំបងយ៉ាងខ្លាំងទម្លាក់ពីលើមាត់រណ្តៅជាមួយអ្នកឯទៀត» ។ ស្ថានភាពរបួសរបស់ម៉ុក នី នាពេលនោះ មានសភាពធ្ងន់ធ្ងរបំផុត លលាដ៍ក្បាលរបស់គាត់បែកនិងហូរឈាមយ៉ាងច្រើន ។ ម៉ុក នី សន្លប់នៅពីលើសាកសពជាច្រើនដែលបានស្លាប់ដោយការវាយនឹងដំបង ។ ម៉ុក នី ស្ទើរតែរើខ្លួនចេញមិនរួចពីក្នុងគំនរសាកសពដែលសង្កត់ពីលើ ។ ដោយសេចក្តីព្យាយាម ម៉ុក នី បានខំប្រឹងវារចេញពីគំនរសាកសពទាំងត្រដាបត្រដួសក្នុងពេលយប់ស្ងាត់ ។ ញឹក ប៉ាន់ បានបន្ថែមថា «ខ្ញុំភ្ញាក់ព្រើតនៅពេលដែលឃើញវា (ម៉ុក នី) មកដល់ខ្ទមរបស់ខ្ញុំទាំងកណ្តាលយប់អធ្រាត្របែបនេះ» ។ ម៉ុក នី ជាមនុស្សតែម្នាក់គត់ដែលសល់ពីការស្លាប់នៅក្នុងរណ្តៅនៃភូមិក្បាលឈើពុក ។ ញឹក ប៉ាន់ បានពន្យល់ថា ការសម្លាប់មនុស្សនៅក្នុងរណ្តៅនៃភូមិក្បាលឈើពុកនេះគឺប្រព្រឹត្តនៅពេលយប់ ។ រណ្តៅនេះមានទំហំបណ្តោយជាង១០ម៉ែត្រ ទទឹងជាង១០ម៉ែត្រ និងជម្រៅប្រហែល៣ម៉ែត្រ ។ ជនរងគ្រោះដែលបានស្លាប់នៅក្នុងរណ្តៅនេះគឺយកមកពីមន្ទីរស-៨ ដែលជាមន្ទីរឃុំឃាំងស្ថិតនៅក្នុងភូមិក្បាលឈើពុក ។ ញឹក ប៉ាន់ បានស្គាល់



ហាក់ សុផល និង ហែម ជា (សាក្សី) កំពុងឈរពីមុខរណ្តៅសាកសពជនរងគ្រោះនៅទួលតាប៉ើវ ស្រុកកណ្តៀង

ឈ្មោះសន្តិសុខគុកចំនួនបីនាក់គឺៈ ១) ឈ្មោះ ឈាង បច្ចុប្បន្នរស់នៅស្រុកកណ្តៀង ២) ឈ្មោះ ប៉ោ ជាឃាតករដ៏សាហាវម្នាក់ (បច្ចុប្បន្នស្លាប់) ៣) ឈ្មោះ មី (បាត់ខ្លួន) ។ មី ធ្លាប់ត្រូវបានឃាត់ខ្លួនដោយរដ្ឋអំណាចនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ប៉ុន្តែក្រោយមកត្រូវបានដោះលែងវិញ ។

**ទីតាំងសម្លាប់និងមន្ទីរសន្តិសុខទួលតាប៉េវ(មន្ទីរ០៧)**

**លេខកូដភូមិសាស្ត្រៈ១៥០២០៣**

**ចំណុចខ្សែស្របៈ (N) ១២° ៣៤' ៥០"**

**រយៈបណ្តោយៈ (E) ១០៣° ៥៥' ៥៨"**

ទីតាំងសម្លាប់និងមន្ទីរសន្តិសុខទួលតាប៉េវ(មន្ទីរ០៧) ស្ថិតក្នុងភូមិផ្លូវពោធិ៍វង្ស ឃុំផ្លូវពោធិ៍វង្ស ស្រុកកណ្តៀង ។ មន្ទីរសន្តិសុខ០៧ ឃុំឃាំងប្រភេទអ្នកទោសដូចជា អ្នកលួចរបស់របរ អ្នកមកធ្វើការមិនទាន់ពេលវេលា និងអ្នកដែលធ្វើពុតឈឺ ខ្ជិលធ្វើការងារ ។ មន្ទីរនេះគ្រប់គ្រងដោយកម្មាភិបាលចំនួនបីរូបគឺ ១) ហួយ (បច្ចុប្បន្នស្លាប់) ទី២) ប៉ិល និង ទី៣) ឈ្មោះ ផន (បច្ចុប្បន្នរស់នៅស្រុកកណ្តៀង) ។ ហែម ដាង អាយុ ៤៣ឆ្នាំ ជាអតីតប្រធានកងឈ្លបក្នុងរបបខ្មែរក្រហម បាននិយាយថា គាត់ធ្លាប់ឃើញខ្មែរក្រហមបណ្តើរអ្នកទោសទៅធ្វើការ និងឃើញអ្នកទោសជីករណ្តៅ ដែលក្រោយមករណ្តៅដែលជីកនោះត្រូវកប់ខ្លួនឯងវិញ ។ ហែម ដាង បានបន្តថា នៅទីតាំងសម្លាប់ទួលតាប៉េវមានជាង៣០រណ្តៅ និងមានអ្នកទោសស្លាប់ចំនួនច្រើនជាង៣០០នាក់ ។

**ទីតាំងសម្លាប់ទួលពោធិ៍ជ្រៃ**

**លេខកូដភូមិសាស្ត្រៈ១៥០២០១**

**ចំណុចខ្សែស្របៈ (N) ១២° ៤១' ៣៣ៈ ៩៤"**

**រយៈបណ្តោយៈ (E) ១០៣° ៥៨' ១២ៈ ៨៥"**

ទួលពោធិ៍ជ្រៃជាទួលមួយស្ថិតនៅក្នុងបន្ទាយទាហាននៃកងវរសេនាតូចខេត្តពោធិ៍សាត់ ក្នុងរបបខ្មែរក្រហម ដែលមានដើមពោធិ៍ជ្រៃមួយដើមជាសម្គាល់ ។ បន្ទាយពោធិ៍ជ្រៃ ឬទួលពោធិ៍ជ្រៃ មានចម្ងាយ១៥គីឡូម៉ែត្រពីសាលាស្រុកកណ្តៀង និងស្ថិតនៅក្នុងភូមិព្រីងខ្ពស់ ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។ ទួលពោធិ៍ជ្រៃ មានទទឹងប្រវែង៦០០ម៉ែត្រ និងបណ្តោយ៨០០ម៉ែត្រ ។ ទួលនេះមានរបងព័ទ្ធជុំវិញ៤ជាន់ កម្ពស់ប្រហែលពីរម៉ែត្រកន្លះទៅបីម៉ែត្រ ត្រូវបានសាងសង់ឡើងនៅឆ្នាំ១៩៧០ ដោយកម្លាំងរបស់ប្រជាជននៅក្នុងភូមិព្រីងខ្ពស់ ។ លុះដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមបានយកបន្ទាយនេះធ្វើជាមន្ទីរសន្តិសុខនិងកន្លែងសម្លាប់រហូតមកដល់ឆ្នាំ១៩៧៨ ។ ទួលពោធិ៍ជ្រៃគឺជាទីតាំងសម្លាប់និងជាមន្ទីរសន្តិសុខដ៏ធំមួយ បើប្រៀបធៀបទៅនឹងទីតាំងសម្លាប់ផ្សេងៗទៀតនៅក្នុងខេត្តពោធិ៍សាត់ ។ ស្រះទឹកដ៏ធំសម្បើមមួយ នៅក្នុងបរិវេណទួលពោធិ៍ជ្រៃបានប្រែក្លាយទៅជារណ្តៅកប់សាកសពជនរងគ្រោះ ។ ជនរងគ្រោះដែលបាននាំយកមកពីមន្ទីរឃុំឃាំងពោធិ៍ជ្រៃ ភាគច្រើនជាចៅហ្វាយខេត្ត នាយទាហាន នាយទាហានរង និងអ្នកមានបណ្តាស័ក្តិធំៗ ក្រុមកុម្ម៉ង់ដូ មន្ត្រីរដ្ឋការទូទៅ គ្រូបង្រៀន សិស្សនិស្សិត ទូទាំងខេត្តពោធិ៍សាត់ និងមួយចំនួនទៀត ត្រូវបាននាំមកពីកន្លែងដទៃទៀតក្នុងខេត្តពោធិ៍សាត់ ។




សេង ស្រ៊ុន បាននិយាយប្រាប់ថា ក្នុងរយៈកាលនៃការសម្លាប់ដំបូងរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ មានជនរងគ្រោះស្លាប់ប្រមាណ៦០០០នាក់ ។ លុះមកដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាប់ផ្តើមប្រមែប្រមូលប្រជាជនដែលមានបងប្អូនធ្វើជាទាហានប៉ូលិស មន្ត្រីរដ្ឋការ អ្នកមកពីទីក្រុងភ្នំពេញ រួមទាំងអ្នករស់នៅក្នុងខេត្តពោធិ៍សាត់ផង យកមកសម្លាប់នៅទួលពោធិ៍ជ្រៃមួយសាទៀត ។ លើកនេះ ជនរងគ្រោះមិនត្រូវបានចាប់ដាក់ឃុំឃាំងជាមុនទេ គឺខ្មែរក្រហមយកទៅសម្លាប់ភ្លាមតែម្តង ។ សេង ស្រ៊ុន បានបញ្ជាក់ពីតួលេខអ្នកស្លាប់ថាមានចំនួនប្រមាណ ២៥០០នាក់ ។ ចាប់ពីឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៨ ប្រជាជនខាងភូមិភាគបូព៌ាប្រមាំជាង១០០០នាក់ទៀត ត្រូវបានសម្លាប់នៅលើទួលពោធិ៍ជ្រៃ ដោយជាប់ចោទថាជាអ្នកចូលរួមក្បត់ជាមួយ សោ ភឹម ប្រធានភូមិភាគបូព៌ា ។ មានរថយន្តធំៗចំនួនជាង១០គ្រឿង បានដឹកជញ្ជូនប្រជាជននិងកម្មាភិបាលខ្មែរ

ក្រហមភូមិភាគពួកបូព៌ាមកសម្លាប់ ។ សេង ស្រ៊ិន បានបន្ថែមថា ជនរងគ្រោះដែលបានស្លាប់នៅបន្ទាយពោធិ៍ជ្រៃសរុបទាំងអស់មានចំនួនរហូតដល់ជាង១ម៉ឺននាក់ ។ កងសន្តិសុខខ្មែរក្រហមបានបាញ់រះទៅលើជនរងគ្រោះ បន្ទាប់មកបរត្រាក់ទ័ររុញអាចម៍ដីលុបពីលើសាកសព ។ អណ្តូងទឹកដែលមានទំហំបណ្តោយជាង ២០ម៉ែត្រនិងជម្រៅជិត៣ម៉ែត្រ កាន់តែរាក់បន្តិចម្តងៗ រហូតក្លាយជាដីរាបស្មើធម្មតា ។ មកដល់បច្ចុប្បន្ននេះ ដោយសារធម្មជាតិមានការប្រែប្រួលអតីតអណ្តូងទឹកដែលលុបដីស្ទើរតែរាបស្មើនោះបានស្រុតទៅវិញខ្លះៗ រហូតធ្វើឲ្យមានសភាពជាដីទំនាបដក់ទឹកនារដូវវស្សា ។

**២) ស្រុកសំពៅមាស**

**ទីតាំងសម្លាប់និងមន្ទីរសន្តិសុខវត្តកោះជុំ**

**លេខកូដភូមិសាស្ត្រៈ១៥០៥០៤,៥**

**ចំណុចខ្សែស្របៈ (N) ១២° ៣៥’ ២៣”**

**រយៈបណ្តោយៈ (E) ១០៣° ៥៣’ ១៨ ”**

ភាពអត់ឃ្លាននិងការបាត់ខ្លួនជារៀងរាល់ថ្ងៃ បានធ្វើឲ្យអ្នកទោសនៅក្នុងមន្ទីរឃុំឃាំងវត្តកោះជុំ ខំប្រឹងប្រែងធ្វើការទាំងត្រដរ ដើម្បីប្តូរមកវិញនូវរបបអាហារបន្តិចបន្តួចនិងការរស់រានមានជីវិត ។ អ្នកទោសម្នាក់ៗបានទទួលរបបបបររាវតែមួយឬពីរវែកប៉ុណ្ណោះក្នុងមួយថ្ងៃ ។

ប៊ួយ អ៊ូផល អាយុ៥៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្តុកជុំ ឃុំកោះជុំ ស្រុកសំពៅមាស បាននិយាយថា មានអង្ករចំនួន១០ កំប៉ុង ត្រូវដាំបបរសម្រាប់អ្នកទោសចំនួនពី៣៨០ទៅ៤០០ នាក់ក្នុងមួយថ្ងៃ ។ ប៊ួយ អ៊ូផល បានបន្តថា អ្នកទោស ដែលបានជាប់នៅមន្ទីរឃុំឃាំងវត្តកោះជុំនេះ ត្រូវបានបែងចែកជាបីរោងបាយធំៗ ។ រោងបាយទាំងបីមានអ្នកទោសសរុបជាងមួយពាន់នាក់ ។ ប៊ួយ អ៊ូផល បានប្រាប់ទៀតថា គាត់បានឃើញខ្មែរក្រហមបណ្តើរអ្នកទោសទៅធ្វើការទាំងជើងជាប់ច្រវាក់ ។ ការងារដែលអ្នកទោសធ្វើ គឺដកស្ទូងនិងច្រូតកាត់ ។ លុះដល់ចុងឆ្នាំ១៩៧៨ អ្នកទោសទាំងអស់លែងបានមកដកស្ទូងនិងច្រូតកាត់ទៀតហើយ ព្រោះត្រូវសម្លាប់ចោលគ្មានសល់ ។ ប៊ួយ អ៊ូផល បាននិយាយទាំងខ្សឹកខ្សួលថា ក្នុងចំណោមសាកសពទាំងជាង១០០០នាក់នេះ មាន៦នាក់ជាកូនបង្កើតរបស់គាត់ ។

ថ្វាង ភឹម អាយុ៤៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្តុកជុំ ឃុំកោះជុំ ស្រុកសំពៅមាស បានរៀបរាប់ថា គាត់បានឃើញកងឈ្លបខ្មែរក្រហមក្មេងៗដែលមានអាយុប្រមាណ១៥ឬ១៦ ឆ្នាំ ចងអ្នកទោសទាំងខ្សែៗ បណ្តើរពីវត្តកោះជុំយកទៅសម្លាប់នៅពេលយប់ ។ ថ្វាង ភឹម បានបន្តថា អ្នកទោសស្ទើរតែទាំងអស់សុទ្ធតែទទួលរងនូវការធ្វើទារុណកម្មយ៉ាងសាហាវពីកងឈ្លបវ័យក្មេងខ្មែរក្រហម ។ អ្នកទោសភាគច្រើនជាប្រជាជនជម្លៀសនិងអ្នកជាប់និន្នាការពីរបបសាធារណរដ្ឋខ្មែរ ។ ទីតាំងសម្លាប់មនុស្សនៅវត្តកោះជុំមានរណ្តៅចំនួនជាង១០០កន្លែងនិងសាកសពចំនួនជាង១០០០នាក់ ។

ថ្វាង ភឹម ស្គាល់មេសន្តិសុខនៅវត្តកោះជុំ ឈ្មោះ ផន (សព្វថ្ងៃគេចខ្លួន) ។ ផន ជាមេធំប្រចាំនៅវត្តកោះជុំ ។ ផន មានរហស្សនាមមួយទៀតថា “តាមុខពីរ” ។ ចំណែកឯអ្នកក្រោមបង្គាប់ តាផន មានពីរនាក់ទៀតឈ្មោះ សៀក (បច្ចុប្បន្នស្លាប់) និង ឈ្មោះ ហ៊ី (បច្ចុប្បន្នរស់នៅស្រុកបាកាន) ។

**៣) ស្រុកភ្នំក្រវាញ**

**ទីតាំងសម្លាប់និងមន្ទីរសន្តិសុខវត្តកណ្តាល**

**លេខកូដភូមិសាស្ត្រៈ១៥០៤០៧,៨**

**ចំណុចខ្សែស្របៈ(N) ១២° ២០’៥១”**

**រយៈបណ្តោយៈ(E)១០៣°៤៦’៤០”**

វត្តកណ្តាលត្រូវបានខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខប្រចាំឃុំសន្ទ្រែ ។ វត្តនេះស្ថិតនៅក្នុងភូមិទល់ទទឹង ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ។ កុដិជាច្រើននៅវត្តកណ្តាលត្រូវបានប្រែក្លាយជាមន្ទីរធ្វើការនិងកន្លែងសួរចម្លើយរបស់ខ្មែរក្រហម ។ រហូតមកដល់បច្ចុប្បន្ន ទីវត្តអារាមនេះមិនត្រូវបានបំផ្លាញទាំងស្រុងទេ ប៉ុន្តែជីវិតមនុស្ស ត្រូវបានបំផ្លាញស្ទើរគ្មានសល់ ។ សុខ សាន បច្ចុប្បន្នជាអនុសេនីយ៍ឯកនៃការិយាល័យទី៥ កងពលធំទី៨ ខេត្តពោធិ៍សាត់ បានរៀបរាប់ថា គាត់ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ មករស់នៅខេត្តពោធិ៍សាត់ដូចប្រជាជនឯទៀតដែរ ហើយត្រូវបានបង្ខំឲ្យធ្វើការងារលំបាកៗជាច្រើនរាប់មិនអស់ ។ នៅខែមករា ឆ្នាំ១៩៧៨ សុខ សាន ត្រូវ

បានចាប់ខ្លួនយកមកដាក់ក្នុងមន្ទីរឃុំឃាំងវត្តកណ្ដាលដោយគ្មានមូលហេតុ ។ អ្នកទោសដែលជាប់នៅវត្តកណ្ដាលនេះមានលាយចម្រុះគ្នា អ្នកទោសខ្លះជាប្រជាជនជម្លៀស ខ្លះជាអ្នកមូលដ្ឋាន និងខ្លះទៀតជាកម្មាភិបាលខ្មែរក្រហមដូចជា គណៈស្រុក និងប្រធានពាណិជ្ជកម្មតំបន់ ដែលត្រូវចោទថាក្បត់នឹងអង្គការ ។ សុខ សាន បាននិយាយទៀតថា អ្នកទោសប្រមាណ២៦០នាក់ត្រូវបានឈ្លបខ្មែរក្រហមចងខ្សែភ្ជាប់គ្នាពីរៗនាក់ បណ្ដើរយកទៅសម្លាប់ ។ ចំណែកឯខ្លួនគាត់វិញ ឈ្លបចងតែម្នាក់ឯងគត់ ។ ប៉ុន្តែក្នុងពេលកំពុងសម្លាប់មានចលាចលកើតឡើងដោយសារការតដៃគ្នារវាងអតីតគណៈស្រុកខ្មែរក្រហមឈ្មោះ ម៉ាល់ និងកងឈ្លប(អ្នកសម្លាប់) ។ ជាឱកាសល្អ សុខ សាន បានលួចរត់ទាំងចំណងចេញពីទីកន្លែងសម្លាប់នោះ ។ សុខ សាន បានរំឭកថា ការសម្លាប់មនុស្សក្នុងពេលនោះ ខ្មែរក្រហមបានប្រើដំបង ព្រនង់ កាំបិតនិងចំពុះទុងកាំភ្លើង ជាឧបករណ៍សម្លាប់ ។ កងឈ្លបខ្មែរក្រហមបានបញ្ជាឲ្យអ្នកទោសលុតជង្គង់នៅមាត់រណ្ដៅ រួចចាប់ភ្ញើយក្បាលឡើងលើ យកកាំបិតចាក់បំពង់កតែម្ដង ។

ឈឹម លន់ អាយុ៦៦ឆ្នាំ មានស្រុកកំណើតនៅឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល បច្ចុប្បន្នរស់នៅខេត្តពោធិ៍សាត់ បាននិយាយថា ខ្លួនគាត់ត្រូវខ្មែរក្រហមចាប់យកទៅឃុំឃាំងនៅវត្តកណ្ដាល ពីបទ«មើលងាយ»អង្គការ ។ ឈឹម លន់ បានបន្តថា គាត់មិនបានមើលងាយអង្គការទេ គ្រាន់តែគាត់ធ្វើការងារមិនសម្រេចតាមផែនការដែលអង្គការដាក់ចុះប៉ុណ្ណោះ ។ ឈឹម លន់ បានជាប់គុកនៅវត្តកណ្ដាលអស់រយៈពេលជាងមួយឆ្នាំ (គិតមកដល់ខែមករា ឆ្នាំ១៩៧៩) ។ នៅក្នុងគុក គាត់បានខិតខំធ្វើការស៊ើរគ្មានពេលសម្រាកទេ ។ ឈឹម លន់ បាននិយាយអំពីរឿងរ៉ាវរបស់ស្ត្រីម្នាក់ឈ្មោះយាយ មុំ ដែលជាប់គុកអស់រយៈពេលជាងបីខែ បន្ទាប់ពីបានបេះល្ហុងរបស់ខ្លួនមួយផ្លែយកមកស្ងោរ ស្ងួតកាលពីឆ្នាំ១៩៧៥ ។ នៅមានប្រជាជនជាច្រើននាក់ទៀតបាន



រណ្ដៅសាកសព នៅវត្តកោះជុំ ស្រុកសំពៅមាស កោ ទិព្

មកដាប់នៅក្នុងគុកវត្តកណ្ដាលនេះដោយសារតែរឿងកំប៉ិកកំប៉ុក ប្រហាក់ប្រហែលនឹងករណីយាយ មុំ ដែរ ។ អំណាចនៃការក្ដោបក្ដាប់គុកវត្តកណ្ដាល ត្រូវឋិតនៅក្នុងកណ្ដាប់ដៃរបស់កម្មាភិបាល ឡុក ជាប្រធាន (បច្ចុប្បន្នស្លាប់) កម្មាភិបាល ចាន់ ជាអនុប្រធានសព្វថ្ងៃរស់នៅស្រុកភ្នំក្រវាញ និងកម្មាភិបាល ម៉េត ជាសន្តិសុខ ។ ឈឹម លន់ បានឲ្យដឹងថាឈ្មោះ ម៉េត ជាជនដៃដល់សម្លាប់ប្រជាជនជាង៣០០០នាក់ជុំវិញបរិវេណវត្តកណ្ដាល ។ បច្ចុប្បន្ន ម៉េត បានស្លាប់បាត់ទៅហើយ ។ មានពីរនាក់ទៀតជាជនដៃដល់ដែរ គឺ ជុំ និង ប៉ត ។ អ្នកទាំងពីរនេះក៏បានស្លាប់ទៅហើយដែរ ។

***៤) ស្រុកបាកាន***

***ទីតាំងមន្ទីរសន្តិសុខបឹងបត់កណ្ដាល***

***លេខកូដភូមិសាស្ត្រៈ១៥០១០៩***

***ចំណុចខ្សែស្របៈ (N) ១២° ៣៧’ ៣២”***

***រយៈបណ្ដោយៈ (E) ១០៣° ៤៦’ ៤៨”***

មន្ទីរសន្តិសុខមួយកន្លែងត្រូវបានបង្កើតឡើងនៅក្នុងឃុំបឹងបត់កណ្ដាល ស្រុកបាកាន ។ ទីតាំងនេះមានឈ្មោះហៅថា មន្ទីរសន្តិសុខបឹងបត់កណ្ដាល មានចម្ងាយប្រហែល៤គីឡូម៉ែត្រពីសាលាស្រុកបាកាន ។ មន្ទីរសន្តិសុខបឹងបត់កណ្ដាលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៧៥និងដំណើរការរហូតដល់ចុងឆ្នាំ១៩៧៩សម្រាប់ឃុំឃាំងជនរងគ្រោះគ្រប់ប្រភេទ ដែលចាប់មកពីបណ្ដាខេត្តក្រុងនិងមូលដ្ឋានរហូតដល់ ។

ចាន់ ប៉េង អាយុ៥៦ឆ្នាំ បានរៀបរាប់ថា គាត់ឃើញឈ្លបបញ្ជូនជនរងគ្រោះមកទីនេះជារៀងរាល់ថ្ងៃ (មកពីខេត្តព្រៃវែង ស្វាយរៀង ស្រុកក្រគរ និងស្រុកពោធិ៍សាត់ជាដើម) ។ ប្រភេទជនរងគ្រោះទាំងនោះភាគច្រើនជាទាហានដែលមានស័ក្តិធំៗ មន្ត្រីរដ្ឋការនិងប្រជាជន ។ នៅ សាន ជាអតីតរដ្ឋអំណាចភូមិដូងជ្រុំ ឃុំបឹងបត់កណ្ដាល នៅឆ្នាំ១៩៧៧ ហើយក្រោយមកត្រូវបានតែងតាំងជាសមាជិកសហករណ៍ភូមិព្រៃផ្ដៅ ឃុំបឹងខ្នារ បានបញ្ជាក់ប្រាប់ថា “គាឃីន” គឺជាមេសន្តិសុខនៅបឹងបត់កណ្ដាល ។ ឈ្មោះនេះបានបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ន ។

***ទីតាំងសម្លាប់ព្រៃភាគ***

***លេខកូដភូមិសាស្ត្រៈ១៥០១១០***

***ចំណុចខ្សែស្របៈ (N) ១២° ៣៧’ ០៤”***

***រយៈបណ្ដោយៈ (E) ១០៣°៤៧’ ៣៦”***

ព្រៃភាគស្ថិតនៅមិនឆ្ងាយប៉ុន្មានពីមន្ទីរសន្តិសុខវត្តកណ្ដាល ។ អ្នកទោសត្រូវបាននាំមកពីមន្ទីរសន្តិសុខវត្តកណ្ដាលទៅសម្លាប់នៅព្រៃភាគ ។ នៅទីនោះមានស្នាកស្នាមរណ្ដៅជាច្រើន ។ អ្នកស្រុកបានគាស់កកាយរណ្ដៅសាកសពដើម្បីរកមាសនៅឆ្នាំ១៩៨០ ។

ចាន់ ប៉េង បានរៀបរាប់ថា គាត់បានឃើញរណ្ដៅជាច្រើនដែលពេញទៅដោយសាកសពហើមស្អុយរលួយចូលជិតស្ទើរមិនបាន ។ ការសម្លាប់ជនរងគ្រោះនៅព្រៃភាគ ប្រព្រឹត្តឡើងតាំងពីឆ្នាំ១៩៧៥រហូតដល់ចុងឆ្នាំ១៩៧៨ ។ ការសម្លាប់នៅព្រៃភាគមានបីដំណាក់កាលគឺៈ ទី១) នៅឆ្នាំ១៩៧៥ ខ្មែរក្រហមសម្លាប់ចាប់ពីទាហានស័ក្តិ១ឡើងទៅ ទី២) នៅឆ្នាំ១៩៧៦-៧៧ ខ្មែរក្រហមបានចំរាញ់ប្រភេទជនរងគ្រោះដែលជាអ្នកគស៊ូយូរអង្វែងឬកម្មាភិបាលក្នុងសម័យប្រជាជាតិយកទៅសម្លាប់ និងទី៣) នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានសម្លាប់ជនរងគ្រោះដែលបានជម្លៀសមកពីភូមិបូព៌ា ដូចជាខេត្តព្រៃវែងនិងខេត្តស្វាយរៀង ។

ចាន់ ប៉េង បាននិយាយថា បងប្អូនជីដូនមួយរបស់គាត់ចំនួនពីរនាក់បានស្លាប់ដោយសារតែពួកគេមានស័ក្តិធំ ។ ជនរងគ្រោះចំនួនប្រហែល៦០នាក់ផ្សេងទៀត ក៏ត្រូវឈ្លបបណ្ដើរយកទៅសម្លាប់នៅក្នុងអំឡុងឆ្នាំ១៩៧៦-៧៧ រួមជាមួយអ្នកគស៊ូយូរអង្វែង ។ ចាន់ ប៉េង បានប្រាប់ទៀតថា ទីតាំងសម្លាប់ព្រៃភាគមានជង្រុកនីមួយៗប្រវែងពីរគីឡូម៉ែត្រកន្លះ មានផ្ទុកសាកសពចំនួនប្រហែលពី៩០០០ទៅ១៥០០០នាក់ ។

ចំណែកលោក សុខ សុវណ្ណ បានអះអាងថា ទីតាំងសម្លាប់នៅព្រៃភាគមានរណ្ដៅពី៣០០ទៅ៤០០ ។

នៅ សាន អាយុ៤៨ឆ្នាំបានឲ្យដឹងថា រណ្ដៅនីមួយៗមានជង្រុកប្រវែងបីម៉ែត្រនិងជម្រៅ២ម៉ែត្រ អាចដាក់សាកសពពី៣០ទៅ៧០នាក់ ។ **(នៅមានត)**

**ផេង ពង្សរ៉ាស៊ី**

# បញ្ជីឈ្មោះជនរងគ្រោះបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

**រៀបចំនិងចងក្រងដោយៈ យិន នាន**

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ១ | ណាង ដាវ (ស្រី) | លាវ | ប្រពន្ធចរឹន ស៊ុប | តំបន់៣៣ | ៧-៤-៧៦ | ២៤-៥-៧៦ |
| ២ | ណាង កែវ (ស្រី) | លាវ | នេសាទត្រី | តំបន់៣៣ | ៧-៤-៧៦ | ២៤-៥-៧៦ |
| ៣ | ម៉ាយ ចរឹនស៊ុប | លាវ | ជាងម៉ាស៊ីន | តំបន់៣៣ | ៧-៤-៧៦ | ២៤-៥-៧៦ |
| ៤ | ថាវ ប៊ុនថាវី | លាវ | ជាងយន្តហោះ | តំបន់៣៣ | ៧-៤-៧៦ | ២៤-៥-៧៦ |
| ៥ | កេ វ៉ាល់វ៉ា | ឥណ្ឌូ | ? | តំបន់២២ | ? | ៨-៤-៧៦ |
| ៦ | ម៉ូហាមេត | ឥណ្ឌូ | ? | តំបន់២២ | ? | ៨-៤-៧៦ |
| ៧ | កេ សូដា | ឥណ្ឌូ | ? | តំបន់២២ | ? | ៨-៤-៧៦ |
| ៨ | អ៊ីស ស្មាអ៊ី | ឥណ្ឌូ | ? | គាកែវ | ៨-៤-៧៦ | ៨-៤-៧៦ |
| ៩ | ម៉ូហ្កាម៉ា ឌូយិត្រិយ៉ា | ? | លក់គ្រឿងការី | គាកែវ | ៨-៤-៧៦ | ៨-៤-៧៦ |
| ១០ | អាហ្សីហ្សាវ៉ាប៊ីប៊ី(ស្រី) | ឥណ្ឌូ | ចិញ្ចឹមគោ | តំបន់២៥ | ? | ២៩-៤-៧៦ |
| ១១ | គីម ការិនយ៉ាប៉ូ | ឥណ្ឌូ | អាហារណ៍នីហរណ៍ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ១២ | ហាស់សា | ឥណ្ឌូ | លក់ដូរ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ១៣ | អាស៊ីស ហាលីម៉ា(ស្រី) | ឥណ្ឌូ | លក់ដូរ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ១៤ | អាស៊ីស សាវ៉ាឌីវី(ស្រី) | ឥណ្ឌូ | លក់ដូរ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ១៥ | អាស៊ីស អ៊ីសាស់កាន់នី(ស្រី) | ឥណ្ឌូ | លក់ដូរ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ១៦ | អាហ្សីហ្ស ការីម | ឥណ្ឌូ | លក់ប្រេងកូឡា | ? | ១១-៤-៧៦ | ? |
| ១៧ | អ៊ី ស្មាអ៊ិល | ឥណ្ឌូ | នៅជាមួយបារាំង | ស្រុក៥៦ | ?-?-៧៧ | ? |
| ១៨ | ម៉ារីយ៉ាន់ (ស្រី) | ឥណ្ឌូ | លក់ដូរ | ស្រុក១៤ | ១២-៤-៧៦ | ? |
| ១៩ | គីមដាត | ប៉ាគីស្ថាន | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ២០ | អាសុខាន់នេប្រាហិម | ប៉ាគីស្ថាន | កូនសិស្ស | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ២១ | មេ ដាម | ប៉ាគីស្ថាន | ចិញ្ចឹមគោ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ២២ | អាប់ ឌុលឡា | ប៉ាគីស្ថាន | ចិញ្ចឹមគោ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ២៣ | ណាស៊ីអាស់ស្មាត់ | ប៉ាគីស្ថាន | ចិញ្ចឹមគោ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ២៤ | សាអ៊ិត | ប៉ាគីស្ថាន | ចិញ្ចឹមគោ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ២៥ | ហាស់សាន់ | ប៉ាគីស្ថាន | ចិញ្ចឹមគោ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ២៦ | ការីម | ប៉ាគីស្ថាន | លក់ដូរ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ២៧ | សាវ៉ាបាត់ វ៉ាន់ណៃ (ស្រី) | ប៉ាគីស្ថាន | កាត់ដេរ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ២៨ | ខាឌីយ៉ា | ប៉ាគីស្ថាន | កាត់ដេរ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ២៩ | សាវ៉ាបាត់ ស៊ីរីណី (ស្រី) | ប៉ាគីស្ថាន | លក់ដូរ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ៣០ | សាអ៊ីត | ប៉ាគីស្ថាន | ចិញ្ចឹមគោ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣១ | ឌី សូយ៉ាន់ (ស្រី) | ប៉ាគីស្ថាន | លក់ដូរ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ៣២ | នូសាហ្សា យីដា (ស្រី) | ប៉ាគីស្ថាន | ចិញ្ចឹមគោ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ៣៣ | អាសុខាន់ អានប្រាហ៊ីប | ប៉ាគីស្ថាន | កូនសិស្ស | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ៣៤ | សារ៉ាបាត់ ឡាល់ម៉ាត់យ៉ាង(ស្រី) | ប៉ាគីស្ថាន | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៣៥ | ប៊ី គីមយ៉ាន | ប៉ាគីស្ថាន | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៣៦ | វ៉ាតីរីយ៉ា | ប៉ាគីស្ថាន | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៣៧ | ម៉ារៀម | ប៉ាគីស្ថាន | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៣៨ | ម៉ាត់ យ៉ាន | ប៉ាគីស្ថាន | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៣៩ | ស៊ីម៉ារៀម | ប៉ាគីស្ថាន | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៤០ | ម៉ីលីយ៉ុប | ប៉ាគីស្ថាន | លក់ដូរ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៤១ | គង់ សេន | អារ៉ាប់ | ចិញ្ចឹមគោ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ៤២ | សាហ៊្វា | អារ៉ាប់ | ចិញ្ចឹមគោ | តំបន់២៥ | ១១-៤-៧៦ | ?-?-៧៦ |
| ៤៣ | សេត កាន់លាល់ | អារ៉ាប់ | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៤៤ | ហ្គូលៀ | អារ៉ាប់ | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៤៥ | សាលីមា | អារ៉ាប់ | ចិញ្ចឹមគោ | ? | ១១-៣-៧៦ | ?-?-៧៦ |
| ៤៦ | កៀវ៉ា (ស្រី) | ក្លឹងឥណ្ឌា) | លក់កង់ឡាន | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ៤៧ | អាហ្សីហ្វ | ក្លឹងឥណ្ឌា) | លក់ក្រណាត់ | តំបន់២៥ | ១១-៣-៧៦ | ?-?-៧៦ |
| ៤៨ | រ៉ូវ៉ា ហៀរណា | បារាំង | ជំនួញតាមកប៉ាល់ | សៀមរាប | ១៦-៤-៧៦ | ?-?-៧៦ |
| ៤៩ | ហាវ៉ា ហៀរណា | បារាំង | ជំនួញតាមកប៉ាល់ | សៀមរាប | ១៦-៤-៧៦ | ?-?-៧៦ |
| ៥០ | គ្រូទីញ្ញេអង់ជ្រេហ្គាល់ស្តុង | បារាំង | លេខាធិការទូតបារាំង | សៀមរាប | ១៦-៤-៧៦ | ?-?-៧៦ |
| ៥១ | ឆាយ រាស្មី (ស្រី) | បារាំង | ប្រពន្ធគ្រូទីញ្ញេអង់ជ្រេហ្គាល់ស្តុង | សៀមរាប | ១៦-៤-៧៦ | ?-?-៧៦ |
| ៥២ | អ៊ី ស៊ីម (ស្រី) | ចិន | ? | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ៥៣ | តាន់ ហួយ | ចិន | ? | ចិន | ២០-១០-៧៦ | ៣០-១០-៧៦ |
| ៥៤ | ស៊ុ ដា មីង | ចិន | បកប្រែចិននៅស៊ីងហាវ | កំពង់សោម | ១២-៥-៧៨ | ? |
| ៥៥ | ម៉ាយកុល ស្កុតឌីត | អាមេរិក | ? | ? | ២៦-១១-៧៨ | ? |
| ៥៦ | ជីម វីល្យ៉ាមក្លាក | អាមេរិក | ភ្នាក់ងារសេ.អ៊ី.អា | កោះវៃ | ២១-៤-៧៨ | ? |
| ៥៧ | ជុនដរ សាន់ យូហ៊ើក | អង់គ្លេស | ? | ? | ២-១១-៧៨ | ? |
| ៥៨ | រ៉ូណាល់ គីសឌីន | អូស្ត្រាលី | ភ្នាក់ងារសេ.អ៊ី.អា | ? | ២-១១-៧៨ | ? |
| ៥៩ | ដេវិត លយ ស្កុត | អូស្ត្រាលី | ភ្នាក់ងារសេ.អ៊ី.អា | ? | ២-១១-៧៨ | ? |
| ៦០ | គែរី ហ្សកហេមិល | នូវែលហ្សេឡង់ | ភ្នាក់ងារសេ.អ៊ី.អា | ? | ១៣-១០-៧៨ | ? |
| ៦១ | សួម សំប៊ិន | សៀម | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៦២ | សាម ឡួយ | សៀម | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៦៣ | ខាំ ស៊ីរៈដាន់ | សៀម | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៦៤ | ប្រសើត លបកើត | សៀម | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |

**(នៅមានត)**

# ឯកសាររូបថត

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងតម្កល់និងរក្សាទុកនូវឯកសាររបបខ្មែរក្រហមសម្រាប់បម្រើការស្រាវជ្រាវជាប្រវត្តិសាស្ត្រ ។ ឯកសារទាំងនេះរួមមានជាប្រវត្តិអ្នកទោសសារទូរលេខ សៀវភៅកំណត់ហេតុ ញត្តិប្រជាជន ចម្លើយសារភាព ទីតាំងពិឃាត ទីតាំងគុក រណ្តៅសាកសពជនរងគ្រោះនិងមន្ទីរឃុំឃាំងដែលខ្មែរក្រហមយកប្រើប្រាស់សម្រាប់ឃុំឃាំងនិងសួរចម្លើយអ្នកទោសមុននឹងយកទៅសម្លាប់ ។

បណ្តាឯកសារទាំងនេះគឺអង្គហេតុបង្ហាញឲ្យឃើញនូវសកម្មភាពនានាដែលរបបខ្មែរក្រហមបានធ្វើមកលើប្រជាជនខ្មែរក៏ដូចជាកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលខ្មែរក្រហមចោទថាបាន«ក្បត់អង្គការ» ។ ឯកសារមានច្រើនប្រភេទ ដូចជាឯកសារជាក្រដាស សៀវភៅ កាសែ្សត រូបថត និងផែនទីជាដើម ។

ក្នុងចំណោមប្រភេទឯកសារទាំងនេះ ឯកសាររូបថតគឺធ្វើជាឯកសារប្រភេទជាក់ស្តែងមួយដែលអាចបង្ហាញច្បាស់នូវរូបភាពនៃការប្រព្រឹត្តអំពើឧក្រិដ្ឋរបស់ខ្មែរក្រហមមកលើប្រជា-ជនកម្ពុជាពីឆ្នាំ១៩៧៥-១៩៧៩ ។ ខ្មែរក្រហមបានចាប់ប្រជា-ជនឃុំឃាំងនិងធ្វើទារុណកម្មយ៉ាងឃោរឃៅ ហើយបង្ខំអ្នកទោសឲ្យសារភាពអំពីទោសកំហុសខ្លួនដែលខ្លួនមិនបានប្រព្រឹត្ត ។ បន្ទាប់ពីបានចម្លើយ អ្នកទោសត្រូវយកទៅកម្ទេច ។ ប៉ុន្តែជនរងគ្រោះដែលបាត់បង់ជីវិតមិនមែនបណ្តាលមកពីការធ្វើទារុណកម្មសុទ្ធសាធទេ ខ្លះស្លាប់ដោយអត់អាហារ ជំងឺ និងធ្វើការបាក់កម្លាំង ។

ឯកសារជារូបថតដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំទៅតាមសកម្មភាពនិងសម័យកាលខុសៗគ្នា សរុបទាំងអស់មានចំនួន៩៨២៧សន្លឹក ។ រូបថតទាំងអស់នេះត្រូវបានថែរក្សាទុកក្នុងអាល់ប៊ុមចំនួន៣០ និងមានចុះបញ្ជីស្ថិតិ ។

ក្នុងចំណោមរូបថតទាំង៩៨២៧សន្លឹកនេះ មានរូបថតអ្នកទោស២៨៧៤សន្លឹកដាក់នៅក្នុងអាល់ប៊ុមលេខ៣ដល់លេខ១១ និងអាល់ប៊ុមលេខ២៨និងលេខ២៩ ។

តាមរយៈរូបថតបង្ហាញឲ្យឃើញថា ឯកសាររូបថតអ្នកទោសមួយសន្លឹកគឺជាអ្នកទោសម្នាក់ៗដែលខ្មែរក្រហមបានចាប់យកមកដាក់ឃុំឃាំង ។ អ្នកទោសដែលជាប់គុកនៅទួលស្លែងគឺជាជនរងគ្រោះខ្មែរក្រហមចាប់មកពីកន្លែងផ្សេងៗគ្នា ។ អ្នកទោសទាំងអស់ត្រូវតែចុះឈ្មោះក្នុងបញ្ជីថ្ងៃខែឆ្នាំចូល វាស់កម្ពស់វាស់ទំហំខ្លួន ពិនិត្យកិនភាគនិងស្លាកស្នាម ។ ក្រោយពេលចុះបញ្ជីនិងពិនិត្យរួចរាល់ហើយ កងសន្តិសុខបានបណ្តើរអ្នកទោសទៅថតរូបទុកជាឯកសារគ្រប់ៗគ្នា ។

មុនពេលថតរូប អ្នកទោសត្រូវរៀបចំឲ្យពាក់ផ្លាកលេខផ្លាកឈ្មោះ និង ចុះកាលបរិច្ឆេទចូលគុក រួចហើយខ្ទាស់ជាមួយកអាវឬខ្សែអាវ ។ ចំពោះអ្នកទោសដែលគ្មានពាក់អាវ កម្មាភិបាលខ្មែរក្រហមបានយកក្រមាឲ្យរុំខ្លួន រួចយកផ្លាកឈ្មោះផ្លាកលេខសម្គាល់ ខ្ទាស់ជាប់នឹងក្រមា ។ អ្នកទោសខ្លះទៀត ដែលគ្មានអាវឬក្រមាត្រូវខ្មែរក្រហមខ្ទាស់ផ្លាកលេខជាប់នឹងសាច់ទ្រូងតែម្តង ។ ក្នុងការថតរូប អ្នកទោសខ្លះត្រូវតម្រូវឲ្យឈរ ប៉ុន្តែភាគច្រើនថតអង្គុយពាក់កណ្តាលខ្លួន ទាំងដៃជាប់ចំណងស្លាបសេក ។ អ្នកទោសនៅក្នុងរបបខ្មែរក្រហមមានប្រុស មានស្រី ចាស់ក្មេង និងជនបរទេស ។ រូបថតអ្នកទោសស្ត្រីមួយចំនួនមានថតជាប់ជាមួយកូនតូច ដោយហេតុថា ពេលចាប់ខ្លួន ជនរងគ្រោះខ្លះបាននាំកូនមកជាមួយ ហើយខ្លះចាប់ទាំងគ្រួសារមានឪពុកម្តាយកូននិងជីដូន ។

សភាពអ្នកទោសក្នុងរូបថតនីមួយៗមានលក្ខណៈខុសគ្នា ។ រូបថតអ្នកទោសខ្លះមានទឹកមុខញញឹមស្រស់ស្រាយ ហាក់ដូចជាពុំដឹងថាខ្លួនត្រូវចាប់មកនេះដើម្បីឃុំឃាំងនិងធ្វើទារុណកម្មសួរចម្លើយនៅពេលបន្តិចទៀតឡើយ ពីព្រោះថា ពេលចាប់ខ្លួនម្តងៗខ្មែរក្រហមតែងតែប្រើពាក្យថា អង្គការស្នើឲ្យទៅរៀនសូត្រ ឬទៅរស់នៅភូមិថ្មី ។ អ្នកទោសដែលមានសភាពបែបនេះ ពេលចូលភ្លាមក៏ត្រូវចាប់ថតរូបភ្លាមតែម្តង ដោយគ្រាន់តែពាក់ផ្លាកលេខប៉ុណ្ណោះ ខ្លះគ្មានទាំងពាក់ផ្លាកលេខផង ។ អ្នកទោសដែលថត

ដោយគ្មានផ្ទាកលេខ ភាគច្រើនជាកុមារ ។

សភាពរូបថតអ្នកទោសមួយចំនួនទៀតបានបង្ហាញថា ត្រូវបានក្រុមអ្នកសួរចម្លើយឬកងសន្តិសុខធ្វើទារុណកម្មវាយដំបែកមុខ ហើមភ្នែក ហើមមាត់ មុនពេលនាំយកមកដល់កន្លែងថតរូប ។

សភាពអ្នកទោសខ្លះមានរូបរាងកាយស្គាំងស្គម ស្បែកដណ្តប់ឆ្អឹង ឃើញតែប្រឡង់ភ្នែក បបូរមាត់បិទមិនជិត មើលឃើញធ្មេញសស្លាញ ដោយសារទទួលទានអាហារមិនគ្រប់គ្រាន់ ។

ការធ្វើទារុណកម្មមានរូបភាពប្លែកៗដែលអ្នកទោសគ្រប់រូបបានទទួលនៅក្នុងគុកទួលស្លែង ដូចជាការបង្អត់អាហារ ការវាយដំគ្រប់ប្រភេទ ឆក់ខ្សែភ្លើង ដកក្រចក រួចចាក់អាល់កុលចងក្បាលនឹងថង់កៅស៊ូផ្ទប់ខ្យល់ដកដង្ហើម និងជ្រមុជក្បាលអ្នកទោសទៅក្នុងពាងទឹក ។ អំពើទាំងនេះធ្វើឡើងដើម្បីជម្រិតយកចម្លើយ ។ ក្រោយពីទទួលទារុណកម្ម អ្នកទោសម្នាក់ៗត្រូវកងសន្តិសុខចងបណ្តើរមកដាក់ក្នុងបន្ទប់តូចចង្អៀតល្មមតែខ្លួនមួយរូបដាក់ខ្នោះជើងបន្ថែមទៀត ។

អ្នកទោសមួយចំនួនដែលមិនអាចទ្រាំទ្រការធ្វើទារុណកម្មក៏បានសម្រេចចិត្តធ្វើអត្តឃាតខ្លួនឯង ដូចករណីរូបថតអ្នកទោសឈ្មោះ កង ជាដើម ។ អ្នកទោសខ្លះត្រូវបានធ្វើទារុណកម្មរហូតដល់ស្លាប់ទាំងដៃជើងជាប់ខ្នោះ ។ អ្នកទោសស្ទើរតែទាំងអស់បានបន្សល់ទុកតែរូបថតប៉ុណ្ណោះ ឯរូបរាងកាយស្លាប់បាត់ទៅហើយ ដូចជាអ្នកទោសឈ្មោះ ហួត សម្បត្តិ ជាអតីតមន្ត្រីការបរទេសម្នាក់កាលពីសង្គមចាស់ និងជាទូតប្រចាំនៅប្រទេសរូម៉ានី ។ ជា សាន ឯកអគ្គរដ្ឋទូតប្រចាំនៅប្រទេសសូវៀត, ឈឹម សំណាង ជាតំណាងរាស្ត្រខេត្តតាកែវ, អ៊ីស៊ុប គន្ធី ឯកអគ្គរដ្ឋទូតប្រចាំនៅប្រទេសស៊ុយអែដ និង ម៉ាន់ សេង អតីតអ្នកទោសនៅគុកក្រាំងតាចាន់ ។ មានតែអ្នកទោសមួយចំនួនតូចដែលនៅមានជីវិតរស់នៅរហូតមកដល់សព្វថ្ងៃ ដូចជាអតីតអ្នកទោសនៅគុកទួលស្លែង គុកភូមិបុស្សី គុកតាម៉ន និងគុកក្រាំងតាចាន់ ។ អតីតអ្នកទោសទាំងនេះ គឺជាសាក្សីដែលបានអធិប្បាយរឿងរ៉ាវពិតដែលខ្លួនធ្លាប់បានឃើញនិងជួបប្រទះនៅក្នុងរបបខ្មែរក្រហម ។

អ្នកទោសដែលនៅរស់រានមានជីវិតគឺជាឯកសាររស់ដែលបញ្ជាក់នូវការពិត ចំពោះរាល់សកម្មភាពទាំងឡាយដែលពួកសន្តិសុខខ្មែរក្រហមបានប្រព្រឹត្តទៅលើអ្នកទោស ។

អ្នកទោសដែលបានរួចផុតពីសេចក្តីស្លាប់រួមមានខ្លះៗដូចជា÷

◆ អ៊ឹង បុិច អតីតអ្នកទោសទួលស្លែងដែលបានរស់រានមានជីវិតក្នុងចំណោមអ្នកទោស១៨នាក់ក្នុងសម័យខ្មែរក្រហម ក្រោយឆ្នាំ១៩៧៩ អ៊ឹង បុិច ធ្វើជាមន្ត្រីទទួលការងារឯកសារនៅសារមន្ទីរទួលស្លែង ។

◆ ហេង ណាត ជាជាងគំនូរដែលបានគូសរូប ប៉ុល ពត ក្នុងរយៈពេលដែលគាត់ជាប់នៅគុកទួលស្លែង ហើយបានរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ។

◆ អៀង សូភាង និង កូនស្រី ជាអតីតអ្នកទោសនៅគុកតាម៉ន ក្នុងស្រុកអង្គជ័យ ខេត្តកំពត នៅមានជីវិតរស់រហូតដល់សព្វថ្ងៃ ។

◆ ម៉ុម ឆុត អតីតអ្នកទោសនៅគុកទន្លេបាទី ក្នុងស្រុកទន្លេបាទី ខេត្តតាកែវ នៅរស់រហូតដល់សព្វថ្ងៃ ។

◆ ទន់ ឡា អតីតអ្នកទោសនៅគុកភូមិបុស្សី ស្រុកព្រៃកប្បាស ខេត្តតាកែវ និងរូបថតឯកសារអ្នកទោស ដែលត្រូវកម្ទេចចោលនៅថ្ងៃ៧ ខែកក្កដា ឆ្នាំ១៩៧៧ ។

ទាំងនេះជាពត៌មាននិងរូបភាពបង្ហាញច្បាស់នូវសកម្មភាពរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋមកលើប្រជាជនខ្មែរ ។

**លឹម គី**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី "ស្វែងរកការពិត"**
ប្រអប់សំបុត្រលេខ ១១១០ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥)(២៣)២១១៨៧៥
ទូរសារលេខៈ (៨៥៥)(២៣)២១០៣៥៨
Email: dccam@bigpond.com.kh
Homepage: http://welcome.to/dccam


17-5-78

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៣៧៣ | អូម ឈុនស្រេង | វិស្វករ | ភ្នំស្រុក | ?? | ២៣-៥-៧៦ | |
| ៣៧៤ | អ៊ុក យន | កម្មករ | កំពង់សោម | ?? | ២៣-៥-៧៦ | |
| ៣៧៥ | ងី ហ៊ាង | ធ្វើថ្នាំពេទ្យ | ព្រះនេត្រព្រះ | ?? | ២៣-៥-៧៦ | |
| ៣៧៦ | ដួ កាន | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៧៧ | ឈឹម ស៊ីត | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៧៨ | ជា ដៃមុនី | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៧៩ | តាន់ គីមស្រេង | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៨០ | ប៉ែន ឌិន | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៨១ | សែម ហែម | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៨២ | សួស សេង | ព្រិន្ទបាលទោ | ?? | ?? | ២៣-៥-៧៦ | |
| ៣៨៣ | សេង សារឿន | ប្រពន្ធទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៨៤ | ម៉ៅ ទូច | ប្រពន្ធទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៨៥ | លឹម ថុន | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៨៦ | ជិន ផល | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៨៧ | ម៉ែន ស៊ីថុន | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៨៨ | ទិត ធឿង | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៨៩ | ម៉ាក់ ដេង | ទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៩០ | អ៊ុម ផាវ | ប្រពន្ធចោរព្រៃ | ?? | ?? | ២៣-៥-៧៦ | |
| ៣៩១ | អ៊ុម វ៉ែន | ប្រពន្ធទាហាន | ?? | ?? | ២៣-៥-៧៦ | |
| ៣៩២ | ពៅ សុខុម | ក្រុមហ៊ុនរិណែល | ព្រែកពោធិ | ?? | ២៣-៥-៧៦ | |
| ៣៩៣ | ថេង ស៊ី | កាកបាទក្រហម | បាត់ដំបង | ?? | ២៣-៥-៧៦ | |
| ៣៩៤ | ងិន សាអ៊ុត | វិស្វករអណ្តូងរ៉ែ | បាត់ដំបង | ?? | ២៣-៥-៧៦ | |
| ៣៩៥ | ឈឹម សុវ៉ាន់ | ប្រជាជន | រោងចក្រកែវ | ?? | ២៣-៥-៧៦ | |
| ៣៩៦ | កង សុខ | ប្រជាជន | ព្រែកក្តាម | ?? | ២៣-៥-៧៦ | |
| ៣៩៧ | ថោង រើន | ប្រជាជន | កាស៊ីណូភ្នំពេញ | ?? | ២៣-៥-៧៦ | |
| ៣៩៨ | អ៊ូ សៅ | ប្រជាជន | ផ្សារកាប់គោ | ?? | ២៣-៥-៧៦ | |
| ៣៩៩ | ប្រាក់ គីមសាន | ប្រជាជន | មុខកំពូល | ?? | ២៣-៥-៧៦ | |
| ៤០០ | ទា ចាន់ថា | ប្រជាជន | បាត់ដំបង | ?? | ២៣-៥-៧៦ | |
| ៤០១ | ជា ឆម | ប្រជាជន | ព្រែកពោធិ | ?? | ២៣-៥-៧៦ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤០២ | ហែម ណែម ហៅ សន | កងរយនិរតី | កំពង់សោម | ?? | ២៣-៥-៧៦ | |
| ៤០៣ | ឡោ ការណា | សក្តិ២ | តំបន់២៥ | ?? | ២៣-៥-៧៦ | |
| ៤០៤ | ចិន ញឹប | កម្មករស្រែអំបិល | កំពង់សោម | ?? | ២៣-៥-៧៦ | |
| ៤០៥ | សួន ឡុង | ប្រជាជនចាស់ | តំបន់២៥ | ?? | ២៣-៥-៧៦ | |
| ៤០៦ | ស៊ិត ហែម | ទាហានកាប៉ូរ៉ាល់ | កំពង់សោម | ?? | ២៣-៥-៧៦ | |
| ៤០៧ | ទី ឈាត | កម្មករនេសាទ | កំពង់សោម | ?? | ២៣-៥-៧៦ | ឈឺសាប់ |
| ៤០៨ | ឡេង ឌី ហៅ នី | កងរយ | កងពលខត្តរ | ?? | ២៣-៥-៧៦ | ឈឺស្លាប់ |
| ៤០៩ | ង៉ែត ង៉ែម ហៅ ចឺរីនស | ស្មៀនយន្តហោះ | តំបន់៣៣ | ២៣-៣-៧៦ | ២៣-៥-៧៦ | |
| ៤១០ | កុក លន | ប្រជាជនចាស់ | តំបន់២៥ | ១២-៣-៧៦ | ២៣-៥-៧៦ | |
| ៤១១ | គង់ ទាង | ប្រជាជនថ្មី | តំបន់២២ | ១-៤-៧៦ | ២៣-៥-៧៦ | |
| ៤១២ | ម៉េង សេង | ប្រជាជនចាស់ | តំបន់២៥ | ៥-៣-៧៦ | ២៣-៥-៧៦ | |
| ៤១៣ | ប្រាជ ទន ហៅ ភី (ស្រី) | កម្មករ | អគ្គីសនីផ្សារតូច | ១៣-១១-៧៥ | ២៣-៥-៧៦ | |
| ៤១៤ | គីម សាដូ ហៅ ឡាតា | កម្មករ | រោងចក្រថ្មពិល | ១៨-១២-៧៥ | ២៣-៥-៧៦ | |
| ៤១៥ | ឃី សេង | កម្មករ | ក្រឡឹង ដ-៦ | ៣-៤-៧៦ | ២៣-៥-៧៦ | |
| ៤១៦ | ឡាំ ហុង | កម្មករ | ក្រឡឹង ដ-៦ | ២៤-៤-៧៦ | ២៣-៥-៧៦ | |
| ៤១៧ | ពិន ឡៃ | កម្មករ | រោងចក្រទឹកដោះគោ | ២៩-១១-៧៥ | ២៣-៥-៧៦ | |
| ៤១៨ | កែ ណាន | យុទ្ធជន | កងពល៥០២ | ៣-២-៧៦ | ២៣-៥-៧៦ | |
| ៤១៩ | ឃឹម រិន | យុទ្ធជន | កងពល៥០២ | ៣-២-៧៦ | ២៣-៥-៧៦ | |
| ៤២០ | ចែម ស៊ីផាត់ (ស្រី) | អគ្គការអ៊ុយនីសេហ្វ | បាត់ដំបង | ៦-៣-៧៦ | ២៣-៥-៧៦ | |
| ៤២១ | ឃិន ស៊ុម | ត្រាវ៉ូបើកឡាន | តំបន់២២ | ២៤-២-៧៦ | ២៣-៥-៧៦ | |
| ៤២២ | រត់ គត់ | ពេទ្យ | តំបន់២២ | ៣០-១១-៧៥ | ២៣-៥-៧៦ | |
| ៤២៣ | ទិព ម៉ម | វេជ្ជបណ្ឌិត | តំបន់២២ | ១៤-១២-៧៥ | ២៣-៥-៧៦ | |
| ៤២៤ | ហ៊ុល ហុង | វិស្វករ | បាត់ដំបង | ២១-១-៧៦ | ២៣-៥-៧៦ | |
| ៤២៥ | ហេ ប៊ុនឡាក់ | គ្រូបង្រៀន | តំបន់២៥ | ៤-៣-៧៦ | ២៣-៥-៧៦ | |
| ៤២៦ | លឹម ផ្លូន | វិចិត្រសិល្បៈ | បាត់ដំបង | ១២-១-៧៦ | ២៣-៥-៧៦ | |
| ៤២៧ | លួម សំប៉ែន | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ជនជាតិសៀម |
| ៤២៨ | សាម ឡួយ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ជនជាតិសៀម |
| ៤២៩ | ខាំ ស៊ីរៈផាន់ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ជនជាតិសៀម |
| ៤៣០ | ប្រសើត លបកើត | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ជនជាតិសៀម |
| ៤៣១ | សំ ស៊ីអន ភាវៀង | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ជនជាតិសៀម |
| ៤៣២ | ដេង ចាន់សេន | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ជនជាតិសៀម |
| ៤៣៣ | ម៉ាណោត ដុយចែមសៃ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ជនជាតិសៀម |
| ៤៣៤ | ចារូន ណូក្រសែ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ជនជាតិសៀម |
| ៤៣៥ | ចារៀង ណូក្រសែ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ | ជនជាតិសៀម |

**(នៅមានត)**

# ក្បួនទ័ពព្រៃខ្មែរក្រហម

(ឯកសារលេខ D ២១៩៣១)

## ១) របៀបទាហានក្នុងក្រុម

របៀបទាហានក្នុងក្រុមមាន÷

១) មេកង ២) មេក្រុម ៣) មេក្រុមរង ៤) មេពួកកាន់កាំភ្លើងដៃ ៥) កាន់កាំភ្លើងយន្ត ៦) ប្រកបង់ទៅក្នុងកាំភ្លើង ៧) ប្រកគ្រាប់ទៅក្នុងបង់ ៨) ស្ពាយគ្រាប់ ៩) មេពួករងកាន់កាំភ្លើងដៃ មានគ្រាប់បែកមួយ ១០) កាំភ្លើងដៃ...និងគ្រាប់បែកមួយ ១១) កាំភ្លើងដៃ...គ្រាប់បែកមួយ ១២) នាំការបំភ្លឺផ្លូវ...កាំភ្លើងដៃ...គ្រាប់បែកមួយ ១៣) កាំភ្លើងដៃ...គ្រាប់បែកមួយ ១៤) អ្នកបោលគ្រាប់បែក ១៥) នាំសំបុត្រ មានកាំភ្លើងវែងឬខ្លីមួយដើម ។

## ២) សេចក្ដីអធិប្បាយប្រមូលក្រុម

មេក្រុម ឬមេក្រុមរង គោងឈរនៅមួយកន្លែង ហើយលើកដៃឆ្វេងឡើងលើជាសញ្ញាស្រែកថា ប្រមូលក្រុម ពេលនោះពួកទី១ រត់ទៅឈរនៅពីក្រោយមេក្រុមឬមេក្រុមកងរងចម្ងាយ ៦ជំហាន ពួកទី២ឬទី៣ឈរនៅខាងស្ដាំបន្តគ្នា ។

ឯទាហានត្រូវរត់ដោយប្រញាប់មកឈរនៅពីក្រោយមេពួកចម្ងាយ៦ជំហាន ។ ទាហានឈរខាងមុខនៅប្រុងលើកដៃឆ្វេងឡើងលើទាហាននៅខាងក្រោយ ត្រូវលើកដៃឆ្វេងសន្ធឹងបោះទៅមុខ ចុងម្រាមដៃទល់ស្មាឆ្វេងបន្តគ្នា មើលតម្រង់ឲ្យត្រង់ជួរ ។

ចំណែកពួកកងត្រឡប់មកខាងមុខទាហានវិញ សម្លឹងមើលទាហានឈរឲ្យត្រង់ជួរ បើកាលណាត្រង់ហើយ ទើបស្រែកឲ្យទាហានបិទ ទាហានទាំងអស់ត្រូវដាក់ដៃចុះព្រមគ្នា រួចត្រូវជម្រាបមេក្រុមឬមេកងរងថាគ្រប់ចំនួនឬខ្វះតាមហេតុតទៅ ។

## ៣) ក្បាច់ទាហានត្រូវហាត់

១) ប្រមូលក្រុម ២) ប្រមូលពួកជាមួយជួរ ៣) លើកដៃតម្រង់ជួរ៤) បិទ ៥) ស្ដាំបែរ ៦) ឆ្វេងបែរ ៧) ត្រឡប់មុខទៅក្រោយបែរ ៨) សម្រាក ៩) ប្រុង ១០) លីអាវុធ ១១) ដាក់អាវុធ ១២) វន្ទាអាវុធ ១៣) វន្ទាបិទ ១៤) ទៅមុខដើរ ១៥) ក្រុមឈប់ ១៦) ស្ពាយអាវុធ ១៧) អាវុធចុងជើង ១៨) កេសា (ឆ្វេង-ស្ដាំ) ។

## ៤) សេចក្ដីអធិប្បាយគ្មានអាវុធ

ត្រូវប្រឹងខ្លួនឲ្យរឹង រួចទាញជើងឆ្វេងមកផ្ទឹមនឹងជើងស្ដាំ ឯកែងជើងទល់គ្នា ចុងជើងកន្ធែក ក្បាលងើប ដងខ្លួនប្រឹងឲ្យត្រង់ ដៃទាំងពីរសំយុងចុះអែបខ្លួន ហើយម្រាមដៃបិទឲ្យជិតគ្នាសម្រប តាមថ្នេរខោ ។

## ៥) ឆ្វេងបែរ

ត្រូវប្រុងរួចទើបបង្វិលទាំងពីរព្រមនៅនឹងដងខ្លួនទៅឆ្វេងៈ

១) ជើងឆ្វេងបង្វិលនឹងកែងជើង

២) ជើងស្ដាំបង្វិលនឹងចុងជើង កែងជើងចំអើតបន្តិច ហើយទាញជើងស្ដាំមកផ្ទឹមនឹងជើងឆ្វេង ។

## ៦) ស្ដាំបែរ

ត្រូវប្រុងរួចហើយ ទើបបង្វិលជើងទាំងពីរព្រមនូវនឹងដងខ្លួនទៅខាងស្ដាំគឺ ១) ជើងស្ដាំបង្វិលនឹងកែង ២) ជើងឆ្វេងបង្វិលនឹងចុងជើង រួចទើបយកជើងឆ្វេងទៅផ្ទឹមនឹងជើងស្ដាំវិញ ។

## ៧) ត្រឡប់ទៅក្រោយ

ប្រុងរួចទាញជើងស្ដាំបោះទៅក្រោយ ចម្ងាយឃ្លាតពីជើងឆ្វេង០,១៥ម៉ែត្រ ឯជើងឆ្វេងនោះ ត្រូវបង្វិលមកឲ្យចំទិស រួចបង្វិលជើងទាំងពីរព្រមនូវដងខ្លួនទៅក្រោយ រួចហើយទាញជើងស្ដាំមកផ្ទឹមនឹងជើងឆ្វេង ។

## ៨) សម្រាក

ប្រុងរួចបោះជើងទៅមុខចម្ងាយ០,១៥ម៉ែត្រ ឯដៃឆ្វេងត្រូវលើកឡើងដាក់លើខ្សែក្រវ៉ាត់នៅចំខាងមុខ ដៃស្ដាំដាក់សំយុងចុះតាមថ្នេរខោ ។

## ៩) របៀបប្រុងមានកាន់អាវុធ

របៀបប្រុងគឺដូចគ្នានឹងប្រុងគ្មានអាវុធ តែដៃស្តាំដែលកាន់អាវុធនោះត្រូវសំយុងឲ្យត្រង់ទៅក្រោម មេដៃនិងម្រាមដៃពីរចាប់អាវុធសម្របគ្នាតាមស្នូក ឯចុងបាតស៊័យកាំភ្លើងខាងមុខ ត្រូវដាក់ឲ្យនៅចំហៀងនឹងជើងស្តាំ ។

បើកាលណាត្រូវប្រមូលពួក គោងលើកអាវុធត្រឹមចង្កេះ ហើយលើកដៃតម្រង់ជួរដូចរបៀបដែលបានអធិប្បាយមុនមក ហើយបើមេស្រែកឲ្យបិទ ត្រូវដាក់ទៅវិញឲ្យត្រឹមត្រូវតាមរបៀបដើម ។

## ១០) អធិប្បាយអំពីលីអាវុធ

របៀបលីអាវុធមានបីថ្នាក់ៈ ១) ត្រូវប្រុង រួចដៃស្តាំកាន់អាវុធផ្កាប់ ហើយលើកបង្វិលផ្ងារឡើងលើ រួចលើកដៃឆ្វេងមកទទួលចាប់អាវុធនៅត្រឹមក្លៀក កែងដៃឆ្វេងត្រូវបិទឲ្យជិតដើមទ្រូង ទើបយកដៃស្តាំទៅចាប់ស៊័យកាំភ្លើង ២) ដៃស្តាំលើកកាំភ្លើងឡើងដាក់លើស្មា ដៃឆ្វេងសម្រូតមកលើបាតស៊័យកាំភ្លើង ឯដៃស្តាំត្រូវឲ្យជិតខ្លួន អាវុធឲ្យចំទិសកែងដៃមិនឲ្យហួសខ្នងនិង ៣) បោះដៃឆ្វេងទៅក្រោយអែបតាមជងខ្លួនឲ្យត្រង់វិញ ។

## ១១) វិធីដាក់អាវុធ

របៀបដាក់អាវុធមានបីថ្នាក់ៈ ទី១) ដៃស្តាំចាប់បាតស៊័យកាំភ្លើងសម្រូតចុះមកដាក់ត្រឹមចង្កេះ ឯដៃឆ្វេងត្រូវលើកមកលើចាប់អាវុធនៅត្រឹមក្លៀក ហើយកែងដៃឆ្វេងត្រូវបិទឲ្យជិតដើម



ទ្រូង ។ ទី២) យកដៃស្តាំទៅចាប់អាវុធនៅលើដៃឆ្វេង រួចទើបបង្អិលផ្កាប់ដាក់មកព្រមគ្នានៅត្រឹមចង្កេះ ។ ទី៣) ដៃឆ្វេងបោះទៅវិញអែបដងខ្លួនស្របតាមថ្នេរខោ ឯដៃស្តាំត្រូវដាក់អាវុធចុះតាមដើមគឺបាតស្ប៉ុយខាងមុខអែបកូនជើងស្តាំ ។

## ១២) វិធីស្ពាយអាវុធ

របៀបស្ពាយអាវុធមាន៤ថ្នាក់គឺ ទី១ ដៃស្តាំលើកអាវុធបញ្ឈរុញទៅមុខលើកដៃឆ្វេងឡើងចាប់អាវុធនៅក្រោមដៃស្តាំប្រមាណឲ្យចំពាក់កណ្តាលទ្រូង ទី២ ដៃឆ្វេងកាន់នៅដងដែល ហើយយកដៃស្តាំ ចាប់កាន់ខ្សែអាវុធទាញឲ្យតឹង និងទី៣) ដៃស្តាំទាញខ្សែអាវុធកញ្ឆក់ទៅចំហៀង ដាក់លើស្មាស្តាំ ដៃឆ្វេងបោះចុះទៅចំហៀងខ្លួនវិញ ឯដៃស្តាំត្រូវសម្រូតចុះដាក់នៅខ្សែស្ប៉ុយកាំភ្លើង ។



## ១៣) អាវុធនៅចុងជើង

របៀបនេះមានបួនគឺៈ ទី១) លើកដៃស្តាំឡើងចាប់ខ្សែកាំភ្លើងនៅត្រឹមក្លៀក ទី២) ដៃស្តាំត្រូវកញ្ឆក់ខ្សែព្រមនូវអាវុធបង្អិលមកខាងមុខ ហើយយកដៃឆ្វេងមកទទួលចាប់អាវុធឲ្យចំពាក់កណ្តាលទ្រូង ទី៣) ដៃឆ្វេងនៅចាប់អាវុធដងដែល ហើយលើកដៃស្តាំមកចាប់អាវុធនៅលើដៃឆ្វេងទាញមកដាក់ត្រឹមចង្កេះ និងទី៤) ដៃឆ្វេងដាក់នៅអែបខ្លួនស្របតាមថ្នេរខោ ដៃស្តាំដាក់អាវុធចុះតាមដើម ។

## ១៤) គ្រួតអាវុធ

វិធីគ្រួតអាវុធមាន ៥ខ÷

១) បោះជើងឆ្វេងទៅមុខ លើកអាវុធដាក់ត្រឹមចង្កេះវាត់ចុងទៅមុខ ២) ដៃស្តាំចាប់កាន់ទាញកន្ទះម៉ូប៊ីលមកក្រោយ ។ ៣) ទាញជើងស្តាំមកផ្ទឹងនឹងជើងឆ្វេង ឯកាំភ្លើងត្រូវបង្អិលយកបាតស្ប៉ុយទៅមុខ ហើយយកចុងកាណុងទៅក្រោយដាក់លើស្មាឆ្វេង ៤) ជើងស្តាំបោះទៅក្រោយវិញ បង្អិលយកបាតស្ប៉ុយទៅក្រោយ យកដៃស្តាំបិទកន្ទាស់ម៉ូប៊ីលតាមដើម អាវុធដាក់ត្រឹមចង្កេះវាត់ចុងទៅមុខ និង ៥) ដៃឆ្វេងបោះទៅចំហៀងអែបតាមដងខ្លួនស្របតាមថ្នេរខោដៃស្តាំដាក់អាវុធចុះតាមដើម ។

## ១៥) វិធីគំនាប់កេសាវេលាដើរ

របៀបនេះមានពីរថ្នាក់គឺៈ ១) អាវុធស្ពាយធម្មតា តែទៅដាក់អ្នកធំ ត្រូវច្បូតដៃនៅបាតស្ប៉ុយ ប្រឹងខ្លួនឲ្យរឹង ២) ក្បាលងើយឡើងបែរទៅរកអ្នកធំ ឆ្វេងឬស្តាំ លុះត្រាដើរផុតអ្នកធំ៦ជំហានទើបបែរទៅតាមដើមវិញ ហើយដើរតាមធម្មតា បើគ្មានអាវុធទេត្រូវលើកដៃគំនាប់ ហើយបែរមុខទៅឆ្វេងឬស្តាំដែលអ្នកធំនៅ លុះត្រាតែផុត៦ជំហានទើបដើរទៅតាមដើម ដាក់ដៃចុះវិញ បើមានរបស់កាន់នៅដៃឆ្វេង ត្រូវលើកដៃស្តាំគំនាប់ដូចគ្នា ឬមានកាន់របស់ដៃទាំងសងខាង ត្រូវបែរក្បាលបានហើយ ។

## ១៦) គំនាប់វេលាពាក់មួក

របៀបគំនាប់ពាក់មួកមាន២ថ្នាក់គឺ ១) ប្រុងលើកដៃស្តាំបោះទៅខាងឲ្យត្រង់ម្រាមបិទឲ្យជិតគ្នា ហើយបត់ផ្កាប់ដៃយកចុងដៃដាក់ទល់លើចិញ្ចើមកន្ទុយភ្នែក កែងដៃលើកដាក់លើ

ស្មា ។ ២) បោះដៃសន្ធឹងទៅចំខាងឲ្យត្រង់ដាក់ចុះតាមដើម ។

## ១៧) ប្រើអាវុធ

ទាហានត្រូវចេះប្រើអាវុធឲ្យច្បាស់លាស់ កុំបាញ់ផ្ដេសផ្ដាសនាំឲ្យខាតគ្រាប់រំសេវនិងនាំឲ្យខូចខាតដល់ជាតិ ឬអន្តរាយដល់ខ្លួន ។

១) មុននឹងចេញទៅតស៊ូ មេត្រូវប្រមូលទាហាន ត្រួតមើលអាវុធឲ្យសព្វគ្រប់ទាំងអស់ ក្រែងអាវុធនោះមិនស្អាត មានច្រែះចាប់ ឬមានរបស់អ្វីចុកកាណុង ម្យ៉ាងទៀតក្រែងមានគ្រាប់ជាប់នៅខាងក្នុងកាណុង ដល់យើងស្ពាយឬដាក់រាលកៃត្រូវគ្នាឯងស្លាប់ ២) កាលបើខ្វះខាត ត្រូវជូនទៅជាងកែកាំភ្លើងឲ្យជួសជុលឡើងវិញ ឯគ្រាប់ទៀតក្ដី បើខ្វះខាតត្រូវបើកបន្ថែមឲ្យគ្រប់ចំនួន វេលាត្រឡប់មកពីតស៊ូវិញ ត្រូវប្រមូលត្រួតមើលម្ដងទៀត ឲ្យទាហានដុះលាងឲ្យស្អាតកុំឲ្យច្រែះចាប់ និង ៣) មេត្រូវប្រាប់ទាហានឲ្យស្គាល់ថា អាវុធនេះត្រូវប្រើយ៉ាងនេះ ចម្ងាយប៉ុណ្ណេះត្រូវ ចេះតម្រង់និងកាត់រយះ ។

## ១៨) ចម្ងាយអាវុធ

១) ចម្ងាយ៥០០ម៉ែត្រដល់៧០០ម៉ែត្រ ត្រូវបាញ់ឈរ ។ ២) ចម្ងាយ៣០០ម៉ែត្រដល់៥០០ម៉ែត្រ ត្រូវបាញ់អង្គុយ ។ ៣) ចម្ងាយ៥០ម៉ែត្រដល់២០០ម៉ែត្រត្រូវបាញ់ដេក ។ ៤) ចម្ងាយ ២០ម៉ែត្រដល់៣០ម៉ែត្រ ត្រូវចោលគ្រាប់បែក ។ ៥) ចម្ងាយ ៥ម៉ែត្រដល់៧ម៉ែត្រត្រូវស៊ុះចូលចាក់ ។

## ១៩) របៀបបាញ់

បើបាញ់មនុស្សឈរត្រូវលើកអាវុធទល់ស្មាស្ដាំ ហើយផាកក្បាលបន្តិចមកជិតនឹងស្នូកកាំភ្លើង បិទភ្នែកឆ្វេងបើកភ្នែកស្ដាំតម្រង់ពីជញ្ជាំងម៉ែត្រទៅគោលកាំភ្លើង ឯគោលនោះត្រូវឲ្យចំទៅមនុស្សឈរ ។ បើបាញ់មនុស្សអង្គុយត្រូវតម្រង់ឲ្យចំជង្គង់បត់ បើបាញ់មនុស្សដេកត្រូវតម្រង់ឲ្យចំដើម-ក ។

## ២០) របៀបបាញ់ឈរ

១) បោះជើងឆ្វេងទៅមុខ កន្ត្រាក់កាំភ្លើងដាក់នៅចង្កេះ វាត់ចុងទៅមុខ គូទអង្គុយលើកែងជើងស្ដាំ ២) ស្នូកកាំភ្លើងទល់ស្មាស្ដាំ កែងដៃលើកស្មើស្មា ខ្លួនទោរទៅមុខម្រាមដៃលូកដល់សន្ទាក់ដៃទី២ ។ ៣) បិទភ្នែកឆ្វេងបើកភ្នែកស្ដាំ មើលពីជញ្ជាំងម៉ែត្រទៅគោលកាំភ្លើងរបស់អ្វីដែលយើងតម្រង់ទាញមួយថ្នាក់យកមកទុកតម្រង់ថ្មីទៀត អត់ដង្ហើមបាញ់ទៅ ។

## ២១) របៀបបាញ់អង្គុយ

១) បោះជើងឆ្វេងទៅមុខ កន្ត្រាក់កាំភ្លើងដាក់នៅចង្កេះ វាត់ចុងទៅមុខ គូទអង្គុយលើកែងជើងស្ដាំ ។

២) កាច់កៃ ប្រកគ្រាប់ លើកស្នូកកាំភ្លើងទល់ស្មា ស្ដាំកែងដៃលើកស្មើស្មា ខ្លួនទោរទៅមុខ កែងដៃឆ្វេងជាប់នឹងក្បាលជង្គង់ឆ្វេង រួចយកម្រាមដៃលូកដល់សន្ទាក់ដៃ ។

៣) ភ្នែកឆ្វេងបិទ បើកភ្នែកស្ដាំមើលពីជញ្ជាំងម៉ែត្រទៅគោលកាំភ្លើងរបស់អ្វីដែលយើងតម្រង់ ហើយទាញកៃមួយថ្នាក់មកទុកតម្រង់ថ្មីទៀត អត់ដង្ហើមបាញ់ទៅ ។

## ២២) របៀបបាញ់ដេក

១) កន្ត្រាក់កាំភ្លើងត្រឹមចង្កេះ ក្បាលជង្គង់ឆ្វេងដៃឆ្វេងច្រត់ដី ខ្លួនក្រាបទៅមុខ ជើងទាំងពីរបោះទៅក្រោយ ។

២) ដៃទាំងពីរកាច់កៃប្រកគ្រាប់ ស្នូកកាំភ្លើងទល់ស្មាស្ដាំ ម្រាមដៃលូកដល់សន្ទាក់ដៃទាំងពីរកាច់កៃ ។

៣) បិទភ្នែកឆ្វេងបើកភ្នែកស្ដាំគោលពីជញ្ជាំងម៉ែត្រទៅគោលកាំភ្លើងរបស់អ្វីមួយដែលយើងតម្រង់ទាញកៃមួយថ្នាក់យកមកទុកតម្រង់ថ្មីទៀត អត់ដង្ហើមបាញ់ទៅ ។

## ២៣) វិធីចាក់នឹងជំពុះទុង

១) ទៅមុខ → ជិត / ឆ្ងាយ ចាក់(៥)ចាក់ → ជិត / ឆ្ងាយ រង → លើ / ឆ្វេង / ស្ដាំ

២) ត្រឡប់មុខទៅក្រោយ៦) ...(អានមិនរួច) ទៅមុខចាក់ ។

៣) → ស្ដាំ / ឆ្វេង បែរ (ចាក់៧) បុកបាតស្មាយ

៤) ចាក់ទៅលើ → ជិត / ឆ្ងាយ ចាក់

**(នៅមានត)**

# កត្តាដែលធ្វើឱ្យសង្គ្រាមប្រជាជនទទួលបានជ័យជម្នះពេញលេញ

សង្គ្រាមប្រជាជនជាសង្គ្រាមរំដោះជាតិនិងរំដោះប្រជាជនតាមមាគ៌ាវណ្ណៈអំពីការជិះជាន់នៃសំណាក់ ចក្រពត្តិ អាណានិគមនិយម សក្តិភូមិនិងនាយទុន ។ សង្គ្រាមប្រជាជនអាចដណ្តើមយកជ័យជម្នះបានត្រូវតែមានចរិតនិងកត្តា៥យ៉ាងគឺ÷

១) ត្រូវមាននយោបាយ គោលនយោបាយត្រឹមត្រូវទាំងយុទ្ធសាស្ត្រ ទាំងយុទ្ធវិធី ត្រូវមានគោលនយោបាយយោធារបស់បក្សត្រឹមត្រូវ ហើយទាំងអស់នេះត្រូវជ្រួតជ្រាប រឹងប៉ឹងហើយបក្សដឹកនាំត្រូវអនុវត្ត ដោយផ្ទាប់ការភ្ជាប់ការភ្ជាប់ស្មុគ្រស្មាញនិងរស់រវើក ។ កត្តាទី១ ជាកត្តាសម្រេច ព្រោះជាកត្តាដើរតួដឹកនាំ បើគ្មានកត្តានេះឬកត្តានោះបំពេញលក្ខណៈសម្បត្តិត្រឹមត្រូវនោះ គឺចាញ់តាំងពីដើមទី ព្រោះសតិអារម្មណ៍នយោបាយនិងស្មារតី ជាកត្តាដើមចមនោះវាមិនច្បាស់មិនដឹងថាជាទៅណាមកណា ច្របូកច្របល់មិត្តជាសត្រូវ ប្រៀបបានជាមនុស្សខ្វាក់ឬស្រវាំងដែលពុំអាចដើរត្រង់ផ្លូវបានឬដើរទៅធ្លាក់ជ្រោះបែកជើងបែកដៃបែកក្បាលក៏មាន ។

២) ត្រូវមានរណសិរ្សសាមគ្គីប្រជាជនទាំងមូល ជាធ្លុងមួយរឹងប៉ឹង ឈរលើបផ្អែកសម្ព័ន្ធភាពកសិករក្រោមការដឹកនាំរបស់បក្ស ។ រណសិរ្សគឺជាកម្លាំងមនុស្ស កម្លាំងប្រជាជន ដែលជាកម្លាំងប្រភពផ្តល់នូវគ្រប់មធ្យោបាយដល់សង្គ្រាមប្រជាជន បើនយោបាយនិងការកសាងរណសិរ្សមិនត្រឹមត្រូវគឺប្រមូលកម្លាំងមនុស្ស កម្លាំងប្រជាជនមិនបានគឺពុំមានន័យពេញលេញជាសង្គ្រាមប្រជាជន ហើយក៏ពុំអាចដណ្តើមយកជ័យជម្នះបានឡើយ ។

៣) ត្រូវប្រើកម្លាំងប្រដាប់អាវុធ ពោលគឺប្រជាជនទាំងមូលត្រូវមានអាវុធជាប់នឹងដៃ ដើម្បីវាយខ្មាំងគ្រប់សមរភូមិ កម្លាំងប្រដាប់អាវុធប្រជាជនកម្ពុជានោះគឺឈ្លបតំបន់ ស្រួច និងសេនាជន ស្រីប្រុសចាស់ក្មេង ខ្វាក់ខ្វែក កំបុតដៃក៏ដោយ ។ នៅសមរភូមិមុខនិងសមរភូមិក្រោយ វាយខ្មាំងនៅគ្រប់ទីកន្លែងដោយប្រើអាវុធបុរាណនិងអាវុធសម្បូរបែបទាល់តែមានកងកម្លាំងប្រដាប់អាវុធប្រជាជននេះ ទើបអាចវាយកម្ទេចខ្មាំងបាន បើគ្មានកងកម្លាំងប្រដាប់អាវុធប្រជាជនគឺមិនគ្រាន់តែវាយខ្មាំងមិនបានទេ ថែមទាំងខ្មាំងកម្ទេចកម្លាំងប្រជាជនទៀតផង ហើយបក្សបដិវត្តន៍ក៏គ្មានន័យអ្វីទាំងអស់ ។

៤) ត្រូវមានតំបន់ក្រោយខ្នងរឹងប៉ឹង តំបន់ខាងក្រោយខ្នងនេះគឺជាមូលដ្ឋានបផ្អែកដែលមានប្រជាជន យោធា រដ្ឋបាល និងមានបក្ស"ប្រជាជនសេនារដ្ឋាបក្ស"រឹងប៉ឹងដើម្បីផ្តល់នូវគ្រប់មធ្យោបាយនិងការណែនាំផ្សេងៗដល់សមរភូមិខាងមុខ ។ បើគ្មានតំបន់ក្រោយខ្នងជាបផ្អែកទេ ក៏គ្មានប្រភពផ្តល់នូវមធ្យោបាយដល់សមរភូមិដែរ គ្មានកន្លែងសម្រាប់បង្ហាត់ហ្វឹកហ្វឺនកងកម្លាំងផង គ្មានមូលដ្ឋានជាទីតាំងក្បាលម៉ាស៊ីនដឹកនាំឲ្យមានលក្ខណៈនឹងនជាបន្ទូរផង បើគ្មានដូច្នេះគឺធ្វើសង្គ្រាមប្រជាជនមិនកើតទេ ។ អាស្រ័យហេតុនេះបានជាត្រូវកសាងនិងស្វែងរកតំបន់ក្រោយខ្នងបផ្អែកតូចធំក្នុងប្រទេសក្រៅប្រទេសជាជំនួយឲ្យបានជាអតិបរមា ដើម្បីជាប្រភពផ្តល់នូវគ្រប់មធ្យោបាយបែបយ៉ាងដល់សមរភូមិខាងមុខនេះជាកត្តាមួយសំខាន់នៃសង្គ្រាមប្រជាជន ។

៥) ត្រូវមានការឧបត្ថម្ភពីបក្សនិងប្រជាជនអន្តរជាតិឲ្យបានអតិបរមាពិសេសបណ្តាប្រទេសសង្គមនិយម ដើម្បីដណ្តើមយកជ័យជម្នះក្នុងសង្គ្រាមប្រជាជន ។ កម្លាំងសំខាន់បំផុតដែលមានលក្ខណៈកំណត់គឺកម្លាំងក្នុងប្រទេស ព្រោះសង្គ្រាមប្រជាជនប្រទេសណាគឺប្រជាជននៅប្រទេសនោះជាអ្នកធ្វើទើបបានសម្រេច ពុំអាចសង្គ្រាមប្រជាជន យកប្រជាជនពីប្រទេសនោះទៅធ្វើសង្គ្រាមនៅប្រទេសដទៃទៀតបានឡើយ ។ សូម្បីតែទទួលយកនូវជំនួយពីបក្សនិងប្រជាជនជាមិត្តនិងជាបងប្អូនទៀត ក៏ចាំបាច់ត្រូវមានអ្នកប្រើប្រាស់ក្នុងស្រុកឲ្យបានត្រឹមត្រូវដែរ បានមានប្រសិទ្ធភាព ។ ប៉ុន្តែកត្តាជំនួយនិងការឧបត្ថម្ភពីបក្សពីប្រជាជនជាមិត្តនិងបងប្អូន ជាកត្តាមួយសំខាន់ចាំបាច់ដាច់ខាត ដែលជួយផ្តល់នូវសង្គ្រាមប្រជាជនកម្លាំងសម្ភារ កម្លាំងនយោបាយ កម្លាំងស្មារតីគ្រប់បែបយ៉ាង ពិសេសក្នុងលោកដែលគេបែងចែកវណ្ណៈជាពីរផ្នែក ក្នុងយុគ្គសម័យដែលសង្គមនិយមនិងបដិវត្តន៍កំពុងមានប្រៀបទៅលើពួកចក្រពត្តិនិយម ។ ដូចនេះត្រូវមានគោលនយោបាយនិងការកសាងបរទេសត្រឹមត្រូវដើម្បីប្រមូលកម្លាំងក្នុងសកលលោកឲ្យបានជាអតិបរមា ហើយសង្គ្រាមប្រជាជនអាចយកជ័យជម្នះបានជាបន្តបន្ទាប់ លុះត្រាតែមានចរិត៤យ៉ាងនិងកត្តា៥យ៉ាងដាច់ខាត ចំពោះសត្រូវដ៏ធំសម្បើមទោះជាមានគ្រឿងសាស្ត្រាវុធសម្បូរបែបយ៉ាងណាក៏ដោយ ។ ម្យ៉ាងទៀតថាចំពោះមុខនៃសង្គ្រាមប្រជាជនដែលមានលក្ខណៈពេញលេញ ចក្រពត្តិអាមេរិកាំងជាចក្រពត្តិលេខមួយលើសកលលោកត្រូវបរាជ័យដាច់ខាត ។

**(ឯកសារលេខ D ២១៩៣០)**

# ប្រជុំជីវភាព "ទិតៀន-ស្វ័យទិតៀន"

ប្រជុំជីវភាព ឬហៅថា «ទិតៀន-ស្វ័យទិតៀន» ត្រូវបានអនុវត្តជាទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រៅពីបំពេញការងារតាមការកំណត់របស់អង្គការ ប្រជាជនមានភារកិច្ចមួយទៀត គឺចូលរួមប្រជុំជីវភាពទិតៀននិងចាប់កំហុសគ្នាទៅវិញទៅមកអំពីកិច្ចការដែលបានបំពេញ ដើម្បីស្ថាបនាសង្គមបដិវត្តឲ្យកាន់តែត្រចះត្រចង់ ។ ប៉ុន្តែការស្ថាបនាដោយការប្រជុំជីវភាព «ទិតៀន-ស្វ័យទិតៀន» បានធ្វើឲ្យបាត់បង់ជីវិតមនុស្សអស់ជាច្រើននាក់ ។

នៅក្នុងកំណត់ហេតុ «ប្រជុំការងារមន្ទីរពេទ្យ» បានបញ្ជាក់អំពីកាលបរិច្ឆេទនិងបញ្ហា «ទិតៀន-ស្វ័យទិតៀន»រវាងបុគ្គលិកនៅក្នុងមន្ទីរពេទ្យ១៧មេសា (ពេទ្យរុស្ស៊ី) ។ ក្នុងកំណត់ហេតុបានបញ្ជាក់ឲ្យដឹងថា រាល់ការប្រជុំជីវភាពធំៗ តែងមានវត្តមានចូលរួមរបស់សមមិត្ត អៀង ធីរិទ្ធ ហៅ ភា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ។ អៀង ធីរិទ្ធ បានបញ្ចុះបញ្ចូលគោលនយោបាយបក្សនិងភារកិច្ចពេទ្យសង្គមនិយម ដោយលើកយកមន្ទីរពេទ្យនៅប្រទេសវៀត-ណាមជាឧទាហរណ៍ ។ គណៈសង្គមកិច្ច មានតួនាទីជាអ្នកសរុបរបាយការណ៍សមូហភាពនៅក្នុងអង្គប្រជុំទាំងមូល ។ រឿន ជាប្រធានពួកផ្នែកជំងឺកុមារ ត្រូវទទួលការទិតៀនទៅលើការបំពេញភារកិច្ចមិនបានជិតដល់ មិនគោរពអង្គការវិន័យ នៅមានមុខមាត់បុណ្យសក្តិ បក្សពួក ចចាក់ចចុច និងចាំតែវាយប្រហារចំណុចខ្សោយទៅលើអ្នកដទៃ ។ ញឹម ត្រូវគណៈមន្ទីរពេទ្យទិតៀនពីបទមិនបេះឈើចាប់នឹងវណ្ណៈ និងធ្វើឲ្យអ្នកជំងឺមើលស្រាល ។ កេនត្រូវទទួលការទិតៀនក្នុងការបំពេញភារកិច្ចមិនទាន់ដែនការ ខ្វះខាតសីលធម៌ ការនិយាយស្តីមិនទាន់ទទួលខុសត្រូវក្នុងការវះកាត់ មិនគោរពវិន័យ និងខ្ជិលរៀនសូត្រ ។

ប៉ុល ពត អគ្គលេខាបក្សកុម្មុយនិស្តនិងជារដ្ឋមន្ត្រីនៃរបបខ្មែរក្រហម បានដាក់បញ្ជាឲ្យមន្ទីរក្រសួងនិងមូលដ្ឋានទាំងអស់អនុវត្តការប្រជុំជីវភាព «ទិតៀន-ស្វ័យទិតៀន»ជាប្រចាំ ។ នៅក្នុងកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍លើកទី២ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ ប៉ុល ពត បានកំណត់ឲ្យមន្ទីរក្រសួងទាំងអស់«ប្រជុំមួយខែម្តង» ដើម្បីពិនិត្យសភាពការណ៍រួម ជំរុញកិច្ចដំណើរការក្រសួងនីមួយៗឲ្យខ្លាំងក្លាតាមសន្ទុះមហាលោតផ្លោះមហាអស្ចារ្យ ។ ឯកសារD២១៨០ ចុះថ្ងៃទី១៣-៧-៧៨ ប៉ុល ពត បានអះអាងថា «តាមពិសោធន៍ បើចង់ឲ្យស្អាតត្រូវធ្វើការទិតៀនទៅល្អជាង ។ បើធ្វើមិនកើតក្នុងក្រសួង ធ្វើជាមួយអចិន្ត្រៃយ៍ក៏បាន ។ ខ្ញុំ(បងលេខ)សុខចិត្តការពារ ៗ» ។

ក្នុងកិច្ចសន្ទនាជាមួយគណៈប្រតិភូ ប៊ែលហ្ស៊ិក នៅទីក្រុងភ្នំពេញថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៨ ប៉ុល ពត បានអះអាងថា ប្រជាជនមានរបបប្រជុំធ្វើ «ទិតៀន-ស្វ័យទិតៀន» ជាប់ដើម្បីដោះស្រាយទំនាស់ជាបន្តបន្ទាប់...ទោះសមត្ថភាពអន់ថយយ៉ាងណាក៏ដោយ ឲ្យតែកសាងគ្នារាល់ថ្ងៃមុខជាបានចម្រើន» ។

(អ្នកស្រី) ពន សយ អតីតគ្រូបង្រៀនកុមារនៅទីក្រុងភ្នំពេញ បានអះអាងថា ប៉ុល ពត បានដើរផ្លូវខុសដោយមិន«និយមពួកបញ្ញវន្ត» ជួនកាលទិតៀនអ្នកទាំងនោះថាជាពួកសក្តិភូមិ អនុធនបញ្ញវន្ត ហើយអ្នកទាំងនោះត្រូវបានសម្លាប់ជាបន្តបន្ទាប់ ។ រូបគាត់ផ្ទាល់ក៏ត្រូវអង្គការធ្វើការទិតៀនពីបទយំនឹកកូន ថ្នាំងថ្នាក់នឹងអង្គការដែលយកកូនទើបមានអាយុ៧ខែទៅដាក់ក្នុងមណ្ឌលកុមារ ។ ពន សយ ត្រូវអង្គការខ្មែរក្រហមបង្ខំឲ្យទទួលកំហុសពីបទមានសតិអារម្មណ៍មិននឹងន ប៉ុន្តែគាត់មិនហ៊ាន«កសាងអង្គការ» វិញទេ ទោះបីអង្គការមានកំហុសក៏ដោយ ។ អ៊ីង វុធ អតីតនារីពេទ្យតំបន់១៣ត្រូវបានទិតៀនយ៉ាងខ្លាំងពីសំណាក់ប្រធានពេទ្យនិងបុគ្គលិកដូចគ្នាថា «នៅជាប់កម្មែលសក្តិភូមិ» ពីព្រោះគាត់ពាក់អាវដៃខ្លីបញ្ចេញសាច់ ។ ទីបំផុត គាត់ត្រូវអង្គការចាប់យកទៅអប់រំនៅគុកភ្នំសន្ទុង ។ មុំ ហេង អតីតបុគ្គលិកពេទ្យស្រុក បានឲ្យដឹងថា ក្នុងរយៈពេលបីថ្ងៃម្តង អង្គការបានចាត់តាំងឲ្យប្រជុំជាក្រុមៗមានគ្នា៤នាក់ ដើម្បីប្រជុំកសាង

គ្នាទៅវិញទៅមក ។ ហេង ត្រូវបុគ្គលិកដូចគ្នាទិតៀនជាញឹកញាប់ពីរឿងដេកលក់ដាស់មិនងាយភ្ញាក់ ។ ហេង ក៏ធ្លាប់បានទិតៀនទៅអ្នកទាំងនោះវិញដែរចំពោះករណីដូចគ្នា ។

បុគ្គលិកពេទ្យខ្មែរក្រហមអនុវត្តគោលនយោបាយនេះយ៉ាងខ្ជាប់ខ្ជួន ។ យ៉ាងតិចបីដងក្នុងមួយសប្តាហ៍ បុគ្គលិកពេទ្យទាំងអស់ត្រូវចូលរួមស្តាប់ប្រធានអង្គប្រជុំកសាងទិតៀនពីកំហុសនៅពេលថ្ងៃ ពិសេសទិតៀនអំពីរឿងសីលធម៌បុរសនារីនិងសីលធម៌រស់នៅប្រចាំថ្ងៃ ។ ទំនាក់ទំនងស្នេហាបុរសនារីត្រូវហាមដាច់ខាត ។ ប្រសិនបើកើតមានបញ្ហាខុសសីលធម៌បុរសនារីទាំងពីររូបនោះគឺត្រូវបានខ្មែរក្រហមចាត់ទុកថាបានប្រព្រឹត្ត "បទឧក្រិដ្ឋ" ហើយត្រូវចាប់យកទៅធ្វើទារុណកម្មដាក់គុកនិងសម្លាប់ចោល ។



និន ហាន អតីតនារីពេទ្យស្រុកត្រាំកក់ ធ្លាប់ជាប់គុកនៅក្រាំងតាចាន់

ដួង ម៉ាឡា បានអះអាងថា ការស្រឡាញ់គ្នាដោយលួចលាក់ក៏ត្រូវអង្គការចាត់ចូលជាបទឧក្រិដ្ឋដែរ ។ នៅឆ្នាំ ១៩៧៨ មានបុរសម្នាក់ឈ្មោះ ជា (ប្រជាជន១៧ មេសា) បានស្រឡាញ់នារីមូលដ្ឋានម្នាក់ឈ្មោះ យ៉ារ៉ាត់ ។ ជា និង យ៉ារ៉ាត់ បានសុំអង្គការរៀបការ ប៉ុន្តែអង្គការមិនអនុញ្ញាត ពីព្រោះអ្នកទាំងពីរស្ថិតនៅក្នុងវណ្ណៈហាមឃាត់ ។ មួយឆ្នាំក្រោយមក ស្នេហាលួចលាក់របស់អ្នកទាំងពីរត្រូវបែកការណ៍ ។ អង្គការក៏ចាប់អ្នកទាំងពីរសម្រាតខោអាវចងជាប់នឹងសសរ យកភ្លើងដុតពេញខ្លួននិងវាយដោយស៊ុយកាំភ្លើង ។ ក្រោយពីធ្វើទារុណកម្ម អ្នកទាំងពីរត្រូវអង្គការបញ្ជូនយកទៅដាក់គុកនិងបង្ខំឲ្យធ្វើពលកម្មជាទម្ងន់រហូតដល់ស្លាប់នៅក្នុងគុក ។

ជ័យ សារីម ដែលជាប្អូនរបស់ ជ័យ សារីម បាននិយាយថា "ជ័យ សារីម អតីតបុគ្គលិកនៅមន្ទីរពេទ្យព៦ ក្រុងភ្នំពេញ ត្រូវអង្គការយកទៅសម្លាប់ចោល ព្រោះតែមានស្នេហាលួចលាក់ជាមួយបុរសម្នាក់" ។

និន ហាន អតីតពេទ្យស្រុកត្រាំកក់ បានត្រូវអង្គការចាប់ដាក់គុកក្រាំងតាចាន់ពីបទខុសសីលធម៌ ។ អាង អតីតស្ត្រីនៅកងមេម៉ាយនៅវត្តភ្នូន ស្រុកកណ្តាលស្ទឹង ត្រូវអង្គការខ្មែរក្រហមយកទៅសម្លាប់ ពីព្រោះគាត់បានច្រៀងបទចម្រៀងពីសង្គមចាស់ និងមានស្នេហាលួចលាក់ជាមួយបុរសមូលដ្ឋាន ។

នៅក្នុងសៀវភៅកំណត់ហេតុរបស់កម្មាភិបាលពេទ្យខ្មែរក្រហមឈ្មោះ ឌិក សំអ បានពិពណ៌នាថាការធ្វើ "ទិតៀន-ស្វ័យទិតៀន" គឺកម្ចាត់និងកសាងកម្លាំង កម្ទេចចោលរបបចក្រពត្តិនាយទុន សក្តិភូមិ កម្ទេចធាតុវណ្ណៈ ដើម្បីកសាងសង្គមនិយម និងតស៊ូកសាងសាមគ្គីភាពផ្ទៃក្នុងបដិវត្តន៍" ។

អង្គការខ្មែរក្រហមបានដាក់បញ្ជាឲ្យអង្គភាពមន្ទីរក្រសួង និងមូលដ្ឋានអនុវត្តការប្រជុំជីវភាព "ទិតៀន-ស្វ័យទិតៀន" និងប្រជុំការងារសន្និបាត មហាសន្និបាត ។ ការប្រជុំនៅក្នុងមន្ទីរពេទ្យកម្មាភិបាលខ្មែរក្រហម គឺដើម្បីកសាងនិងជួយកែលម្អចំណុចខ្វះខាតបច្ចេកទេសទៅវិញទៅមក និងចៀសវាងមិនឲ្យឈ្លោះប្រកែកជាមួយអ្នកជំងឺ ។ ទិតៀន-ស្វ័យទិតៀន តម្រូវឲ្យសាមីជនព្រមដាក់ចិត្តដាក់កាយឲ្យមហាជននៅជុំវិញខ្លួន លាតត្រដាងពីទោសកំហុសដែលខ្លួនបានប្រព្រឹត្ត ។ សាមីជន ត្រូវទទួលស្គាល់អំពីទោសកំហុសដោយរីករាយ និងត្រូវសន្យាថានឹងកែប្រែកំហុសឆ្គងទាំងអស់ដែលបានប្រព្រឹត្តកន្លងមក ។

នៅក្នុងកំណត់ហេតុ“ប្រជុំការងារមន្ទីរពេទ្យ” បានបញ្ជាក់ឲ្យដឹងថា ស្ទើរតែរៀងរាល់ថ្ងៃ មន្ទីរពេទ្យ១៧មេសា បានប្រជុំជីវភាព “ទិតៀន-ស្វ័យទិតៀន” ។ ចាន់ ជាបុគ្គលិកនៅមន្ទីរពេទ្យ ១៧មេសា បានចាក់ថ្នាំហួសកម្រិត ។ រ៉ាត ជាបុគ្គលិកនៅមន្ទីរពេទ្យ១៧ មេសា បានចាក់សេរ៉ូមឲ្យអ្នកជំងឺខុសនឹងរោគសញ្ញា ។ មុំ ជាបុគ្គលិកនៅមន្ទីរពេទ្យ១៧មេសា ត្រូវគណៈពេទ្យឈ្មោះ យ៉េត, រី និង ដៃ រាយការណ៍ថា ប្រើថ្នាំខុស បណ្តាលឲ្យអ្នកជំងឺស្លាប់ ។ បុគ្គលិកមន្ទីរពេទ្យ១៧មេសា រាប់រយនាក់ទៀតត្រូវចាប់ដាក់គុកនិងសម្លាប់ព្រោះតែកំហុសបន្តិចបន្តួច ។ ការចាប់មនុស្សទាំងខ្សែៗនៅក្នុងមន្ទីរពេទ្យ១៧មេសា បានធ្វើឲ្យបុគ្គលិកមន្ទីរពេទ្យមានការភិតភ័យយ៉ាងខ្លាំង ។ ការភិតភ័យនឹងសេចក្តីស្លាប់ ដោយសារការកសាងទិតៀន-ស្វ័យទិតៀនពីមហាជនធ្វើឲ្យបុគ្គលិកពេទ្យមានការភ្លាំងភ្លាត់ចំពោះភារកិច្ចរបស់ខ្លួនជាញឹកញយ ។ ជាពិសេសការប្រើថ្នាំខុសនឹងរោគសញ្ញារបស់អ្នកជំងឺ ។ គ្រាន់តែអំឡុងខែឧសភា និងខែមិថុនា ឆ្នាំ១៩៧៨ មន្ទីរពេទ្យ១៧ មេសា មានមនុស្សស្លាប់អស់ចំនួន៨៣នាក់ ។

ប្រជុំជីវភាព “ទិតៀន-ស្វ័យទិតៀន” បានធ្វើឲ្យរបបមហាលោតផ្លោះមហាអស្ចារ្យរបស់ខ្មែរក្រហមប្រែក្លាយទៅជា“គុកឥតជញ្ជាំង” និងជារបបមួយដែលមានការមិនទុកចិត្តគ្នា ។ មនុស្សម្នាក់ៗក្លាយទៅជាខ្មាំងរបស់អង្គការដោយសារការតែចាប់កំហុសគ្នាទៅវិញទៅមក ។ ការប្រជុំជីវភាព“ទិតៀន-ស្វ័យទិតៀន” បានផ្តាច់ទំនាក់ទំនងមនោសញ្ចេតនារវាងឪពុកម្តាយនិងកូនឲ្យស្អប់គ្នា រាយការណ៍ពីគ្នាទៅវិញទៅមក ។ សួង ស៊ីគឿន ដែលជាសមាជិកក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ក៏ត្រូវទទួលការរិះគន់ “ទិតៀន” ពីសំណាក់សមាជិកដូចគ្នា ពីបទមានប្រពន្ធជាជនជាតិបារាំង និងធ្វើការពុំទទួលខុសត្រូវ ទោះបីជាសួង ស៊ីគឿន និងប្រពន្ធរបស់គាត់ ធ្លាប់មានគុណបំណាច់នឹងបដិវត្តន៍ក្នុងការតស៊ូនៅក្រៅប្រទេសយ៉ាងណាក៏ដោយ ។ សួង ស៊ីគឿន ខ្លួនឯងក៏តែងតែទិតៀនប្រពន្ធគាត់ជាញឹកញាប់ ធ្វើឲ្យចំណងគ្រួសារមានការប្រេះឆា ។

ទោះបី ប៉ុល ពត, អៀង ធីរិទ្ធ និងសមមិត្តទាំងអស់ ខិតខំប្រើប្រាស់ទ្រឹស្តី“ទិតៀន-ស្វ័យទិតៀន” លើកយកហេតុផលផ្សេងៗក្នុងការកសាងសង្គមមួយស្អាតស្អំយ៉ាងណាក៏ដោយ ក៏ហេតុផលនេះនៅតែបរាជ័យ ។ រាល់កំណត់ហេតុប្រជុំជីវភាព “ទិតៀន-ស្វ័យទិតៀន” តែងតែមានកត់ត្រានូវគុណវិបត្តិសមាជិកជាសម្ងាត់ ទោះបីអ្នកទាំងនោះធ្លាប់មានគុណប្រយោជន៍ដ៏លើសលប់ចំពោះសង្គមនិងបក្សក៏ដោយ ។

ឌី ផុន អតីតពេទ្យធ្មេញមុនរបបខ្មែរក្រហម បានលះបង់សុភមង្គលគ្រប់បែបយ៉ាងចូលបម្រើខ្មែរក្រហមតាំងពីទសវត្សរ៍ឆ្នាំ១៩៧០ ក្នុងការបង្កើតក្បួនច្បាប់ឱសថបុរាណសម្រាប់របបកម្ពុជាប្រជាធិបតេយ្យទាំងមូល ។ ប៉ុន្តែ ឌី ផុន នៅតែទទួលការរិះគន់ទិតៀន-ស្វ័យទិតៀន ពីសំណាក់អង្គការខ្មែរក្រហមដដែល ។ នៅខែ១២ ឆ្នាំ១៩៧៨ ឌី ផុន ត្រូវបានអង្គការចាប់ដាក់គុកទួលស្លែង ។

ការកម្ទេចចោលធនធានមនុស្ស តាមរយៈការប្រជុំជីវភាព “ទិតៀន-ស្វ័យទិតៀន”របស់ ប៉ុល ពត បានធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យក្លាយជាទីវាលកប់ខ្មោចមនុស្សរាប់លាននាក់និងបង្កគ្រោះមហន្តរាយដល់សង្គមខ្មែររហូតដល់បច្ចុប្បន្ន ។

**អែម សុខឃីម**

## ពាក្យស្លោកខ្មែរក្រហម

◆ **ប្រយុទ្ធពុំបានជ័យជម្នះ ប្រយុទ្ធជាថ្មីពុំបានជ័យជម្នះទៀត ប្រយុទ្ធហើយប្រយុទ្ធទៀតដល់ទីបំផុត សម្រេចនៅគជ័យជម្នះ ប្រាកដ នេះជាដំណើរសមហេតុផលរបស់ប្រជាជន ប្រជាជនក៏មិនអាចចៀសវាងដំណើរសមហេតុផលនេះដែរ នេះជាច្បាប់មួយនៃម៉ាក្សស៊ីសនិយមបដិវត្តន៍របស់ប្រជាជន មិនបានសម្រេច បានសម្រេចឡើងតាមគម្រោងច្បាប់បដិវត្តរបស់ប្រជាជនខ្មែរ ក៏បានសម្រេចឡើងតាមគម្រោងច្បាប់នេះដែរ។**

◆ **អាវុធជាកត្តាមួយសំខាន់ តែមិនមែនជាកត្តាឱ្យឈ្នះសង្គ្រាមទេ កត្តាសម្រេចធំបំផុតគឺមនុស្សមិនមែនសម្ភារតែម្យ៉ាងទេ។**

*(កំណត់ហេតុរបស់សមមិត្ត ញ៉ក សារុន)*

***(តពីលេខមុន)***

*ការសម្តែងមួយទៀតបានត្រូវរៀបចំឡើងនៅសហរដ្ឋអាមេរិកនាដើមទសវត្សរ៍ឆ្នាំ១៩៦០ ដោយ ស្តេនលី មីលក្រាម ផ្តល់នូវទិដ្ឋភាពកាន់តែស៊ីជម្រៅ ។ អ្នកស្ម័គ្រចិត្តនៅទីក្រុងញូហេវិន រដ្ឋខណេធិខិត ត្រូវបាន"ចិត្តវិទូខាងអប់រំ"ឲ្យអង្គុយក្នុងបន្ទប់មួយហើយឲ្យដើរតួជា"គ្រូបង្រៀន" ។ (សិស្សមហាវិទ្យាល័យត្រូវបានហាមប្រាមមិនឲ្យចូលរួមជាមួយទេ) ។ អ្នកស្ម័គ្រចិត្តទាំងនោះ បន្ទាប់មកត្រូវបានឲ្យចុចកុងតាក់ឆក់ខ្សែភ្លើងចំពោះចម្លើយណាដែល"មិនត្រឹមត្រូវ"ទៅនឹងសំណួររបស់"ចិត្តវិទូខាងអប់រំ" ។ សំណួរទាំងអស់គឺទុកឲ្យខាងនិស្សិតដែលស្ថិតនៅក្នុងបន្ទប់ផ្សេងមិនអាចមើលគ្នាឃើញ ដែលស្តាប់ឮជាអ្នកឆ្លើយ ។*

*តាមការពិតគ្មានចរន្តឆ្លងកាត់នៅក្នុងកុងតាក់ដែលខាងលោកគ្រូចុចទេ ចំណែកនិស្សិតទាំងអស់ លោក មីលក្រាម ជាអ្នកជួលមក ។ នៅពេល"កំហុស"របស់និស្សិតចេះតែកើនឡើងច្រើនទៅៗ អាំងតង់ស៊ីតេនៃការឆក់ចេះតែកើនឡើង រហូតដល់គ្រូមួយចំនួនចុចដល់កម្រិតខ្លាំងបំផុតដែលស្តាប់ទៅពិតជាគួរឲ្យឈឺចាប់និងគ្រោះថ្នាក់ពោលគឺជាការស្តែងចេញតាមរយៈការសង្កត់កុងតាក់ដោយមេដៃ ស្រែកខ្លាំងៗ និងភាពស្ងាត់ជ្រងំពីបន្ទប់នៅជាប់គ្នា ។ ប៉ុន្មានថ្ងៃក្រោយមក មានគ្រូម្នាក់ក្នុងចំណោមគ្រូ៣នាក់នៃគ្រូទាំងអស់ បានបដិសេធនូវអ្វីដែលបានកើតឡើង ឬឈប់ធ្វើពិសោធន៍តែម្តង ។ ពីរឆ្នាំក្រោយមកទៀតក៏មានការពិសោធន៍តាមរបៀបផ្សេងៗដែរ ។ ដូចជាយកអ្នកទាំងនេះទៅទីក្រុងដ៏មមាញឹកមួយ គឺទីក្រុងប្រ៊ីចដត ឲ្យគ្រូនិងសិស្សទាក់ទងគ្នាដោយផ្ទាល់ ឲ្យមានចំនួនស្ត្រីច្រើននៅខាងក្រុមគ្រូៗ និងផ្លាស់ប្តូរចិត្តវិទូចេញទៅកន្លែងផ្សេង ។ លទ្ធផលភាគច្រើននៅតែដូចគ្នាដដែល ។ ការពិសោធន៍ទាំងអស់ដែលបានធ្វើមកមានករណីលើកលែងតិចបំផុតបង្ហាញថា "២ភាគ៣នៃជនជាតិអាមេរិកាំងទូទៅ (ក្នុងចំនួនមនុស្សដែលយកមកធ្វើពិសោធន៍) ចង់ឆក់ជនរងគ្រោះដែលស្លូតត្រង់រហូតដល់គាត់ស្រែកសុំជីវិតរស់ ហើយចង់បន្តឆក់ជនរងគ្រោះនេះរហូតដល់ដួលស្រ៊ុបបាត់មាត់ឈឹង ។ នេះជាអ្វីដែល អាឡាំង អែម្ស បានសរសេរ ។*

*នៅក្នុងការសិក្សាពិសោធន៍មួយទៀត ចន ដាលី បានឲ្យយោបល់ថា ការគោរពគ្រូត្រូវបានធ្វើឲ្យស្របទៅតាមវត្តមាននៃអ្នកធ្វើពិសោធន៍ ដែលត្រូវបានឲ្យបញ្ឈប់ពីអំពើឃោរឃៅទ្រង់ទ្រាយធំ ។ ចន ដាលី និយាយថា ដោយត្រូវគេបណ្តោយឲ្យធ្វើអ្វីៗស្រេចតែចិត្តគ្រូៗនឹងមិនមើលការខុសត្រូវចំពោះការឆក់ខ្សែភ្លើងឡើយ ។ ដូច្នេះ តាមដែលលោកទាញហេតុផលគឺធ្វើឲ្យមានចន្លោះរវាងគ្រូៗដែល មីលក្រាម រៀបចំនិងអ្នកដែលបានប្រព្រឹត្តអំពើឃោរឃៅ ។ ចន ដាលី បន្ថែមទៀតថា ធ្វើឲ្យមនុស្សហ៊ានប្រព្រឹត្តអំពើឃោរឃៅ គឺទាក់ទងនឹងពេលវេលា ។*

*អាឡិចសាន់ដ័រ ហ៊ីនតុន បានទាញហេតុផលថា ការគោរពដល់កម្រិតនេះកើតឡើងស្ទើរតែគ្រប់ពេលនៅក្នុងការពិសោធន៍ ហើយកាន់តែជ្រាលជ្រៅជាងនេះទៅទៀតនៅក្នុងវប្បធម៌ខ្មែរ ។ ខ្ញុំសូមនិយាយថា ការកម្ទេច"ខ្មាំង"នៅមន្ទីរស-២១ត្រូវបានធ្វើឡើងបានដោយងាយ គឺដោយសារការយល់ព្រមនិងការគោរព ដែលមានជាប្រពៃណីទៅហើយនៅក្នុងសង្គមខ្មែរពីសំណាក់អ្នកតូចទាប ចំពោះអ្នកមានអំណាច ។ វប្បធម៌ការកេងប្រវ័ញ្ច ការការពារ ការគោរព និងការពឹងពាក់ទាំងអស់នេះបានចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងការអនុវត្តជាក់ស្តែងនៅក្នុងសង្គមកម្ពុជា និងពង្រឹងការក្តាប់អំណាចរបស់អ្នកកាន់អំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បើទោះបីជា(ឬដោយសារ)អ្នកកាន់អំណាចបញ្ឈាក់ហើយបញ្ឈាក់ទៀតថា ទំនាក់ទំនងអំណាចមុន*




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី៦: បរិយាយអំពីមន្ទីរស-២១**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

បដិវត្តន៍ត្រូវបានកម្ទេចចោលអស់ហើយយ៉ាងណាក៏ដោយ ។ ឋានានុក្រម ការគួរសម និង“ការគោរពសំពះ” បង្ហាញយ៉ាងច្បាស់ពី“ការជិះជាន់” ដែលមិនត្រូវបានលុបបំបាត់ដោយសារបដិវត្តន៍ទេ ។ ប៉ុន្តែនៅមានភាពលម្អៀងនៅក្នុងរូបភាពថ្មីជាចៅហ្វាយនិងអ្នកបម្រើ (ដូចជាការ“ទទួលអំណាច”និងចាត់តាំងឲ្យធ្វើជាកម្មាភិបាល) និងជនរងគ្រោះបែបថ្មី ។ នៅក្រោមវិន័យរបស់ខ្លួន អ្នកនៅមន្ទីរស-២១ត្រូវបានបែងចែកជា÷ ម្នាងជាអ្នកបញ្ជាឬប្រើអ្នកដទៃនិងអ្នកស្តាប់ ដែលគេដាក់ឲ្យប្រើអ្នកបម្រើ រីឯម្នាងទៀតជាជនរងគ្រោះទូទៅ ។ ក្នុងដូវខ្វះសង្គម “ថ្មី” មានចម្រុះដោយបញ្ហានេះ ដូចមុននិងក្រោយការប្រើអំណាចនិងគោរពអំណាចបដិវត្តន៍ដែរ ។

ទោះជាអ្នកសួរចម្លើយនៅមន្ទីរស-២១ធ្លាប់មានសេចក្តីស្មោះត្រង់ចំពោះអ្នក“នៅពីលើ”ខ្លួន ហើយទោះជាទំនាក់ទំនងរវាងអ្នកសួរចម្លើយនិងអ្នកទោសនៅគ្រប់ស្ថាប័នតែងតែមានភាពស្មុគ្រស្មាញក៏ដោយ ប៉ុន្តែ “ភាពមានប្រៀប” របស់អ្នកសួរចម្លើយនៅមន្ទីរស-២១ បើតាមរយៈសៀវភៅរបស់ ប៉ុន គឺថាអ្នកទោស “ស្ថិតនៅក្នុងដៃ(របស់អ្នកសួរចម្លើយ)” ។ គ្មានការអនុវត្តកំហិតជាលក្ខណៈច្បាប់ គ្មានសម្ពាធពីខាងក្រៅរដ្ឋាភិបាល និងគ្មានពេលកំណត់ជាក់លាក់ឡើយ ។ ដរាបណាអ្នកសួរចម្លើយសួរអ្នកទោសដដែលៗ និងធ្វើទារុណកម្មគ្រប់បែបយ៉ាងដើម្បីទទួលចម្លើយសារភាព ហើយអ្នកសួរចម្លើយអាចធ្វើអ្វីបានស្រេចតែចិត្តតាមតែខ្លួនយល់ថាសមរម្យ ។

គិតដល់អំណាចរបស់អ្នកសួរចម្លើយ និងភាពគ្មានអំណាចទាល់តែសោះរបស់អ្នកទោស ព្រមទាំងដំណើរការសួរចម្លើយនៅមន្ទីរស-២១ ធ្វើឲ្យនឹកឃើញដល់រឿងល្បើកដែលជាស្នាដៃនិពន្ធរបស់ ឡា ហ្វុងតែន ដែលនិយាយពីចចកនិងកូនចៀម ។ នៅក្នុងរឿងព្រេងនេះ ចចកបានជួបនឹងកូនចៀមមួយ និងចង់ស៊ីសាច់កូនចៀមនោះ ពីព្រោះ បើតាមចចកនិយាយថា កូនចៀមនេះបានធ្វើឲ្យខ្លួនអាម៉ាស់មុខ “មួយឆ្នាំមកហើយ” ។ នៅពេលកូនចៀមឆ្លើយថា កាលពីឆ្នាំមុនវាមិនទាន់កើតផង ចចកក៏តបវិញថា “ប្រសិនបើមិនមែនឯង ក៏បងរបស់ឯងដែរ” ។ កូនចៀមឆ្លើយប្រាសវិញថា “ខ្ញុំគ្មានបងទេ” ។ “អ៊ីចឹងមានតែបងប្អូនឯង អ្នកគង្វាលរបស់ឯង ឬឆ្កែរបស់ឯង” ចចកស៊ីកសម្តីរួចហើយ ក៏ស៊ីកូនចៀមតែម្តងទៅ ។

នៅក្នុងជំពូកទី៥ យើងបានពិនិត្យករណីមួយចំនួនដែលកើតមានឡើងពីមុន នៅក្នុងអតីតកាលរបស់ប្រទេសកម្ពុជាលើអំពើឃោរឃៅនៅមន្ទីរ ស-២១ និងជួរនានាដែលទារុណកម្មក្នុងគុកក្លាយជាពាក្យពន្យល់របស់ ហ៊ូខល ដែលថា “ការសងសឹករបស់អ្នកកាន់អំណាច” ។ យើងដឹងថា ភាពដាច់ខាតនិងហ្មត់ចត់នៅមន្ទីរ ស-២១ ស្រដៀងគ្នានឹងគំរូពិសេសៗមួយចំនួននៅក្នុងសតវត្សរ៍ទី២០ ដែលមួយផ្នែកភ្ជាប់ទៅនឹងការអនុវត្តតាមបែបកុម្មុយនិស្ត និងមួយផ្នែកទៀតទាក់ទងនឹងប្រព័ន្ធស៊ើបការណ៍សម្ងាត់ទំនើប ។ គំរូសម្រាប់មន្ទីរស-២១ រួមមានការកាត់ក្តីនៅមូស្គូដែលគ្រាន់តែឲ្យល្អមើល និងវិសុទ្ធកម្មនៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០ និង “យុទ្ធនាការអប់រំកសាង” នៅប្រទេសចិនក្រោមអំណាចរបស់ ម៉ៅ សេទុង និងវៀតណាមកុម្មុយនិស្ត ។ មន្ទីរស-២១នាំដល់គំនិត “យុត្តិធម៌បដិវត្តន៍” របស់បារាំង ។ នៅទសវត្សរ៍ឆ្នាំ១៧៩០ យុត្តិធម៌បដិវត្តន៍បានឡើងដល់កំពូល បើនិយាយតាមន័យភាសាវិទ្យាថា ពាក្យថ្មីប្រឆាំងនឹងបដិវត្តន៍ និងអ្នកប្រឆាំងនឹងបដិវត្តន៍ ដែលអនុញ្ញាតឲ្យអ្នកគាំទ្រមានសេរីភាពយ៉ាងពេញទំហឹង ។ សារសំខាន់នៃពាក្យទាំងពីរម៉ាត់នេះ អាចប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ។ នៅមន្ទីរស-២១ ពាក្យថា “ខ្មាំង” មានន័យប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ដូចជាពាក្យខាងលើនេះដែរ ។

មជ្ឈិមបក្សបានអនុម័តនូវមនោគមវិជ្ជាពីរបបកុម្មុយនិស្តដទៃទៀតដែលថា ថ្នាក់ដឹកនាំបក្សកុម្មុយនិស្ត មិនប៉ះពាល់ក្រុមច្បាប់គហបតី ឬប្រព័ន្ធតុលាការមិនល្អនោះ មានសិទ្ធិពេញលេញក្នុងការដាក់ទណ្ឌកម្មទៅលើខ្មាំងរបស់រដ្ឋ ។ ថ្នាក់ដឹកនាំត្រូវបានផ្តល់អំណាចឲ្យ ។ ធ្វើយ៉ាងដូច្នេះដោយសារថ្នាក់ដឹកនាំទាំងនោះមានទំនាក់ទំនងពិសេសទៅនឹងច្បាប់ប្រវត្តិសាស្ត្រ ។ តាមគន្លងរបស់ចិន និងវៀតណាមកុម្មុយនិស្តមានគំនិតបដិបក្ខថា យ៉ាងហោចណាស់មានសត្រូវមួយចំនួនអាចយកទៅអប់រំកសាងនិងកែប្រែបាន ពោលគឺជាគំនិតដែលចាក់ឬសគល់យ៉ាងជ្រៅនៅក្នុងប្រទេសទាំងពីរនេះ និងមានការអនុវត្តតិចតួចនៅក្នុងប្រទេសកម្ពុជា ។

ឧបករណ៍សម្រាប់ការកែប្រែនេះ រួមមានការទិតៀននិងស្វ័យទិតៀន ដែលនិយាយអំពីរឿងផ្ទាល់ខ្លួនជាសាធារណៈ ។ នៅមន្ទីរស-២១ អ្នកទោសបានកែប្រែខ្លួន និងត្រូវបានអប់រំកសាងតាមរយៈចម្លើយសារភាពរបស់ខ្លួន ពោលគឺដោយអត្ថបទដែលខ្លួនចោទប្រកាន់ទោសអ្នកទោសទាំងអស់ដល់ជីវិត ។

អ្វីដែលកើតឡើងនៅមន្ទីរស-២១គឺ“កម្ពុជា” “កុម្មុយនិស្ត” និង “បរទេស” ដែលមានកម្រិតផ្សេងៗគ្នា ។ ចំនួនមនុស្សស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជំរុញឲ្យយើងស្វែងរកការពន្យល់ឲ្យកាន់តែច្បាស់ថែមទៀតអំពីរបបនេះ ជាពិសេសគឺអំពីមន្ទីរស-២១ ។ ប៉ែន យៀវនិន បញ្ចេញទស្សនៈផ្ទាល់ខ្លួនថា ផ្ទៃរឿងដ៏សំខាន់មួយក្នុងចំណោមផ្ទៃរឿងសំខាន់ពីរគឺ “បញ្ហាពូជសាសន៍” ។ ចំណែក ម៉ៃឃើល វីកឃ័ររី មានប្រសាសន៍ថា បដិវត្តន៍កម្ពុជាមានលក្ខណៈខុសឆ្ងាយពីបដិវត្តន៍ម៉ាក្ស-ឡេនីន ដែលនិយាយឲ្យចំគឺការផ្ទុះឡើងនូវកំហឹងប្រជាកសិករដែលអួសបន្ទាយនិងមិនអាចគ្រប់គ្រងបាន ។

គំនិតរបស់ យៀវនិន គឺមានប្រយោជន៍ ពីព្រោះភាពសាហាវយង់ឃ្នងនិងភាពមិនអើពើរបស់មន្ទីរស-២១បង្ហាញពីជំនឿមួយថា អ្នកដែលត្រូវសម្លាប់ត្រូវបានចាត់ទុកថាជាអ្នកដែលមានឋានៈក្រោមមនុស្សទូទៅ ហើយថាមិនមាន“ពូជសាសន៍” ដូចជាឃាតករដែលសម្លាប់ជនរងគ្រោះទាំងអស់នោះទេ ។ ជាការច្បាស់ណាស់ ការប្រឆាំងនឹងពូជសាសន៍វៀតណាមជាគំនិតប្រឆាំងពូជសាសន៍ដ៏ជ្រាលជ្រៅរបស់ខ្មែរ ដែលគ្របដណ្តប់លើគំនិត ពាក្យសម្តី និងកាយវិការរបស់កម្ពុជាប្រជាធិបតេយ្យនៅក្រោយឆ្នាំ១៩៧៧ ។

នៅឆ្នាំ១៩៧៨ អ្នកទោសជាច្រើននៅមន្ទីរស-២១ ដែលជាខ្មាំងរបស់រដ្ឋតាមពិតទៅបានក្លាយទៅជាវៀតណាម ។ តាមរបៀបឲ្យអ្នកទោសថ្វាយបង្គំរូបហូជីមិញ និង លីនដុនចនសុន បង្ហាញថា អ្នកទោសកំពុងត្រូវបានកម្ចាត់ចោលពីទឹកដីកម្ពុជាដែលកាន់កាប់ដោយ ប៉ុល ពត មិនខុសពីខ្មាំងពូជសាសន៍របស់ណាហ្ស៊ីទេ ។ សូម្បីតែ មុនពេលយកទៅសម្លាប់ក៏ខ្មាំងទាំងនោះត្រូវបានកម្ចាត់ចេញពីទឹកដីអឺរ៉ុបដែលកាន់កាប់ដោយហ៊ីត្លែរដែរ ។ តាមពិតជនរងគ្រោះភាគច្រើនមានដើមកំណើតជាពូជសាសន៍ដូចជាឃាតកររបស់ខ្លួនដែរ ។ ប៉ុន្តែអ្នកប្រកាន់ពូជសាសន៍បានដើរតួជាអ្នកចាប់ចង់ធ្វើទារុណកម្មនិងសម្លាប់ជនរងគ្រោះទាំងនេះ ។ ដោយប្រែក្លាយជនរងគ្រោះឲ្យទៅជា“អ្នកផ្សេង”តាមបែបពូជសាសន៍ និងដោយប្រើពាក្យអាមីងដូចសត្ធាតុមកលើជនរងគ្រោះ ធ្វើឲ្យឃាតករទាំងនោះមានភាពងាយស្រួលក្នុងការធ្វើទារុណកម្មនិងសម្លាប់ ។ ដំណើរការប្រហាក់ប្រហែលគ្នានេះដែរ ត្រូវបានអ្នកនិពន្ធនានាលើកឡើងទាក់ទងនឹងការសម្លាប់រង្គាលរបស់ណាហ្ស៊ីទៅលើជនជាតិជ្វីហ្វនិងការសម្លាប់រង្គាលនៅក្នុងឆ្នាំ១៩៦៥ និង ឆ្នាំ១៩៦៦ ។

តាមទស្សនៈរបស់ ស្ទីវ ហេដឌ័រ គឺថា ការប្រកាន់ពូជសាសន៍របស់របបកម្ពុជាប្រជាធិបតេយ្យ ទៅលើខ្មាំងរបស់ខ្លួន សំខាន់គឺសំដៅទៅលើបុគ្គលដែលមិនចង់និងមិនអាចអនុវត្តបដិវត្តន៍បែបម៉ាក្ស-ឡេនីន ច្រើនជាងទៅលើពូជសាសន៍ ។ អ្នកដែលជាមុខសញ្ញាថាគ្មានសមត្ថភាព ឬអ្នកប្រឆាំងនឹងបដិវត្តន៍ ជាញឹកញយត្រូវបានហៅថា“វៀតណាម” ។ ហេដឌ័រ សរសេរថា “ការប្រកាន់ពូជសាសន៍របស់របបកម្ពុជាប្រជាធិបតេយ្យ គឺជាលទ្ធផលកើតចេញពីកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីឈានទៅរកលោកទស្សនៈបែបប្រវត្តិសាស្ត្រមួយផ្អែកលើការសន្និដ្ឋានដោយគ្មានការពិនិត្យពិច័យនិងរកការពិតឲ្យបានច្បាស់លាស់ទៅលើសក្តានុពលភាពរបស់សញ្ជាតិនិងពូជសាសន៍កម្ពុជា ដើម្បីរួមចំណែកដល់ពិភពលោកទំនើប តាមរយៈការកសាងសង្គមនិយមមហាលោតផ្លោះមហាអស្ចារ្យ” ។

ប៉ុន្តែមានភាពស្របគ្នាទៅនឹងលោក វីកឃ័ររី ដែលថាភាពឃោរឃៅរបស់បដិវត្តន៍កម្ពុជា គឺបណ្តាលមកពីកំហឹងកសិករច្រើនជាង ការប្រកាន់ពូជសាសន៍ ឬលទ្ធិម៉ាក្ស-ឡេនីន ។ វីកឃ័ររី ទាញហេតុផលថា មជ្ឈិមបក្សត្រូវបានសម្រិតសម្រាំងដោយកំហឹងវណ្ណៈពី“ថ្នាក់ក្រោម” ដែលក្នុងកម្រិតណាមួយប្រហែលជាផ្ទុយនឹងឆន្ទៈរបស់ខ្លួន ។ ការទាញហេតុផលរបស់ វីកឃ័ររី ដែលប្រហែលគ្នាទៅនឹងចលនាម៉ាក្ស-ឡេនីន ដូចជាអនាធិបតេយ្យនិយមរបស់ប្រទេសអេស្ប៉ាញដែរនោះ អាចនិយាយជាសំអាងទៅលើវិសុទ្ធកម្មក្នុងប្រទេសកម្ពុជានាពាក់កណ្តាលឆ្នាំ១៩៧៥ និងការធ្វើបាប“ប្រជាជនថ្មី” ពីសំណាក់កម្មាភិបាលរបស់កម្ពុជា

ប្រជាធិបតេយ្យ ជាពិសេសនៅភូមិភាគពាយ័ព្យ ។ ការនិយមវណ្ណៈកសិករ គឺជាធាតុផ្សំមួយនៃបដិវត្តន៍កម្ពុជា ដូចជាបដិវត្តន៍នៅប្រទេសចិន និងជាការប្រមូលកំហឹងចលនាបដិវត្តន៍ទាំងអស់ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការពន្យល់របស់ វីកឃ័រី មិនសូវជាមានប្រយោជន៍ទេ នៅពេលយើងបានជួបក្នុំឯកសាររបស់កម្ពុជាប្រជាធិបតេយ្យដែលរួមមានទាំងទិនានុប្បវត្តិ ផ្នែកទ្រឹស្តី សុន្ទរកថារបស់ថ្នាក់ដឹកនាំ និងឯកសារសៀវភៅកំណត់ហេតុក្នុងកិច្ចប្រជុំស្ម័យទិតៀន ។ ការទាញហេតុផលរបស់ វីកឃ័រី បានបំបែកកាន់តែលម្អិតថែមទៀត ដោយផ្អែកលើដំណើរការសួរចម្លើយប្រកបដោយវិធីសាស្ត្រ និងជំរុញដោយលទ្ធិកុម្មុយនិស្ត និង“ការឆ្លើយសារភាព” ដែលធ្វើឡើងយ៉ាងខ្ជាប់ខ្ជួននៅមន្ទីរស-២១ ។ ចំពោះរឿងការផារវិញ ឌុច, ចាន់ និង ប៉ុន ដែលជាអ្នកចេះដឹងទាំងអស់ គួរតែមើលឃើញពីសន្តានចិត្តដែលកូនចៅមានចំពោះខ្លួន ជាជាងគិតតែពីសន្តានចិត្តរបស់ខ្លួនឯងផ្ទាល់ ។

នៅមន្ទីរស-២១ ដូចយើងឃើញស្រាប់ហើយ ការដាក់ទណ្ឌកម្មតាមលក្ខណៈប្រពៃណី និងទណ្ឌកម្មតាមគំរូកុម្មុយនិស្តផ្សេងៗទៀត មានផ្សំជាមួយនឹងបច្ចេកទេសស៊ើបអង្កេត ធ្វើឯកសារ និងការគ្រប់គ្រងនៅសតវត្សរ៍ទី២០ ។ របៀបទាំងអស់នេះមាននិយាយលម្អិតនៅក្នុងស្នាដៃនិពន្ធរបស់ ហ្វូខល ដែលមានចំណងជើងថា “វិន័យនិងការដាក់ទណ្ឌកម្ម” និងនៅក្នុងគំនិតផ្សេងមួយទៀតរបស់ អូវើល បោះពុម្ពនៅឆ្នាំ១៩៨៤ ។ ធាតុផ្សំផ្ទុយមកវិញដែលធ្វើឲ្យ “មន្ទីរស-២១” មានរូបរាងឡើងនេះត្រូវបានបង្កើតឡើងតាមគំនិតឧត្តមភាពកើតចេញពីក្នុងខ្លួនដែលសាយភាយនៅក្នុងគំនិតរបស់មជ្ឈិមបក្សផ្តល់នូវភាសាសម្រាប់ប្រើនៅពេលប្រកាសជ័យជម្នះ និងបិទបាំងសមាជិករបស់ខ្លួនមិនឲ្យដឹងពីការពិត ។

សញ្ញាណឧត្តមភាពទាំងអស់នេះមួយផ្នែកចេញមកពីការបកស្រាយរបស់កម្ពុជាប្រជាធិបតេយ្យស្តីអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា និងមួយផ្នែកមកពីការផ្តល់អំណាចដោយចៃដន្យទៅឲ្យប្រជាកសិករនៅតាមជនបទមួយភាគតូចដែលប្រហែលជាត្រូវបានចាត់ទុកថាជាជនបដិវត្តមិនចេះនឿយហត់ គឺជាកម្លាំងដែលគេរៀបចំឡើងដើម្បីកម្មវិធីសេដ្ឋកិច្ច ។ អ្នកទាំងនេះជាញឹកញាប់បានបង្កើតនូវឃ្លាសម្ងែងអំណាចដែលទើបតែទទួលបានដោយអះអាងអភ័យឯកសិទ្ធិធ្វើឲ្យអាម៉ាស់មុខនិងកម្ចាត់ “ខ្មាំងវណ្ណៈ” នៅពេលប្រជាកសិករទាំងនេះត្រូវបានគេឲ្យធ្វើយ៉ាងដូច្នេះ ។

ដូច្នេះមន្ទីរស-២១ ក៏ដូចជារបបកម្ពុជាប្រជាធិបតេយ្យផ្ទាល់ គឺជាវត្ថុចម្លែកខុសគេរបស់ប្រទេសកម្ពុជា ដែលមានបែបផែនជាកុម្មុយនិស្តនិងនាំចូលពីបរទេស ។ ដោយសារតែមានធាតុផ្សំច្រើន ដូច្នេះហើយបានជាមន្ទីរស-២១មានលក្ខណៈខុសគេ ។ ដោយហេតុនេះការប្រៀបធៀបជាមួយគុក អំពីពេលវេលា និងទីកន្លែងខុសគ្នានេះគឺមិនមានអ្វីពិសេសឡើយ ។ ទោះជាមានចរិតជា “ខ្មែរ” ក៏ដោយ ក៏ឆ្នាំគុកម្នាក់នៅប្រទេសកម្ពុជាមុនសម័យបដិវត្តន៍ត្រូវធ្វើឲ្យទាល់គំនិតដោយសារមន្ទីរស-២១នេះដែរ ។ នៅពេលឆ្មាំគុកនេះមានភាពស៊ាំទៅនឹងការរំលោភលើរាងកាយ ប្រវាក់ខ្នោះឃ្នាង ការស៊ើអត់ស៊ីឃ្លាន ភាពគ្មានមេត្តា ហើយភាពដាច់ខាត ភាពឥតប្រែប្រួល និង ភាពឯកោពីពិភពលោកនិងឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ដែលធ្វើឡើងនៅទីនោះពិតជាមិនដែលមានពីមុនមកទេ ។ ដូចគ្នានេះដែរ “ព្រៃស” អាចយកមកប្រៀបធៀបជាមួយកន្លែង“អប់រំ” នៅប្រទេសចិននិងវៀតណាម ។ ចំណែកភាពគ្មានមេត្តារបស់មន្ទីរស-២១ មិនដូចគ្នាទៅនឹងប្រទេសទាំងពីរនេះទេ ។ រីឯការសួរចម្លើយនៅមន្ទីរស-២១ ដែលជាភារកិច្ចយ៉ាងសំខាន់របស់មន្ទីរនេះ មិនដូចគ្នានឹងជំរំមរណៈណាហ្ស៊ីដែលអ្នកនិពន្ធតែងតែលើកយកមកប្រៀបធៀបគ្នាដែរ ។

តាមប្រភពដែលខ្ញុំបានពិនិត្យមើល មិនអាចកំណត់ថាតើអ្នកធ្វើការនៅមន្ទីស-២១ឬអ្នកនៅពីលើធ្លាប់ដែលមានទុក្ខព្រួយឬវង្វេងស្មារតីដែរឬអត់ទេចំពោះអ្វីដែលខ្លួនកំពុងតែធ្វើការនៅក្នុងអំឡុងពេលនោះ ។ អារម្មណ៍មិនទុកចិត្តគឺជាគ្រឿងដ៏ប្រណិត ដែលអ្នកធ្វើការនៅក្នុងគុក និងថ្នាក់ដឹកនាំប្រទេសមិនអាចអត់បាន ។ ប៉ុន្តែ គក ស្រស់ បានប្រាប់ ឌូហ្វាស នីវិន ថាអ្នកសួរចម្លើយដែលរួញរាស្ទាក់ស្ទើរមិនហ៊ានប្រើទារុណកម្មត្រូវបានចាប់ខ្លួន ។

**(នៅមានត)**

# ចាប់ពីទល់ដែនមកដាក់នៅមន្ទីរស-២១


ចាន់ លីម

ជារៀងរាល់ឆ្នាំ នៅថ្ងៃបុណ្យសែនក្បាលទឹកតាមប្រពៃណីរបស់ជនជាតិចិននិងវៀត-ណាម អ៊ឹ ចាន់ លីម តែងតែនឹកឃើញនូវរឿងរ៉ាវដ៏រន្ធត់បំផុតសម្រាប់ជីវិតគាត់ ពីព្រោះនៅក្រោយថ្ងៃសែនក្បាលទឹកមួយថ្ងៃ ក្នុងឆ្នាំ១៩៧៨ ប្រពន្ធនិងកូនប្រុសច្បងពីរនាក់ត្រូវកងទ័ពខ្មែរក្រហមចាប់ខ្លួនពីចម្ការស្រូវរបស់គាត់នៅទល់ដែនមកដាក់នៅមន្ទីរ ស-២១ ។ ប្រពន្ធនិងកូនប្រុសទី១របស់អ៊ឹ ចាន់ លីម ត្រូវបានសន្តិសុខខ្មែរក្រហមនៅមន្ទីរស-២១ វាយសួរចម្លើយនិងសម្លាប់ចោល ។ រូបថតប្រពន្ធនិងកូនប្រុសទី១របស់អ៊ឹ ចាន់ លីម បានបន្សល់ទុកនៅសារមន្ទីរទួលស្លែងរហូតមកដល់បច្ចុប្បន្ននេះ ។ ចំណែកកូនប្រុសទី២របស់គាត់ពុំដឹងថា ខ្មែរក្រហមសម្លាប់ចោលនៅទីណាឡើយ ។

ប្រពន្ធរបស់អ៊ឹ ចាន់ លីម ឈ្មោះ នង គីមហេក្ក ។ បើគិតមកដល់ឆ្នាំ២០០២នេះ អ៊ឹស្រីមានអាយុ៦០ឆ្នាំហើយ ។ អ៊ឹស្រីមានឪពុកជាកូនចៅចិននិងម្តាយជាជនជាតិវៀតណាម ។ អ៊ឹស្រី គីមហេក្ក កើតនៅភូមិព្រែកសង្កែ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ហើយបានរៀបការជាមួយអ៊ឹ ចាន់ លីម នៅឆ្នាំ១៩៦០ ។ ក្រោយពេលរៀបការរួច គាត់ទាំងពីរនាក់ប្តីប្រពន្ធបាននាំគ្នាមករស់នៅភ្នំពេញអស់រយៈពេលមួយឆ្នាំ ។ ដោយសារអ៊ឹស្រី គីម ហេក្ក នឹករឭកឪពុកម្តាយគាត់ពេករហូតដល់ទ្រាំរស់នៅភ្នំពេញមិនបាន គាត់ទាំងពីរក៏នាំគ្នាត្រឡប់ទៅរស់នៅព្រែកសង្កែវិញ ដោយប្រកបមុខរបបទិញដូរផ្តៅ ជ័រ វល្លិ៍ ចន្ទុះ និងផ្លែឈើព្រៃ ។ អ៊ឹ លីម ទិញទំនិញទាំងនេះពីអ្នកស្រែនិងមេព្រៃ ។ ក្រុមគ្រួសាររបស់ អ៊ឹ លីម ប្រកបរបរនេះរហូតដល់ឆ្នាំ១៩៧០ ។

ក្រោយឆ្នាំ១៩៧០ ភូមិព្រែកសង្កែបានក្លាយទៅជាតំបន់រំដោះរបស់ខ្មែរក្រហមស្ថិតនៅក្នុងតំបន់៣០៤ ដែលមានសមមិត្ត កុយ ធួន ហៅ ធុច ជាគណៈតំបន់ ។ ភូមិព្រែកសង្កែនិងភូមិពាមកោះស្នា ស្ថិតនៅក្នុងស្រុក៦៥ (មិនមែនស្ថិតនៅក្នុងស្រុកស្ទឹងត្រង់ទេ) ។ កាលនោះកងទ័ពរំដោះខ្មែរក្រហមតែងតែចុះទៅធ្វើការនៅភូមិព្រែកសង្កែជានិច្ច ។ កងទ័ពរំដោះខ្មែរក្រហមដែលចុះមកតំបន់នេះ ភាគច្រើនជាខ្មែរតស៊ូដែលវិលត្រឡប់មកពីវៀតណាមខាងជើង ហើយស្ថិតនៅក្រោមការដឹកនាំរបស់មិត្តសាញ់,មិត្តស៊ឹម មិត្តសុទ្ធនិងមិត្តពល ។ កម្មាភិបាលទាំងនេះជាក្រុមប្រមូលផ្តុំនៅវៀតណាមភាគខាងជើងក្នុងអំឡុងពេលប្រទេសកម្ពុជាទទួលឯករាជ្យពីបារាំងឆ្នាំ១៩៥៤ ។

នៅអំឡុងឆ្នាំ១៩៧០ អ៊ឹ លីម ធ្លាប់បានទាក់ទងស្គាល់មិត្តសាញ់ មិត្តស៊ឹម មិត្តសុទ្ធ និង មិត្តពល ដើម្បីទិញថ្នាំកូតាបនៅពីអ្នកភូមិព្រែកសង្កែ និងពីអ្នកភូមិជិតខាងដែលប្រកបរបរដាំថ្នាំជក់ ។ អ៊ឹ លីម បានទិញម៉ូតូមួយគ្រឿងដើម្បីដឹកថ្នាំកូតាបយកទៅលក់នៅតំបន់ប្រទាញប្រទង់រវាងរបបលន់ណុលនិងខ្មែរក្រហម ហើយរកទិញឥវ៉ាន់ដូចជាក្រណាត់អង្រឹង ខ្សែអង្រឹង ក្រណាត់កាគី អង្ករ និង សាំង យកមកលក់ឲ្យខ្មែរក្រហមវិញ ។

អ៊ឹ លីម ប្រកបមុខរបរលក់អង្ករឲ្យខ្មែរក្រហមតាំងពីឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧៤ រួមផ្សំនិងប្រាក់កម្រៃបន្តិចបន្តួចពីការមូរបារីនិងលក់ឥវ៉ាន់ចាប់ហួយកំប៉ិកកំប៉ុកនៅក្នុងផ្ទះ ធ្វើឲ្យជីវភាពគ្រួសាររបស់អ៊ឹ លីម មានលក្ខណៈមធ្យម ។ អ៊ឹ លីម និង អ៊ឹស្រី នង គីមហេក្ក មានកូនប្រុស៥នាក់និងស្រី២នាក់ ។

នៅក្នុងឆ្នាំ១៩៧៤ អ៊ឹ ចាន់ លីម បានឮដំណឹងល្ហិចល្ហៀងពីគណៈទាក់ទងវៀតណាមប្រចាំនៅតំបន់៣០៤ ប្រកាសឲ្យប្រជាជននិងអាណិកជនវៀតណាមត្រៀមខ្លួនវិលត្រឡប់ទៅ

ប្រទេសវៀតណាមវិញ ។ ដោយសារអ៊ឹ ចាន់ លីម ជាជនជាតិខ្មែរ ទើបខាងភាគីវៀតណាមមិនអនុញ្ញាតឲ្យទៅរស់នៅប្រទេសវៀតណាម ។ អ៊ីស្រី គីមហេ្កក និងកូន ត្រូវភៀសខ្លួនទៅប្រទេសវៀតណាមជាមួយឪពុកម្តាយរបស់គាត់ ។ ចំណែក អ៊ឹ លីម ក៏បានសម្រេចចិត្តលួចធ្វើដំណើរទៅប្រទេសវៀតណាម មុនការចាកចេញរបស់ប្រពន្ធនិងកូនគាត់ទៅទៀត ។ អ៊ឹ លីម បានទៅស្នាក់នៅផ្ទះក្មួយជីដូនមួយឈ្មោះ ឆេង ហុង ស្ថិតនៅក្នុងប្រទេសវៀតណាម ។

ក្រោយថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥ ប្រពន្ធកូននិងក្រុមគ្រួសារខាងឪពុកម្តាយក្មេក អ៊ឹ លីម រួមទាំងអាណិកជនវៀតណាមជាច្រើន ដែលមកពីស្រុកនិងខេត្តផ្សេងៗ បានមកប្រមូលផ្តុំនៅព្រែកសង្កែ ដើម្បីឆ្លងមកខាងស្រុកក្រូចឆ្មារ ភូមិភាគបូព៌ា និងរកជួលរថយន្តបន្តដំណើរទៅព្រំដែនវៀតណាម ។ រដ្ឋាភិបាលវៀតណាមមិនបានយករថយន្តមកដឹកជញ្ជូនអាណិកជនវៀតណាមទាំងអស់នេះទេ គ្រាន់តែរង់ចាំជួយសម្រួលដល់ការធ្វើដំណើរតាមផ្លូវតែប៉ុណ្ណោះ ។ ក្រុមគ្រួសាររបស់អ៊ឹ លីម និងអាណិកជនវៀតណាមប្រមាណមួយពាន់គ្រួសារទៀតដែលបានទៅដល់មុន ត្រូវបានរដ្ឋាភិបាលវៀតណាមអនុញ្ញាតឲ្យចាប់ដីសង់ផ្ទះនិងរានដីធ្វើស្រែចម្ការនៅក្នុងឃុំស្នាច់ ។ ចំណែកអាណិកជនវៀតណាមមួយចំនួនទៀត ដែលបានទៅដល់ក្រោយគឺត្រូវទិញដីរៀបចំផ្ទះសម្បែងដោយខ្លួនឯង ។





ឃុំស្នាច់មានផ្ទៃដីទំហំជាង១០គីឡូម៉ែត្រការ៉េនិងមានប្រជាជនរស់នៅទីនោះជាងមួយពាន់គ្រួសារ ដែលភាគច្រើនជាអាណិកជនវៀតណាមភៀសខ្លួនមកពីស្រុកខ្មែរ ។ អាណិកជនវៀតណាមដែលភៀសខ្លួនពីស្រុកខ្មែរមួយចំនួនធំមកពីខេត្តកំពង់ធំ ទន្លេសាប កំពង់ឃ្នាំង និង សៀមរាប ។ ប្រជាជនទាំងអស់បានមករស់នៅស្នាច់ ខ្ញុំ ក្នុងខេត្តតាយនិញ ខ្លះទៀតរស់នៅធុងលុង និង ដានតី ដែលមានព្រំប្រទល់ជាប់នឹងខេត្តមណ្ឌលគិរី ហើយដែលមានចំនួនរាប់ម៉ឺននាក់ ។

នៅពេលទៅដល់ប្រទេសវៀតណាមដំបូង គ្រួសារអ៊ឹលីម មិនទាន់ទៅរានដីធ្វើចម្ការដាំស្រូវទេ គឺប្រកបរបរលក់ដូរបន្តិចបន្តួច ។ អ៊ឹ ចាន់ លីម ជាអ្នកឡើងទៅទិញឥវ៉ាន់នៅទីក្រុងព្រៃនគរយកមកឲ្យប្រពន្ធគាត់លក់នៅផ្ទះ ។ ការលក់ដូរបន្តិចបន្តួចនេះពុំបានធ្វើឲ្យជីវភាពគ្រួសារអ៊ឹ លីម ធូរធារទេ គឺរឹតតែមានសភាពធុនដាបឡើងៗ ។ រហូតដល់ឆ្នាំ១៩៧៧ អ៊ឹ ចាន់ លីម បានសម្រេចចិត្តនាំកូនប្រុសច្បងពីរនាក់ ដែលអាចជួយធ្វើការងារបានខ្លះៗ ទៅកាប់ព្រៃបានដីប្រមាណ២ហិកតាដើម្បីដាំស្រូវ ។ ដីនៅជាប់របងខាងក្រោយផ្ទះមានទទឹង១០ម៉ែត្រនិងបណ្តោយប្រហែល ២០០ម៉ែត្រត្រូវដាំដំឡូងនិងអំពៅ ។

ព្រឹកព្រលឹមនៅក្រោយថ្ងៃសែនក្បាលទឹកមួយថ្ងៃ អ៊ីស្រី គីមហេ្កក ដែលកំពុងមានផ្ទៃពោះកូនទី៨និងកូនប្រុសច្បងពីរនាក់បានទៅចម្ការ ចម្ងាយប្រមាណ៤គីឡូម៉ែត្រពីព្រំដែនកម្ពុជា ។ នៅតំបន់នេះ កងទ័ពខ្មែរក្រហមបានវាយចូលចំនួនពីរលើកមកហើយ ។ វៀតណាមក៏បានវាយរុញច្រាននិងសម្រុកចូលទឹកដីកម្ពុជា រួចហើយក៏ដកថយទៅវិញ ។ ក្រោយមក កងទ័ពខ្មែរក្រហមបានវាយសម្រុកចូលរហូតមកដល់ចំការស្រែរបស់អ៊ឹ លីម ។ ពេលនោះ អ៊ីស្រី គីមហេ្កក និងកូនប្រុសទី១ឈ្មោះទីគា កូនប្រុសទី២ ឈ្មោះ ផេង ទើបតែធ្វើដំណើរដល់ស្រែ ក៏ត្រូវកងទ័ពខ្មែរក្រហមចាប់ខ្លួនតែម្តង ។

ពេលដែលកងទ័ពខ្មែរក្រហមចាប់ប្រពន្ធនិងកូន អ៊ឹ លីម មិនបាននៅផ្ទះទេ ព្រោះគាត់រវល់ទៅទិញឥវ៉ាន់នៅទីក្រុងព្រៃនគរ ។ ក្រោយពីបានទទួលដំណឹងនេះ អ៊ឹលីម មានការតក់ស្លុតយ៉ាង

ខ្លាំង ។ ចំណែកឯកូនតូចៗទាំង៥នាក់ទៀត របស់អ៊ឹ លីម ស្រែកយំរកម្តាយទ្រហឹងពេញផ្ទះ ដែលកាន់តែធ្វើឲ្យអ៊ឹ លីម អាណោចអធម៌ថែមទៀត ។

អ៊ឹ លីម នៅចាំបានថា ប្រពន្ធនិងកូនរបស់គាត់ត្រូវកងទ័ពខ្មែរក្រហមចាប់ខ្លួននៅក្នុងខែសីហា ឆ្នាំ១៩៧៨ ។ ចំណែករូបថតរបស់អ៊ឹស្រី គីមហ៊ុក និងកូនប្រុសទី១របស់គាត់ ក៏មានពាក់ផ្លាកលេខបញ្ជាក់ពីកាលបរិច្ឆេទមកដល់គុកទួលស្លែងដែរ គឺនៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៨ ។ នៅក្នុងរូបថតរបស់អ៊ឹស្រី នង គីមហ៊ុក និងកូនប្រុសទី១ សរសេរថា «នង គីមវើត» និង «ចូវីគា» ។

នៅចុងឆ្នាំ១៩៧៩ អ៊ឹ លីម បាននាំកូននិងក្រុមគ្រួសារឪពុកម្តាយក្មេកត្រឡប់មករស់នៅស្រុកខ្មែរវិញ ។

នៅក្នុងឆ្នាំ១៩៨១ អ្នកភូមិព្រែកសង្កែម្នាក់ឈ្មោះ ហុង ជា បានមកលេងភ្នំពេញ ហើយបានចូលទៅមើលសារមន្ទីរទួលស្លែង ។ ហុង ជា បានប្រទះឃើញរូបថតអ៊ឹស្រីនិងរូបថតកូនប្រុសម្នាក់ព្យួរនៅលើជញ្ជាំង ។ ហុង ជា បាននាំដំណឹងនេះទៅប្រាប់អ៊ឹ លីម និងក្រុមគ្រួសារ ។ គ្រាន់តែទទួលដំណឹងថាប្រពន្ធនិងកូនត្រូវជាប់នៅគុកទួលស្លែង អ៊ឹ លីម កាន់តែរន្ធត់ចិត្តទ្វេឡើង ។ គាត់មិនអាចមកសារមន្ទីរទួលស្លែងមើលរូបថតប្រពន្ធនិងកូនឡើយ ។ ប្អូនថ្លៃអ៊ឹ លីម ឈ្មោះ ហុង និងកូនៗរបស់អ៊ឹ លីម បានទៅមើលរូបថតម្តាយនិងបងប្រុស ហើយបានថតយករូបថតមកទុកគោរពបូជារហូតដល់សព្វថ្ងៃ ។

ទោះបីរឿងរ៉ាវប្រពន្ធនិងកូនរបស់អ៊ឹ ចាន់ លីម បានកន្លងទៅអស់រយៈពេលជាងម្ភៃឆ្នាំហើយក៏ដោយ ក៏អ៊ឹ លីម នៅតែមិនអាចបំភ្លេចបាន ។ នៅក្នុងចិត្តរបស់អ៊ឹ លីម តែងដិតជាប់នូវរូបភាពប្រពន្ធនិងកូនជានិច្ច ។

នៅរដូវបុណ្យចូលឆ្នាំប្រពៃណីចិន-វៀតណាម សែនក្បាលទឹក ចូលឆ្នាំប្រពៃណីខ្មែរ បុណ្យភ្ជុំបិណ្ឌ អ៊ឹ លីម តែងតែសែនព្រេនម្ហូបអាហារឧទ្ទិសដល់វិញ្ញាណក្ខន្ធប្រពន្ធនិងកូនជានិច្ច ។ អ៊ឹ លីម មិនដែលហ៊ានអុជធូបខ្លួនឯងនៅចំពោះមុខរូបថតប្រពន្ធគាត់ទេ ។ គាត់បានឲ្យកូនៗអុជធូបជំនួសគាត់ ពីព្រោះគាត់មិនអាចអត់ទ្រាំនឹងភាពសោកសង្រេងបានឡើយ នៅពេលឃើញមុខប្រពន្ធរបស់គាត់ ។

អ៊ឹ លីម បានមានប្រសាសន៍ទៀតថា គាត់ចង់បានតុលាការឯករាជ្យមួយដើម្បីវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម រកយុត្តិធម៌ឲ្យប្រពន្ធកូននិងប្រជាជនស្លូតត្រង់ទាំងអស់ដែលបានស្លាប់ក្រោមរបបខ្មែរក្រហម ប៉ុន្តែការទន្ទឹងរង់ចាំរបស់អ៊ឹ លីម បេះតែអូសបន្លាយយូរទៅៗ ធ្វើឲ្យក្តីសង្ឃឹមរបស់គាត់ចំពោះការស្វែងរកយុត្តិធម៌ជូនប្រពន្ធនិងកូនកាន់តែថយចុះជាលំដាប់ ។

**ឡុង ដានី**

## ទស្សនៈខ្មែរក្រហម ដូចម្តេចដែលហៅថារបបប្រជាធិបតេយ្យ?

**(ឯកសារលេខ D ២១៥០៩)**

ប្រជាជន របបប្រជាធិបតេយ្យ ប្រជាជនមានលក្ខណៈដូចខាងក្រោមនេះ÷

**ខាងនយោបាយ**

គឺស្ថិតនៅក្រោមការផ្តាច់ការនៃវណ្ណៈបដិវត្តទាំង៤ កម្មករ កសិករ អនុធន នាយទុនជាតិ និងបុគ្គលចម្រើនស្នេហាជាតិ ដោយឈរលើសម្ព័ន្ធភាព កម្មករ កសិករ ក្រោមការដឹកនាំនៃវណ្ណៈតាមរយៈបក្ស ។

**ខាងសេដ្ឋកិច្ច**

១) សេដ្ឋកិច្ចរដ្ឋត្រូវអូសទាញពីចក្រពត្តិនិយម សក្តិភូមិ ប្រតិកិរិយា នូវដើមទុនដើម្បីកសាងសេដ្ឋកិច្ចជាតិ ។

២) សេដ្ឋកិច្ច ចម្រុះរដ្ឋត្រូវចូលហ៊ុនជាមួយនាយទុនជាតិ នូវដើមទុនដើម្បីកសាងសេដ្ឋកិច្ចជាតិ ។

៣) សហករណ៍រដ្ឋត្រូវប្រមូលកម្លាំងផ្តុំកសិករ ដើម្បីបង្កបង្កើនផលរួម ។ ៤) សេដ្ឋកិច្ចឯកជន រដ្ឋទុកឲ្យបង្កើតផលដំណាំដើម្បីផ្គត់ផ្គង់ចិញ្ចឹមគ្រួសារតាមការកំណត់ ។

**ខាងវប្បធម៌**

វប្បធម៌ត្រូវមានលក្ខណៈជាតិ វិទ្យាសាស្ត្រ លក្ខណៈប្រជាជននេះ ដូច្នេះរបបដែលហៅថា របបប្រជាធិបតេយ្យប្រជាជននេះគឺជាគ្រឹះដើម្បីឈានទៅកសាងនូវរបបសង្គមថ្មី គឺសង្គមនិយមក្នុងប្រទេសខ្មែរ ។

# ខ្មែរកម្ពុជាក្រោមក្នុងគំនិតខ្មែរក្រហម

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរកម្ពុជាក្រោម គឺជាប្រជាជនដែលត្រូវបានខ្មែរក្រហមរើសអើង ។ បើមើលពីសំបកក្រៅខ្មែរកម្ពុជាក្រោមមានលក្ខណៈខុសប្លែកពីខ្មែរកណ្តាលបន្តិចបន្តួចតែប៉ុណ្ណោះ ចំពោះសម្លៀកបំពាក់និងសំនៀងនិយាយ ។

នៅដើមឆ្នាំ១៩៧៧ អំឡុងពេលដែលខ្មែរក្រហមធ្វើសង្គ្រាមជាមួយវៀតណាម អង្គការស្រុកបាកានបានបញ្ជាឲ្យគណៈសហករណ៍ដើរស្រង់ប្រវត្តិរូបខ្មែរកម្ពុជាក្រោម ។ បន្ទាប់ពីស្រង់ប្រវត្តិរូបរួចហើយ នៅដើមខែវស្សាឆ្នាំដដែល ខ្មែរកម្ពុជាក្រោមទាំងអស់ត្រូវបានប្រមូលផ្តុំឲ្យទៅរស់នៅភូមិបាក់មែក ឃុំខ្នាទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ នៅក្នុងភូមិបាក់មែក ខ្មែរកម្ពុជាក្រោមត្រូវរស់នៅក្នុងកងដាច់ដោយឡែកពីអ្នកស្រុកទូទៅ ។ ក្រោយមក ខ្មែរកម្ពុជាក្រោមទាំងអស់ត្រូវអង្គការយកទៅសម្លាប់ជាបន្តបន្ទាប់ដោយចោទថាខ្មែរយៈវៀតណាម ។

គឹម សូ រស់នៅក្នុងឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ បាននិយាយថា នៅចុងឆ្នាំ១៩៧៧ អង្គការបានកោះហៅខ្មែរកម្ពុជាក្រោមទាំងអស់មកប្រជុំ ព្រោះគឺជា "ដំណាក់កាលត្រូវបោសសម្អាតខ្មែរយួនទាំងអស់" ។ បន្ទាប់ពីប្រកាសយ៉ាងដូច្នេះហើយ កម្មាភិបាលខ្មែរក្រហមបានចាប់ផ្តើមយកខ្មែរកម្ពុជាក្រោមទៅសម្លាប់ចោល ។ ក្នុងចំណោមជនរងគ្រោះខ្មែរកម្ពុជាក្រោមទាំងអស់ដែលត្រូវបានសម្លាប់នោះ មានឪពុកម្តាយនិងបងប្អូនបង្កើតរបស់ គឹម សូរ ចំនួន៩នាក់ និងសាច់ញាតិជាច្រើនទៀត ។ ចំណែកឯ គឹម សូ ត្រូវអង្គការចាប់ដាក់គុក ដោយចោទថាជាខ្មែរក្បត់អង្គការ ។ គឹម សូ បានអះអាងថា ឪពុកម្តាយបងប្អូន និងសាច់ញាតិរបស់គាត់ រួមទាំងខ្លួនគាត់ មិនដែលស្គាល់ពាក្យថា ខ្មែរយួនឬខ្មែរក្បត់ទាល់តែសោះ ។

ខ្មែរកម្ពុជាក្រោមត្រូវអង្គការចោទប្រកាន់ថា"ក្បាលយួនខ្លួនខ្មែរ" ។ ការសម្លាប់មនុស្សនៅក្នុងឃុំរំលេច គឺសំដៅយកខ្មែរកម្ពុជាក្រោម ។ ប្តីឬប្រពន្ធដែលមានសញ្ជាតិខ្មែរ អាចមានផ្លូវ២សម្រាប់ជ្រើសរើស គឺទី១តាមប្តីឬប្រពន្ធ ទី២មិនតាម ។ ចំពោះអ្នកដែលសម្រេចចិត្តថាតាម នឹងត្រូវយកទៅសម្លាប់ជាមួយគ្នា ។ អ្នកដែលមិនទៅតាមនឹងបានរស់ ។ រីឯកូន បើចង់ទៅតាមឪពុកឬម្តាយដែលអង្គការយកទៅសម្លាប់នោះក៏ត្រូវសម្លាប់ដែរ ។ ក្រោយពេលសម្លាប់សាច់ញាតិដែលជាខ្មែរកម្ពុជាក្រោមអស់ហើយ ខ្មែរក្រហមបានរៀបចំឲ្យអ្នកដែលនៅរស់ជាពោះម៉ាយ ឬមេម៉ាយត្រូវរៀបការជាមួយគ្នា ។ ធ្វើបែបនេះ ដើម្បីកុំឲ្យអាឡោះអាល័យជាមួយ "ខ្មាំងយួន" តទៅទៀត ។


ង៉ែត ឡូយ

ង៉ែត ឡូយ មានប្តីជាខ្មែរកម្ពុជាក្រោម ។ នៅពេលដែលអង្គការមានផែនការយកប្តីរបស់ ង៉ែត ឡូយ ទៅសម្លាប់ ប្រធានកងឈ្មោះ យាយភុប បានមកប្រាប់ ង៉ែត ឡូយ ថាប្តីរបស់គាត់ (ង៉ែត ឡូយ) ត្រូវទៅកាប់ពោតនៅព្រៃធំ ។ ង៉ែត ឡូយ មានការសង្ស័យ ក៏សុំមិនទៅជាមួយប្តីទេ ។ ដោយដឹងថា ង៉ែត ឡូយ ជាខ្មែរ យាយភុប ក៏យល់ព្រម ។ ចំណែកកូនទាំងអស់របស់ ង៉ែត ឡូយ ក៏មិនឲ្យទៅជាមួយឪពុកដែរ ។ ក្រោយពីសម្លាប់ប្តីរបស់ ង៉ែត ឡូយ អស់រយៈពេល២ខែ អង្គការបានតម្រូវឲ្យ ង៉ែត ឡូយ រៀបការជាមួយបុរសម្នាក់ដែលមានប្រពន្ធជាខ្មែរកម្ពុជាក្រោម ហើយដែលត្រូវបានអង្គការយកទៅសម្លាប់រួចហើយ ។

ចំពោះការសម្លាប់ប្រជាជនខ្មែរកម្ពុជាក្រោមនៅក្នុងឃុំរំលេច ឌឹក ប៊ុនរឿន ជាប្រធានភូមិរំលេច ដែលបានរស់នៅក្នុងសហករណ៍រំលេច បាននិយាយថា ការសម្លាប់មាន៣ដំណាក់

កាលៈ ដំណាក់កាលទី១និងទី២នៅក្នុងឆ្នាំ១៩៧៧ ខ្មែរកម្ពុជាក្រោមត្រូវអង្គការយកទៅសម្លាប់នៅព្រៃកាបៅ ឃុំតាលោ ស្រុកបាកាន និងដំណាក់កាលទី៣គឺនៅដើមឆ្នាំ១៩៧៨ សម្លាប់នៅសេះញ្ញូវក្នុងឃុំខ្នារទទឹង ខេត្តពោធិ៍សាត់។ ប៊ុនរឿន បានឃើញការនាំយកប្រជាជនខ្មែរកម្ពុជាក្រោមទៅសម្លាប់នៅដំណាក់កាលទី១និងទី២ដោយផ្ទាល់ភ្នែក។ ប៊ុនរឿន បានអះអាងថា ដំណាក់កាលទី១ ខ្មែរក្រហមបានយកខ្មែរកម្ពុជាក្រោមទៅសម្លាប់ចំនួន៣៥០គ្រួសារនិងដំណាក់កាលទី២ ចំនួន២០០គ្រួសារ។


ប្រាក់ សារិន

ប្រាក់ សារិន រស់នៅក្នុងភូមិរំលេចតាំងពីឆ្នាំ១៩៦៤រហូតមក បាននិយាយថា នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងភូមិរំលេច មានខ្មែរកម្ពុជាក្រោមរស់នៅជាង៥០០គ្រួសារដែលមានមនុស្សប្រមាណបីទៅបួនពាន់នាក់។ មកដល់របបកម្ពុជាប្រជាធិបតេយ្យ ខ្មែរកម្ពុជាក្រោមដែលរស់នៅក្នុងភូមិរំលេចត្រូវអង្គការសម្លាប់ចោលទាំងអស់។

ចំណែកនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ក៏មានការមិនទុកចិត្តនិងសម្លាប់ខ្មែរកម្ពុជាក្រោម ដូចជានៅស្រុកបាកាន ខេត្តពោធិ៍សាត់ដែរ។ អ៊ិន ញ៉ាន់ រស់នៅក្នុងស្រុកត្រាំកក់ តាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ រហូតដល់បច្ចុប្បន្នរស់នៅក្នុងស្រុកនេះដដែល។ អ៊ិន ញ៉ាន់ បាននិយាយថា នៅពេលរំដោះឆ្នាំ១៩៧៥ អង្គការបានប្រមូលប្រជាជនខ្មែរកម្ពុជាក្រោមចំនួន៧០គ្រួសារ ដែលមកពីកន្លែងផ្សេងៗ ឲ្យទៅរស់នៅជុំគ្នាមួយកន្លែង។ ក្រោយមក អង្គការបានហៅខ្មែរកម្ពុជាក្រោមទាំងអស់នោះមកប្រជុំ ហើយបាននិយាយក្នុងពេលនោះថា «បើបងប្អូនណាចង់ត្រឡប់ទៅស្រុកវិញ អង្គការនឹងឧបត្ថម្ភជាក្រណាត់និងស្បៀងអាហារសម្រាប់ការធ្វើដំណើរ»។ ប៉ុន្តែនៅពេលដែលខ្មែរកម្ពុជាក្រោមទាំងនោះប្រាប់ថាចង់ទៅស្រុកកំណើតអង្គការក៏យកទៅសម្លាប់ ព្រោះមានជាប់«និន្នាការវៀតណាម»។

នៅក្នុងរបាយការណ៍មួយដែលរៀបរាប់ពីការធ្វើបញ្ជីខ្មែរកម្ពុជាក្រោមនៅក្នុងឃុំអង្គតាសោម ស្រុកត្រាំកក់ ក្នុងខែមេសា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានប្រើពាក្យ“នៅស្រុកយួន”និង“យួន” ជំនួសពាក្យ“ខ្មែរកម្ពុជាក្រោម”។ ក្រៅពីរបាយ-ការណ៍នេះ មានបញ្ជីឈ្មោះខ្មែរកម្ពុជាក្រោមដែលរស់នៅក្នុងស្រុកត្រាំកក់ជាច្រើនទៀត។

ជាត់ សមុទ្រ ជាអតីតកុមារទទួលភ្ញៀវនៅស្ថានីយ៍ស្ទាត់អូឡាំពិកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បាននិយាយថា ក្នុងពេលដែលបញ្ហានៅតាមព្រំដែនកម្ពុជា-វៀតណាមមានសភាពតឹងតែងក្នុងអំឡុងឆ្នាំ១៩៧៧-៧៨ សមមិត្ត ប៉ុល ពត បានហៅខ្មែរកម្ពុជាក្រោមជាច្រើនមកប្រជុំដើម្បីអប់រំគោលជំហរ។ ពេលនោះជាត់ សមុទ្រ ក៏បានចូលរួមដែរ។ ប៉ុល ពត បាននិយាយថា ចំពោះបងប្អូនខ្មែរកម្ពុជាក្រោម បើអ្នកណាដើរតាមអង្គការនឹងអាចរស់ តែបើមិនដើរតាមអង្គការមិនទុកទេ។

នៅមន្ទីរស-២១ ជាមន្ទីរសន្តិសុខថ្នាក់មជ្ឈិម ក៏មានការឃុំឃាំងនិងសម្លាប់អ្នកទោសខ្មែរកម្ពុជាក្រោមដែរ។ តាមរយៈឯកសារដែលបានរកឃើញនៅក្នុងមន្ទីរស-២១ មានអ្នកទោសខ្មែរកម្ពុជាក្រោមចំនួន៤០នាក់ត្រូវបានបញ្ជូនមកមន្ទីរស-២១ គឺនៅឆ្នាំ១៩៧៥ចំនួន៥នាក់ ឆ្នាំ១៩៧៦ចំនួន១៨នាក់ ឆ្នាំ១៩៧៧ចំនួន៦នាក់ និងឆ្នាំ១៩៧៨ចំនួន១២នាក់។ តាមឯកសារដដែលនេះ អ្នកទោសខ្មែរកម្ពុជាក្រោម៨នាក់ត្រូវសម្លាប់នៅក្នុងឆ្នាំ១៩៧៧ និងក្នុងឆ្នាំ១៩៧៨មានចំនួន៣នាក់។ ចំណែកអ្នកទោសមួយចំនួនទៀតមិនបានចុះកាលបរិច្ឆេទចាប់ខ្លួននិងសម្លាប់ទេ។

យឿង កែវ គឺជាខ្មែរកម្ពុជាក្រោមម្នាក់ត្រូវបានបញ្ជូនមកស-២១នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៨ និងត្រូវសម្លាប់នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៨ ដោយសារក្នុងចម្លើយរបស់គាត់បានសារភាពថាជាចារបុរសវៀតណាម ទទួលបញ្ជាឲ្យមកស៊ើបការណ៍នៅប្រទេសកម្ពុជា។

នាង សាង ជាសមាជិកតំបន់ព្រះវិហារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដើមឆ្នាំ១៩៧៨ នាង សាង ត្រូវអង្គការបញ្ជូនមកមន្ទីរស-២១ និងធ្វើទារុណកម្មនៅថ្ងៃទី១៩ ខែមេសា




ឆ្នាំ១៩៧៨ ។ នាង សាង បានសារភាពថា ខ្លួនពិតជាចារកម្មវៀតណាមបង្កប់ក្នុងជួររណសិរ្សមែន ជាពិសេសបង្កប់ក្នុងគណៈមជ្ឈិមបក្សកុម្មុយនិស្ត ។

ក្នុងរយៈពេលសង្គ្រាមរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមកងទ័ពខ្មែរក្រហមបានចាប់ប្រជាជនខ្មែរកម្ពុជាក្រោមដែលរស់នៅតាមព្រំដែន បញ្ជូនមកមន្ទីរ ស-២១យ៉ាងច្រើន ។

ការសិក្សាមួយអំពីជោគវាសនាខ្មែរកម្ពុជាក្រោមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកំពុងតែដំណើរការ ។ នៅក្នុងការសិក្សានេះមានកង្វះខាតឯកសារជាច្រើន ។ ប្រសិនបើមិត្តអ្នកអានមានពត៌មានឬឯកសារផ្សេងៗ ដែលទាក់ទងនឹងប្រធានបទសិក្សានេះ សូមទាក់ទងមកនាងខ្ញុំតាមទូរស័ព្ទលេខ(០២៣) ២១១ ៨៧៥ ប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ។

**គីម កែវកន្និដ្ឋា**

ពីមន្ទីរពេទ្យពិសេសរបស់អង្គការ
ថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧

## មកអាផាកូនស្រីសម្លាញ់ឪពុក

ឪពុកមានគ្រោះថ្នាក់ធំណាស់ ដោយពួកសេ.អ៊ី.អា ដាក់ថ្នាំបំពុលប៉ងសម្លាប់ឪពុក ។

សព្វថ្ងៃអង្គការកំពុងយកចិត្តទុកដាក់ព្យាបាលសង្គ្រោះនៅមន្ទីរពេទ្យពិសេសរបស់អង្គការ ។ មិនដឹងជាសង្គ្រោះបានមិនបានទេ... ។ កុំចង់ទៅសួរអីព្រោះល័ក្ខការណ៍ ។

១៩៦៨ រូបកូនឯងត្រូវឲ្យពួកអាក្បត់ លន់ ណុល ផ្នែកបម្រើអាមេរិកចាប់ដាក់គុកធ្វើទារុណកម្មព្រៃផ្សៃ ។

ថ្ងៃនេះ សេ.អ៊ី.អា អាមេរិកបន្តព្យាបាទសម្លាប់ឪពុកទៀត ។

សូមកូនចងគំនុំជាតិនិងគំនុំវណ្ណៈចំពោះអាចក្រពត្តិសេ.អ៊ី.អា អាឃ្នូនលេបទឹកដី អាកា.សេ.បេ (សើរើសូវៀត) តពូជតពង្សរហូតទៅ ។ នាំប្អូនៗចូលសហករណ៍ កសិករ សមូហភាពក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាដ៏ត្រឹមត្រូវតែមួយគត់ ប្រយុទ្ធទល់ខ្មាំង និងកសាងកម្ពុជាប្រជាធិបតេយ្យសង្គមនិយមឲ្យសម្បូរសប្បាយរុងរឿង ដោយល្បឿនមហាលោតផ្លោះមហាអស្ចារ្យ ។

អាថានៅតាខ្មៅជាមួយតាជាម្ដាយកូនឯង នៅមន្ទីរតម្បាញនិងកាត់ដេរ ស្រុកកណ្ដាលស្ទឹង ។ កុំចាំបាច់ទៅមកអី (ដំណើរផ្លូវលំបាក) ខំតែធ្វើការនិងកសាងខ្លួននិងប្អូនៗក្នុងចលនាសមូហភាពក្រោមការដឹកនាំរបស់បក្សទៅបានហើយ ។

នៅជាមួយមីងរហូតទៅព្រោះមីងឯងឈឺច្រើនណាស់ អត់អ្នកណាជួយមើលទេ ។ នាំគ្នារស់ក្នុងសហករណ៍ភូមិនោះទៅ ។

ឪពុកសូមលាកូនសំឡាញ់ដោយគំនិតជាតិនិងវណ្ណៈចំពោះចក្រពត្តិសេ.អ៊ី.អា អាឃ្នូនលេបទឹកដីកដីនឹងអាកា.សេ.បេរហូតដល់ស្លាប់ ។

ឪពុកសូមថើបកូនពីចម្ងាយ លាទាំងអាល័យនឹងចុកចាប់ជាទីបំផុត ។ ជយោបក្សកុម្មុយនិស្តកម្ពុជាដ៏ត្រឹមត្រូវនិងភ្លឺស្វាងមហាអស្ចារ្យ ។ ៤-៥-៧៧

ទុំ (ឪពុករបស់កូន)

**(ឯកសារលេខ J៩០០បបគ១)**

# ការជួបជុំគ្នាឡើងវិញរបស់អតីតយុទ្ធជនមន្ទីរស-២១

អតីតយុទ្ធជននៃមន្ទីរស-២១ (គុកទួលស្លែង) ចំនួនប្រាំមួយនាក់ ស្ថិតក្នុងសម្លៀកបំពាក់ចម្រុះពណ៌ ខុះបង់ក្រមានៅលើស្មាតាមទម្លាប់ជាអ្នកស្រែចម្ការ បានធ្វើដំណើរមួយៗចូលទៅក្នុងបរិវេណសារមន្ទីរទួលស្លែង ។ អ្នកទាំងនេះបានជួបជុំគ្នាម្តងទៀតនៅសារមន្ទីរទួលស្លែង តាមការស្នើសុំរបស់លោក ប៉ាន់ ឫទ្ធី ដើម្បីថតខ្សែភាពយន្តឯកសារ ។ អស់រយៈពេល២៣ឆ្នាំហើយដែលអតីតយុទ្ធជនទាំងនេះបានចាកចេញពីគុកទួលស្លែង ដែលជាកន្លែងឃុំឃាំងមនុស្សយ៉ាងសាហាវព្រៃផ្សៃបំផុត ។

កាលពី២៥ឆ្នាំមុន អ្នកទាំងនេះបានចូលមកគុកទួលស្លែងក្នុងតួនាទីជាអ្នកចាប់អ្នកទោស អ្នកសួរចម្លើយអ្នកទោស អ្នកការពារអ្នកទោស អ្នកធ្វើបញ្ជីឈ្មោះអ្នកទោស និងអ្នកប្រហារជីវិតអ្នកទោស ។ អ្នកទាំងនេះបានប្រាប់ថា ខ្លួនធ្វើការងារទាំងអស់នោះ ដើម្បីជាផ្លូវសម្រាប់ការរស់រានមានជីវិតតែប៉ុណ្ណោះ ។ គ្រប់គ្នាបានសម្លឹងមើលដោយរន្ធត់ចិត្តចំពោះកេរដំណែលនៃរបបខ្មែរក្រហមនៅសារមន្ទីរទួលស្លែង ថ្វីដ្បិតតែធ្លាប់បានធ្វើការនៅទីនេះអស់រយៈពេលជិតបីឆ្នាំក៏ដោយ ។

ប្រាក់ ខន អតីតអ្នកសួរចម្លើយអ្នកទោស បាននិយាយថា «នៅពេលដែលខ្ញុំចូលមកដល់កន្លែងនេះវិញ ខ្ញុំមានការរន្ធត់ចិត្តចំពោះរឿងរ៉ាវកាលពីមុន ពីព្រោះទីនេះជាកន្លែងសោកនាដកម្ម ។ ខ្ញុំមានអារម្មណ៍អៀនខ្មាសខ្លួនឯងដែលបានប្រព្រឹត្តអំពើឃោរឃៅទាំងអស់នេះ ក៏ប៉ុន្តែការភ័យខ្លាចនាពេលនេះមិនដល់ក្នុងសម័យខ្មែរក្រហមទេ ។ ពេលនោះ បើយើងមិនធ្វើតាមបញ្ជាគេទេ យើងនឹងឆាប់ស្លាប់បំផុត» ។


ប្រាក់ ខន
ឆ្នាំ២០០២

ទោះបីជាយ៉ាងណាក៏ដោយ ក៏អតីតកាលរបស់អ្នកទាំងប្រាំមួយរូបមិនទាន់ជ្រះស្រឡះពីអារម្មណ៍នៅឡើយដែរ ។ នេះដោយសាររឿងរ៉ាវខ្មែរក្រហមមិនទាន់ត្រូវបានយកមកជំនុំជម្រះក្តីតាមផ្លូវច្បាប់ ។ ម្នាក់ៗបាននិយាយថា ខ្លួនធ្លាប់ទទួលរងនូវពាក្យត្មះតិះដៀលពីអ្នកស្រុក ចំពោះទង្វើនិងតួនាទីរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ញ៉ៀប ហូ អតីតកងការពារអ្នកទោស បាននិយាយថា «អ្នកស្រុកបានហៅខ្ញុំថា«មេអាពត» ។ អ្នកស្រុកអ្នកភូមិភាគច្រើនបានដឹងថាខ្ញុំធ្លាប់ធ្វើការនៅគុកទួលស្លែង ។ ខ្ញុំមិនខឹងគេទេ ព្រោះ ខ្ញុំធ្លាប់ធ្វើពីមុនមកមែន ។ ខ្ញុំមិនតូចចិត្តទេ ប៉ុន្តែខ្ញុំអាណិតប្រពន្ធនិងកូនរបស់ខ្ញុំ» ។

នៅអំឡុងឆ្នាំ១៩៨០ អតីតយុទ្ធជននៅមន្ទីរស-២១ ភាគច្រើនត្រូវបានកោះហៅទៅអប់រំនិងមួយចំនួនត្រូវបញ្ជូនខ្លួនទៅមន្ទីរឃុំឃាំង ។


សួស ធី
ឆ្នាំ១៩៧៧

សួស ធី អតីតអ្នកកាន់បញ្ជីឈ្មោះអ្នកទោសត្រូវរដ្ឋអំណាចខេត្តកណ្តាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ឃុំឃាំងខ្លួននៅក្នុងគុកងងឹតអស់រយៈពេលបួនឆ្នាំ ។ ហ៊ិម ហ៊ុយ អតីតអនុប្រធានកងការពារអ្នកទោស ត្រូវជាប់គុកនៅខេត្តកណ្តាលអស់រយៈពេលពីរឆ្នាំ ។ សួស ធី បាននិយាយ


សួស ធី
ឆ្នាំ២០០២

# អតីតយុទ្ធជន



រូបថតដោយៈ ឆាំង យុ
ឆ្នាំ២០០២ ថតនៅទួលស្លែង

ខៀវ ចេស ហៅ ពៅ

ហ៊ីម ហ៊ុយ

# ះ មន្ទីរស-២១



ជាម សឿ

ញៀប ហូ

ថា "ខ្ញុំនៅតែមិនអស់ចិត្ត ។ មិនយុត្តិធម៌សោះដែលខ្ញុំធ្វើការនៅក្រោមការបង្គាប់បញ្ជារបស់គេ បែរជាជាប់គុក ចំណែកឯមេធំៗបែរជារួចខ្លួន ។ របបសម្លាប់មនុស្សគឺអ្នកទាំងនោះជាអ្នកបង្កើតឡើង ។ ពួកមេធំៗត្រូវតែនាំកាត់ទោសតាមច្បាប់ ។ ខ្ញុំនិយាយនេះមិនមែនយកតែរួចខ្លួនទេ ពីព្រោះធ្វើរបៀបនេះទើបយុត្តិធម៌" ។ ប្រាក់ ខន បានបន្ថែមថា "ខ្ញុំធ្វើបាបធ្វើទោសគេមែន ប៉ុន្តែក៏ត្រូវគិតពីយុត្តិធម៌ដែរ" ។

ឆ្លើយតបនឹងមេដឹកនាំខ្មែរក្រហមដែលនិយាយថា មិនបានស្គាល់គុកទួលស្លែង សួស ធី បានបញ្ជាក់ថា "គុកទួលស្លែងធំណាស់ មិនមែនតូចតាចទេ គឺមួយគីឡូម៉ែត្របួនជ្រុង ។ អ្នកបង្កើតគុកនេះទាល់តែថ្នាក់ធំទើបអាចបង្កើតបាន ហើយអ្នកទោសដែលចាប់មកមានទូទាំងប្រទេស ។ អ្នកណាដែលហ៊ានទៅចាប់តាមភូមិភាគតាមបន្ទាយដោយគ្មានបទបញ្ជា" ។ ញ៉េប ហូ បន្ថែមថា "គុកទួលស្លែងសម្លាប់មនុស្សជាប្រចាំ តើក្នុងពេលនោះសមមិត្តធំៗនៅឯណា? រឿងនេះមិនពិបាកសោះ គ្រាន់តែសួរ ឌុច ប្រធានគុកទៅដឹងហើយ" ។

ហ៊ឹម ហ៊ុយ បានហៅមន្ទីរស-២១ថា ជា"កន្លែងចូលហើយគ្មានថ្ងៃចេញ" ។ បន្ថែមលើតួនាទីជាអនុប្រធានកងការពារអ្នកទោស ហ៊ុយ មានតួនាទីចាប់អ្នកទោសបញ្ជូនមកកាន់មន្ទីរស-២១ និងដឹកជញ្ជូនអ្នកទោសពីមន្ទីរស-២១យកទៅសម្លាប់នៅបឹងជើងឯក ។ ហ៊ុយ ទទួលស្គាល់ថា គាត់ធ្លាប់បានសម្លាប់អ្នកទោសចំនួនប្រាំនាក់ដោយវាយនឹងដែកភ្លៅរទេះ ។ គាត់និយាយថា "ខ្ញុំមិនចង់ធ្វើខុសទេ ប៉ុន្តែមកពី ឌុច និង ហ៊ី គាបសង្កត់ខ្ញុំ ។ បើខ្ញុំមិនធ្វើតាម ពួកគេនឹងសម្លាប់ខ្ញុំ" ។

មន្ទីរស-២១ដែលស្ថិតនៅក្រោមការដឹកនាំរបស់ ឌុច បានចាប់ផ្តើមការងារនៅដើមឆ្នាំ១៩៧៦ ។ ក្នុងការជ្រើសរើសឲ្យមកបម្រើការនៅមន្ទីរស-២១ យុទ្ធជនភាគច្រើនមិនត្រូវបានប្រាប់ឲ្យដឹងជាមុនឡើយ ។ អ្នកទាំងនោះតែងតែត្រូវបានភូតភរថា អង្គការត្រូវបញ្ជូនទៅថ្នាក់លើឬទៅធ្វើការជាមួយប្រជាជន ។ បន្ទាប់ពីចូលមកដល់មន្ទីរស-២១ យុទ្ធជនទាំងអស់គ្មានឱកាសនឹងចេញទៅវិញបានឡើយ ។

នៅចុងឆ្នាំ១៩៧៦ ខៀវ ចេស ត្រូវគណៈសាលាបច្ចេកទេសយោធានៅស្ទឹងព្រែកត្នោត បញ្ជូនមកមន្ទីរស-២១ ដោយនិយាយប្រាប់ថា ត្រូវទៅនៅជនបទជាមួយប្រជាជន ។ ខៀវ ចេស បានមកបម្រើការងារនៅមន្ទីរស-២១ ក្នុងតួនាទីជាកងការពារអ្នកទោស ។ ចេស បានរំឭកថា យុទ្ធជនបម្រើការងារនៅមន្ទីរស-២១ជាច្រើននាក់ ត្រូវបានចាប់ខ្លួនយកទៅសម្លាប់ចោល ដោយចោទថាធ្វើខុសនឹងមាគ៌ាអង្គការ ។

ខៀវ ចេស បានបន្តទៀតថា "នៅពេលខ្ញុំសម្លឹងមើលរូបថតអ្នកទោសដែលព្យួរនៅលើជញ្ជាំង ធ្វើឲ្យខ្ញុំនឹកឃើញដល់អ្នកទោសជាច្រើនដែលត្រូវបានបណ្តើរចូលមកក្នុងគុក ហើយខ្ញុំបាននៅយាមអ្នកទាំងនោះ ។ ខ្ញុំនៅចាំថា ខ្ញុំធ្លាប់ឮសំឡេងស្រែករបស់អ្នកទោស ។ ខ្ញុំនឹកឃើញសមមិត្តភក្តិខ្ញុំម្នាក់ឈ្មោះ ហុង ដែលធ្លាប់ធ្វើការនៅក្នុងក្រុមជាមួយខ្ញុំ ហើយត្រូវចាប់ខ្លួនយកទៅសម្លាប់ចោល ។ ហុង បានផ្តាំខ្ញុំថា "បើឯងនៅមានជីវិតបានត្រឡប់ទៅភូមិស្រុក ជួយប្រាប់ម៉ែអញផង ថាអញងាប់ហើយ" ។

យុទ្ធជននៅមន្ទីរស-២១ ត្រូវបានបង្ខំឲ្យធ្វើការងារបម្រើបដិវត្តន៍ ដោយមិនត្រូវគិតពីឪពុកម្តាយនិងបងប្អូនឡើយ ។

ជាម សឿ អតីតយុទ្ធជនកងការពារអ្នកទោសបាននិយាយថា "ឌុច មិនដែលអនុញ្ញាតឲ្យខ្ញុំទៅលេងផ្ទះជួបជុំឪពុកម្តាយម្តងណាឡើយ ។ កាលពីមុនកន្លែងនេះគួរឲ្យខ្លាចបំផុត ។ ចាប់តាំងពីខ្ញុំចាកចេញពីកន្លែងនេះ ខ្ញុំមិនដែលនឹកគិតថានឹងមកកន្លែងនេះទៀតទេ ។ គុកទួលស្លែងជាកន្លែងឃុំឃាំងនិងធ្វើទារុណកម្មអ្នកទោសយ៉ាងសាហាវព្រៃផ្សៃ ។ ឥឡូវនេះ ទួលស្លែងបានក្លាយទៅជាកន្លែងចងចាំសម្រាប់ប្រជាជនកម្ពុជា" ។

អតីតយុទ្ធជនមន្ទីរស-២១ ទាំងប្រាំមួយនាក់បាននិយាយដូចៗគ្នាថា "នៅក្នុងរបបខ្មែរក្រហមយើងគិតតែពីខំធ្វើការរៀងៗខ្លួន ។ យើងមិនអាចជួបជុំនិងជជែកលេងជាមួយគ្នាដូចពេលនេះទេ ។ ការជំនុំគ្នាគឺជាទោសឧក្រិដ្ឋ ។ នៅពេលដែលយើងបានជួបជុំគ្នារំឭកពីរឿងអតីតកាលឡើងវិញ ធ្វើឲ្យយើងមានអារម្មណ៍ធូរស្បើយ" ។ អ្នកទាំងនេះបានត្រៀមខ្លួនជានិច្ចនឹងឡើងទៅបំភ្លឺតុលាការជាសាធារណៈ ប្រសិនបើការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហមត្រូវការរូបគាត់ទាំងអស់គ្នា ។ **ហ៊ុយ ខណ្ណៈ**



ខៀវ ចេស
ឆ្នាំ១៩៧៧



ហ៊ឹម ហ៊ុយ
ឆ្នាំ១៩៧៦



ញ៉ែប ហូ
ឆ្នាំ១៩៧៧

# ភ្នាក់ងារផ្តាច់ព្រលឹង: បរិយាយអំពីការប៉ះទង្គិចផ្លូវអារម្មណ៍តាមលក្ខណៈ ចិត្តសាស្ត្រសង្គម នៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា

មានមនុស្សច្រើនណាស់មកសួរខ្ញុំថា «តើធ្វើដូចម្តេចបាន ជាប្រជាកសិករខ្មែរដែលធ្លាប់តែត្រូវបានចាត់ទុកថាជាជនជាតិដែលមានចរិតសុភាពរាបសា ញញឹមប្រិមប្រិយ និងស៊ីវិល័យ ប្រែក្លាយទៅជាជនបដិវត្តន៍ដែលចូលមកក្នុងទីក្រុងភ្នំពេញ នៅថ្ងៃ១៧ខែមេសាប្រកបដោយទឹកមុខកាចសាហាវទៅវិញ?»

នៅពេលមានភាពមិនស៊ីគ្នា(ពោលគឺមិនស្រណុកក្នុងចិត្ត) កើតឡើង វានឹងធ្វើឲ្យមនុស្សព្យាយាមបន្ថយភាពមិនស្រណុកក្នុងចិត្ត ហើយឈានទៅសម្រេចបាននូវលទ្ធផលសុខស្រួលវិញ ។

ជាញឹកញយ មនុស្សជាច្រើនតែងតែបានចាត់ទុកកម្ពុជាថាជា«ទឹកដីស្ងប់ស្ងៀម» ដែលមានពុទ្ធសាសនិកប្រកាន់អហិង្សាក្នុងខ្លួន ហើយតែងតែគួរសម រាក់ទាក់ និងញញឹមញញែមជានិច្ច ។ ប៉ុន្តែនៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ប្រទេសកម្ពុជាត្រូវទទួលរងនូវភាពរំជើបរំជួលផ្នែកសេដ្ឋកិច្ចសង្គម សង្គ្រាមស៊ីវិល ការទម្លាក់គ្រាប់បែក ហើយចុងក្រោយគឺជួបប្រទះបដិវត្តន៍សង្គមតែម្តង ។ អំឡុងពេលនោះ ក្នុងចំណោមប្រជាជន៨លាននាក់ មានប្រជាជនចំនួនប្រមាណ៦សែននាក់ត្រូវបានសម្លាប់ ។ ប៉ុន្តែនៅក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ មានប្រជាជនរហូតដល់ ១លាន៥សែននាក់ត្រូវបាត់បង់ជីវិតដោយសារជំងឺតម្កាត់ ខ្វះចំណីអាហារ ធ្វើការបាក់កម្លាំង និងការកាប់សម្លាប់ ។ ជនរងគ្រោះដែលមានវាសនារស់រានមានជីវិត សុទ្ធតែបានរៀបរាប់អំពីការធ្វើទុក្ខទោសពីសំណាក់ខ្មែរក្រហម ដូចជាការបាញ់សម្លាប់ វាយនឹងព្រនង់ ចាក់នឹងកាំបិត និងការធ្វើទារុណកម្មមកលើប្រជាជនឯង ។ អំពើហិង្សារបៀបនេះធ្វើឲ្យអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់មានចំណាប់អារម្មណ៍ ។ តើធ្វើដូចម្តេចបានជាជនជាតិខ្មែរដែលមានចរិត «ស្លូតបូត សុភាពរាបសា» បែរជាមកប្រព្រឹត្តអំពើប្រល័យពូជសាសន៍យ៉ាងដូច្នេះទៅវិញ? ។

កន្លងមក សំណួរនេះត្រូវបានបកស្រាយតាមរបៀបផ្សេងៗទៅហើយ ។ ពួកនរវិទូ(អ្នកសិក្សាអំពីមនុស្ស) មិនបានបញ្ចេញយោបល់អ្វីទៅលើអំពើប្រល័យពូជសាសន៍ក្នុងទ្រង់ទ្រាយធំនេះទេ ។ នេះជារឿងមួយចម្លែក ពីព្រោះជាធម្មតានរវិទូបានតែបង្ហាញជូននូវសមត្ថភាពរបស់ខ្លួនក្នុងការពន្យល់អំពីប្ញសគល់នៃអំពើឃោរឃៅនៅក្នុងបរិបទមិនមែនជាការប្រល័យពូជសាសន៍ ។ ដើម្បីជួយដោះស្រាយនូវកង្វះខាត បទនិពន្ធនេះនឹងផ្តល់ការពន្យល់តាមបែបចិត្តសាស្ត្រ អំពីមូលហេតុនៃការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយផ្អែកទៅលើទ្រឹស្តីភាពមិនចុះសម្រុងគ្នានៃគំនិតដែលបញ្ជាក់ន័យនិងជំរុញដោយសញ្ញាណនរវិទ្យានៃបុគ្គល គំរូវប្បធម៌ និងវេទនារម្មណ៍ ។ បន្ទាប់មក ខ្ញុំនឹងវិភាគទៅលើព្រឹត្តិការណ៍នានាដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាតាមរយៈអ្វីដែលខ្ញុំហៅថា «ភាពមិនចុះសម្រុងគ្នានៃចិត្តសាស្ត្រសង្គម» ។ តាមរយៈនោះ ខ្ញុំនឹងផ្តល់នូវចំណុចចាប់ផ្តើមនៃការពិភាក្សាបែបនរវិទ្យាទៅលើការប្រល័យពូជសាសន៍ជាទ្រង់ទ្រាយធំ បរិយាយបញ្ហាថាតើធ្វើដូចម្តេចបានជាមនុស្សធម្មតាមកប្រព្រឹត្តអំពើឃោរឃៅប្រល័យពូជសាសន៍ដូច្នេះ និងពន្យល់ពីដើមកំណើតចិត្តសាស្ត្រសង្គមនៃការប្រល័យពូជសាសន៍នៅកម្ពុជា ។

ផ្នែកទីមួយនៃអត្ថបទនេះរៀបរាប់ជាសង្ខេបអំពីទ្រឹស្តីនៃភាពមិនស្របគ្នានៃការយល់ឃើញ រួចមកនឹងបង្ហាញអំពីវិធីធ្វើយ៉ាងណាឲ្យទ្រឹស្តីនេះក្លាយទៅជាគំរូមួយនៃ «ភាពមិនចុះសម្រុងគ្នានៃចិត្តសាស្ត្រសង្គម» តាមរយៈទស្សនៈបែបនរវិទ្យា ។ បន្ទាប់មកខ្ញុំនឹងពិពណ៌នាគំរូវប្បធម៌ពីរបែបដែលលេចធ្លោជាងគេ ហើយកើតមានឡើងមុនសម័យកម្ពុជាប្រជាធិបតេយ្យ ពោលគឺ«សីលធម៌ស្លូតបូតសុភាពរាបសា» (អហិង្សា) និង«សីលធម៌ប្រឡោងខាម» (ហិង្សា) ។ វគ្គទីបី បង្ហាញពីមូលហេតុដែលនាំឲ្យគំរូទាំងនេះក្លាយទៅជាមិនចុះសម្រុងគ្នា នៅពេលដែលខ្មែរក្រហមប៉ុនប៉ង

កែប្រែសង្គមកម្ពុជាទាំងស្រុង ដែលជាការបង្កើតឲ្យមានស្ថានភាពប្រឆាំងគ្នាខាងផ្លូវចិត្តសាស្ត្រ ។ បន្ទាប់មកទៀត ខ្ញុំនឹងបង្ហាញនូវចំណាត់ការមួយចំនួនដែលរបបខ្មែរក្រហមបានប្រើប្រាស់ដើម្បីជួយកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តនូវ«ភ្នាក់ងារផ្តាច់ព្រលឹង»របស់ខ្លួន ។ វគ្គទីបួន បង្ហាញពីរបៀបថាតើធ្វើដូចម្តេចបានជាកម្មាភិបាលខ្មែរក្រហម ដែលមួយផ្នែកផ្អែកទៅលើ «ការឆ្លើយតបពីរដ្ឋ» ចាត់វិធានការតាមការយល់ឃើញដើម្បីកាត់បន្ថយការប៉ះពាល់អារម្មណ៍របស់ខ្លួន ដូចជា«ការឆ្លើយតបពីបុគ្គលផ្ទាល់ខ្លួន» ។ ខ្ញុំទាញសេចក្តីសន្និដ្ឋានដោយពិភាក្សាពីចំណាប់អារម្មណ៍អំពីភាពមិនចុះសម្រុងគ្នា សម្រាប់ការសិក្សាបែបនរវិទ្យាទៅលើការប្រល័យពូជសាសន៍ក្នុងទ្រង់ទ្រាយធំ ។

### គំរូមួយនៃ«ការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គម» ដោយការដឹងឮឬយល់ឃើញ

លីអូន ស៊ីងជ័រ បានបង្កើតទម្រង់ដើមនៃ«ការប៉ះពាល់អារម្មណ៍ដោយការយល់ឃើញ» ដែលបកស្រាយថាៈ ប្រសិនបើមនុស្សម្នាក់មានការយល់ឃើញពីរយ៉ាងខុសគ្នា បុគ្គលរូបនេះច្បាស់ជាចង់កាត់បន្ថយភាពមិនស្រណុកក្នុងចិត្តមិនខាន ។ ឧទាហរណ៍ ក្រោយពីឮរបាយការណ៍និយាយថាការជក់បារីមានផលប៉ះពាល់ដល់សុខភាព អ្នកជក់បារីជាច្រើននឹងចង់កាត់បន្ថយភាពមិនស្រណុកក្នុងចិត្តជាមិនខាន ដោយផ្លាស់ប្តូរការដឹងឮទាំងឡាយរបស់ខ្លួន ដើម្បីធ្វើយ៉ាងណាឲ្យខ្លួនមានអារម្មណ៍ធម្មតាវិញ ដូចជាកម្ចាត់របកគំហើញនេះចេញពីខួរក្បាល ដោយខំបន្ថែមការដឹងថ្មីៗទៀត ដូចជាខំរកពត៌មានដែលបង្ហាញថាការជក់បារីមិនសូវមានគ្រោះថ្នាក់ (ដូចជាបើកឡានទេ) ឬដោយផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនតែម្តង (ឈប់ជក់បារីជាដើម) ។ កាលណា«ទំហំ»នៃការប៉ះទង្គិចផ្លូវអារម្មណ៍កាន់តែធំ នឹងធ្វើឲ្យបុគ្គលនោះកាន់តែចង់កាត់បន្ថយការប៉ះពាល់អារម្មណ៍កាន់តែខ្លាំងដែរ ។

ទ្រឹស្តីនេះបានធ្វើឲ្យមានការសិក្សាស្រាវជ្រាវច្រើនណាស់ ដែលការស្រាវជ្រាវភាគច្រើនបានបញ្ជាក់ថា ការប៉ះទង្គិចផ្លូវអារម្មណ៍តាមការដឹងឮគឺអស្ចារ្យណាស់ នៅពេលដែលបុគ្គលម្នាក់មានការតាំងចិត្តប្រកាន់យកអាកប្បកិរិយាការយល់ដឹងមួយឬទាំងពីរដែលមានទំនាស់នឹងគ្នា ។ ការរកឃើញតាមការពិសោធន៍របៀបនេះ ព្រមជាមួយការមិនពេញចិត្តដែលចេះតែកើនឡើង និងភាពស្រពេចស្រពិលទាក់ទងនឹងការបង្កើតទម្រង់ទ្រឹស្តីដើមនៃការប៉ះទង្គិចផ្លូវអារម្មណ៍ បានធ្វើឲ្យ អេលៀត អារ៉ូនសុន អះអាងថា ការប៉ះទង្គិចផ្លូវអារម្មណ៍ដោយការដឹងឮ «គឺច្បាស់លាស់និងសម្បើមណាស់ ។ វាពាក់ព័ន្ធមិនត្រឹមតែការដឹងយល់ពីរនោះទេ ប៉ុន្តែថែមទាំងពាក់ព័ន្ធការយល់ដឹងអំពីខ្លួនឯងផង និងផ្នែកមួយនៃអាកប្បកិរិយារបស់យើងដែលរំលោភទៅលើការយល់ឃើញរបស់ខ្លួនយើងផ្ទាល់» ។ ដូច្នេះការប៉ះទង្គិចផ្លូវអារម្មណ៍កើតឡើងនៅក្នុងស្ថានភាពដែលមនុស្សម្នាក់ត្រូវប្រឈមមុខនឹងកាយវិការដែលរំពឹងទុកថាមិនស៊ីគ្នាជាមួយគំនិតខ្លួនឯង ។

ទ្រឹស្តីនៃការប៉ះទង្គិចផ្លូវអារម្មណ៍ដោយការដឹងឮ និងការបង្កើតទម្រង់ថ្មីរបស់ទ្រឹស្តីនេះ ផ្តល់នូវការយល់ដ៏ជ្រៅទៅក្នុងគំនិតនិងអាកប្បកិរិយារបស់មនុស្ស ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ គំនិតនេះត្រូវបានសំអាងដោយផ្អែកលើមូលដ្ឋានមួយចំនួននៃចិត្តវិទ្យាបែបលោកខាងលិច ។ តាមទស្សនៈបែបនរវិទ្យា ការសិក្សាស្រាវជ្រាវទៅលើការប៉ះពាល់ផ្លូវអារម្មណ៍នេះមានបញ្ហាមួយចំនួននៅក្នុងៈ ១) ប្រព្រឹត្តកម្មទៅលើទំនាក់ទំនងរវាងវប្បធម៌និងភាពផ្សេងៗគ្នារបស់បុគ្គលម្នាក់ៗ ២) គន្លះទ្រឹស្តីនៃហេតុបណ្តាលឲ្យធ្វើអ្វីមួយ ៣) ការយកចិត្តទុកដាក់មិនបានគ្រប់គ្រាន់ទៅលើភាពសាំញ៉ាំដែលពាក់ព័ន្ធ ៤) ការឲ្យតម្លៃទៅលើគំនិតខ្លួនឯងច្រើនជាង ៥) ការមិនផ្តល់សេចក្តីគោរពទៅលើអារម្មណ៍ ។ ប៉ុន្តែផ្ទុយទៅនឹងទ្រឹស្តីនេះ យើងអាចរំពុកសាឡើងវិញនូវគំនិតនេះ ដោយផ្អែកតាមការវិវឌ្ឍខាងទ្រឹស្តីអំពីគំរូវប្បធម៌បុគ្គលនិងអារម្មណ៍ ។

### ការផ្តល់ផលតាមបែបនរវិទ្យាៈ គំរូវប្បធម៌និងបុគ្គល

បញ្ហាទី១ - វប្បធម៌ៈ ក្នុងខណៈដែល ហ្វេស ស៊ីងហ្គ័រ បានបញ្ចូលថា «វប្បធម៌»ជាប្រភពដ៏សំខាន់នៃការប៉ះទង្គិចផ្លូវអារម្មណ៍នៅក្នុងទម្រង់ដើមរបស់ទ្រឹស្តីនៃការប៉ះពាល់ផ្លូវអារម្មណ៍ដោយការដឹងឮ វប្បធម៌មិនដែលត្រូវបានយកមកអនុវត្តតាមរបៀបទំនើបនៅក្នុងការស្រាវជ្រាវក្រោយៗមកទេ ។ ប៉ុន្តែការវិវឌ្ឍថ្មីៗនៅក្នុងផ្នែកនរវិទ្យាបែប «ការដឹងឮ» បានបំពេញចន្លោះរវាង

វប្បធម៌និងការយល់ដឹងតាមរយៈទស្សនៈនៃគម្រោងនៃការយល់ដឹង ឬរចនាសម្ព័ន្ធនៃចំណេះដឹង ដែលតាមរយៈនេះ មនុស្សបកស្រាយធាតុសម្រាប់ជំរុញ ហើយសម្រេចឆ្លើយតបតាមអាកប្បកិរិយាផ្សេងៗ ។

ការវិវត្តដ៏សំខាន់ដែលនរវិទូទាំងឡាយបានធ្វើឡើង គឺជាការបង្ហាញថា គម្រោងនៃចំណេះដឹងជាច្រើនមានការរួមផ្សំជាមួយវប្បធម៌ ។ នៅពេលដែលគ្មានការទាក់ទងគ្នារវាងគំរូវប្បធម៌និងវិធីដែលគំរូទាំងនេះត្រូវបានស្រូបទាញដោយសារកត្តាសង្គមផ្សេងៗគ្នានោះ ភាពអាចផ្លាស់ប្តូរបានរបស់បុគ្គលម្នាក់ៗត្រូវបានទប់ដោយភាសានិងរួមផ្សំជាមួយបទពិសោធន៍សង្គមបន្តិចបន្តួច ។ ឧទាហរណ៍ ពេលទៅភោជនីយដ្ឋានណាមួយ សេចក្តីរំពឹងទុកនិងអាកប្បកិរិយារបស់សមាជិកសង្គមរបស់យើងត្រូវបានសម្រួលដោយ"នាដកថាភោជនីយដ្ឋាន" (ដែលមានដូចជាការចូលភោជនីយដ្ឋាន ការហៅមុខម្ហូបមកទទួលទាន និងពេលចេញទៅវិញ) ដែលអ្នកទាំងនោះបានដឹងឮតាំងពីក្មេងៗ បទពិសោធន៍ខ្លួនឯងផ្ទាល់ ការសម្តែងនៅតាមទូរទស្សន៍សៀវភៅ ។ល ។ កម្លាំងមួយនៅក្នុងចំណោមកម្លាំងទាំងឡាយរបស់ទ្រឹស្តីនៃ"គំរូវប្បធម៌"គឺសមត្ថភាពក្នុងការបង្ហាញអំពីទំនាក់ទំនងរវាងរចនាសម្ព័ន្ធចំណេះដឹងផ្ទាល់ខ្លួននិងគំរូសង្គម ។ តាមរយៈការភ្ជាប់ការដឹងឮជាមួយនឹងវប្បធម៌ ទស្សនៈនៃគំរូវប្បធម៌ផ្តល់នូវមធ្យោបាយនានាសម្រាប់ធ្វើឲ្យវប្បធម៌មានការបញ្ចូលគ្នាជាមួយទ្រឹស្តីនៃការប៉ះពាល់ផ្លូវអារម្មណ៍ដោយការដឹងឮ ។

*បញ្ហាទី២-កត្តាជំរុញៈ* ទ្រឹស្តីនៃការប៉ះទង្គិចផ្លូវអារម្មណ៍ខុះនូវទស្សនៈគ្រប់គ្រាន់នៃកត្តាជំរុញ ។ ហ្វេស ស៊ីងហ្គ័រ បានអះអាងតាំងពីដំបូងថា មនុស្សចង់កាត់បន្ថយការប៉ះទង្គិចផ្លូវអារម្មណ៍តាមរបៀបមួយប្រហាក់ប្រហែលនឹងការកាត់បន្ថយភាពញ្ញាណ ។ នៅពេលដែលការណែនាំរបស់ អារ៉ូនសុន អំពីទស្សនៈចំពោះខ្លួនឯង បន្ថែមនូវការបញ្ជាក់កាន់តែច្បាស់ទៅលើ"ប្រអប់ខ្មៅ"នេះ ដំណើរការដែលជាមូលដ្ឋាននៃកត្តាជំរុញរបស់ការប៉ះពាល់ផ្លូវអារម្មណ៍ដោយការដឹងឮនោះ នៅតែមិនមានលក្ខណៈច្បាស់លាស់ដដែល ។ ដូច្នេះទស្សនៈនៃកត្តាជំរុញត្រូវបានរៀបរាប់នៅក្នុងការសិក្សាស្រាវជ្រាវអំពីគំរូវប្បធម៌នោះ អាចនាំមកនូវការបញ្ជាក់កាន់តែច្បាស់លាស់ថែមទៀត ដែលត្រូវការចាំបាច់ទៅលើទ្រឹស្តីនៃ"ការប៉ះទង្គិចផ្លូវអារម្មណ៍ដោយការដឹងឮ" ។

នរវិទូសិក្សាខាងខួរក្បាលបានទាញហេតុផលថា កត្តាជំរុញអាចយកមកពន្យល់តាមលក្ខណៈសាំញ៉ាំជាងនេះទៅទៀត ទាក់ទងនឹងគម្រោងទាំងនេះ ដោយសារគម្រោងទាំងនេះតែងតែបង្កើតនូវគោលដៅនានាដែលជំរុញឲ្យមានអំពើ ។ កត្តាជំរុញនេះ ជួយទៅនឹងការដែលគ្រាន់តែឆ្លើយតបទៅនឹងធាតុជំរុញឲ្យមានសេចក្តីក្លាហានពីខាងក្នុងខ្លួនមក ។ ដូច្នេះនៅក្នុងក្របខ័ណ្ឌនាដកថាភោជនីយដ្ឋាន ការមិនពេញចិត្តនឹងការបម្រើអាចជំរុញឲ្យមនុស្សម្នាក់ប្តឹងទៅថៅកែហាងឬអ្នកមើលការខុសត្រូវក្នុងហាង ។ ជាការសំខាន់ណាស់ក្នុងការទទួលស្គាល់ដំណើរការរៀបចំនៃគម្រោងនៅក្នុងខួរក្បាល ។ នៅក្នុងករណីនេះគម្រោងនៃ"ការបម្រើមិនពេញចិត្ត"គឺជាធាតុផ្សំមួយនៅក្នុងនាដកថាភោជនីយដ្ឋានកម្រិតខ្ពស់ ។ ក្នុងខណៈដែលគម្រោងកម្រិតទាបអាចមានទំនាក់ទំនងជាមួយគំរូដទៃទៀត ដូចជា "គម្រោងទិញអីវ៉ាន់" ឬ "គម្រោងជួសជុលរថយន្ត" ការបកស្រាយនានាហាក់ដូចជាត្រូវបានបន្តទៅដល់"កម្រិតខ្ពស់បំផុតនៃការបកស្រាយដែលជាធម្មតាភ្ជាប់ទៅនឹងអំពើដែលសរីរាង្គធ្វើចលនានៅក្នុងបរិយាកាសរបស់វា ។ ពោលគឺ គម្រោងខ្ពស់បំផុតនោះទោរទន់ក្លាយទៅជាគោលដៅ" ។ ដោយសារគម្រោងកម្រិតខ្ពស់ជាគំរូវប្បធម៌នោះ នាំឲ្យវប្បធម៌ជាអ្នកកំណត់គោលដៅ ។ ដូច្នេះវាជាកម្លាំងជំរុញ ។

គំរូវប្បធម៌ក៏ត្រូវបានចាប់យកដោយមិនដឹងខ្លួនតាមវិធីផ្សេងៗដោយកត្តាផ្សេងៗពីគ្នា ។ ឧទាហរណ៍មានគំរូមួយ ។ ចំពោះគំរូនេះមនុស្សខ្លះធ្វើព្រងើយកន្តើយ ចំណែកអ្នកផ្សេងទៀតបែរជាចាប់អារម្មណ៍ខ្លាំង ។ នៅករណីនីមួយៗ សារសំខាន់នៃគំរូដែលមានលក្ខណៈជំរុញ នឹងខុសគ្នាទៅតាមកម្រិតដែលត្រូវបានចាប់យកដោយមិនដឹងខ្លួន និងទៅតាមកម្រិតកម្លាំងឆ្លងដែលគំរូនេះមាន ។ ដើម្បីសម្រេចចំណុចលេចធ្លោរបស់គំរូវប្បធម៌សម្រាប់បុគ្គលម្នាក់ វាជាការសំខាន់ក្នុងការយល់អំពីអ្វីដែលមានកម្រិតប្រហាក់ប្រហែលអ្វីដែលគំរូនេះបានទទួលកម្លាំងអារម្មណ៍នៅពេលប្រវត្តិជីវិតរបស់បុគ្គលនោះ ។ ប៉ុន្តែគំរូខ្ពស់

បំផុតដូចជា"មានលក្ខណៈជាធម្មជាតិ" និងហាក់ជំរុញឲ្យមនុស្សជាច្រើនសម្តែងអាកប្បកិរិយានៅក្នុងសង្គមណាមួយ ដូចជា"សិទ្ធិរបស់បុគ្គល" និង "សមភាព"នៅសហរដ្ឋអាមេរិក ។

*បញ្ហាទី៣ៈ អត្ថន័យផ្សេងៗគ្នាទៅតាមបរិបទ*

ទ្រឹស្តីនៃការប៉ះពាល់អារម្មណ៍ដោយការដឹងពុ តែងតែទទួលស្គាល់សារសំខាន់នៃការគិតគូរដល់កត្តាស្ថានភាព ។ ទ្រឹស្តីនេះខ្វះខាតលក្ខណៈវិនិច្ឆ័យដែលត្រូវកំណត់ថាតើការយល់ដឹងណាខ្លះដែលលេចធ្លោនៅក្នុងបរិបទណាមួយនោះ ។ ទ្រឹស្តីគំរូវប្បធម៌អាចផ្តល់ជាតម្រុយនេះ ។ បន្ថែមទៅលើភាពខុសគ្នារវាងបុគ្គលនិងបុគ្គល សារសំខាន់នៃគម្រោងទាំងនេះក៏ខុសគ្នាទៅតាមបរិបទសង្គម ។ ហេតុដូចនេះ នៅពេលនាដកថានៅភោជនីយដ្ឋានមួយនាំមកនូវអាកប្បកិរិយានៅពេលមនុស្សទៅបរិភោគបាយខាងក្រៅ មានមនុស្សមួយចំនួនតូចដើរតាមលំដាប់លំដោយនៃហេតុការណ៍នេះនៅពេលដែលខ្លួនបរិភោគបាយ នៅផ្ទះ ។ គម្រោងផ្សេងនេះអាចមិនដូចគ្នាទៅនឹងលំនាំដើម ។ ដើម្បីកំណត់ថាតើ គម្រោងនៃការយល់ដឹងមានការទាក់ទងនៅក្នុងស្ថានការណ៍បែបនេះ អ្នកសិក្សាស្រាវជ្រាវត្រូវតែបញ្ជាក់ឲ្យបានច្បាស់នូវសាវតារដែលបង្កើតលំដាប់លំដោយនៃការទាក់ទងគ្នា ដោយប្រើការវិភាគប្រវត្តិជីវិត ការសង្កេតតាមអាកប្បកិរិយា និង/ឬការសិក្សាទៅលើការអនុវត្តជាក់ស្តែងនៃការរស់នៅតាមបែបផែនសង្គម ។

*បញ្ហាទី៤ៈ ខ្លួនឯងផ្ទាល់*

អ្នកសិក្សាខាងការប៉ះទង្គិចផ្លូវអារម្មណ៍ដោយការដឹងពុបានរកឃើញថា ការប៉ះពាល់ផ្លូវអារម្មណ៍គឺមានសភាពខ្លាំងជាងគេនៅក្នុងស្ថានការណ៍ទាំងឡាយដែលតម្រូវឲ្យស្តែងនូវអាកប្បកិរិយាដែលរំលោភលើទស្សនៈផ្ទាល់ខ្លួន ។ អារ៉ុនសុន បាននិយាយថា ភាពមិនស្រណុកក្នុងចិត្តកើតឡើងដោយសារមនុស្សពុះពារចង់"រក្សានូវទស្សនៈមួយថា គំនិតខ្លួនឯងល្អត្រឹមត្រូវដូចគ្នា នឹងន អាចទាយទុកបាន...មានសមត្ថភាព..." ។ ប៉ុន្តែនរវិទូបានកត់សម្គាល់ថា គំនិតដ៏ជ្រុលនិយមឲ្យតម្លៃខ្លួនឯងនេះបំភ្លេចចោលការពិតដែលថា ទស្សនៈគិតលើខ្លួនឯងអាចខុសគ្នាទៅតាមបរិបទសង្គម ។

ឧទាហរណ៍ កាធីរីន វីង (ឆ្នាំ១៩៩០) បានស្នើនូវ "គំរូពឹងពាក់តែលើខ្លួនឯង" ដែលក្នុងនោះ មនុស្សត្រូវបានយល់ថាមានទស្សនៈគិតតែពីគំនិតខ្លួនឯងច្រើនហើយមិនដូចគ្នា ដែលត្រូវបានកំណត់ទៅតាមបរិបទនៅអំឡុងពេលកំណត់ណាមួយជាក់លាក់ ។

ដើម្បីជាការបញ្ជាក់ចំណុចរបស់ខ្លួនអ្នកស្រី វីង ពិពណ៌នាអំពីវិធីធ្វើយ៉ាងដូចម្តេចបានជាអ្នកផ្តល់ព័ត៌មានជនជាតិជ៉ាមីស្ថានឈ្មោះ ហ្សាមីម ប្រកាន់យកនូវការអះអាងខុសគ្នាស្រឡះអំពីខ្លួននាងផ្ទាល់ ដូចជាធ្វើជា "កូនស្រីល្អ" ដែលគោរពនិងធ្វើតាមសេចក្តីប្រាថ្នារបស់ឪពុកម្តាយ នឹងក្លាយជាភរិយាល្អ ព្រមទាំងក្លាយជា"អ្នកនយោបាយ"មួយរូបដែលប្រើយុទ្ធសាស្ត្រផ្សេងៗដើម្បីសម្រេចបាននូវគោលដៅអប់រំ (ឬគោលដៅការងារ) នៅក្នុងបរិបទខុសៗគ្នា ។ យើងអាចប្រើសញ្ញាណបែបនរវិទ្យានៃការគិតដោយខ្លួនឯង ដែលបានឲ្យនិយមន័យទៅតាមបរិបទនោះដើម្បីឲ្យអត្ថន័យទៅលើទ្រឹស្តីនៃការប៉ះទង្គិចផ្លូវអារម្មណ៍ដោយការយល់ដឹង ។ ជាពិសេស ផ្ទុយទៅនឹងការកើតឡើងនៃគំនិតនេះ នៅពេលដែលគំនិតសំខាន់បំផុតរបស់ខ្លួនត្រូវបានរំលោភនោះ ការប៉ះពាល់ផ្លូវអារម្មណ៍អាចត្រូវបាននិយាយថាបានកើតឡើងនៅពេលមនុស្សម្នាក់សម្តែងចេញតាមវិធីទាំងឡាយណាដែលរំលោភការបង្ហាញចេញអំពីខ្លួនឯង តាមការឲ្យនិយមន័យទៅតាមបរិបទ ។

*បញ្ហាទី៥ៈ វេទនារម្មណ៍*

គំរូនៃការប៉ះទង្គិចផ្លូវអារម្មណ៍តាមការដឹងពុរបស់លោកហ្វេសស៊ីងហ្គ័រ ត្រូវបានសំអាងទៅលើការសង្កត់ធ្ងន់របស់ពួកជូឌីអូ-គ្រីសស្ទៀន ទៅលើភាពដូចៗគ្នាតាមការយល់ឃើញរៀងៗខ្លួន ។ ក៏ប៉ុន្តែ នរវិទូបានបង្ហាញឲ្យឃើញថា នៅក្នុងវប្បធម៌ដទៃៗទៀត ការប៉ះទង្គិចផ្លូវអារម្មណ៍តែងតែកើតឡើងនៅក្នុងស្ថានភាពដែលមានការយល់ឃើញមិនស្របគ្នាដោយអារម្មណ៍ចំពោះនាដក ។ គំនិតដែលថា ការប៉ះទង្គិចផ្លូវអារម្មណ៍កើតឡើងនៅក្នុងស្ថានភាពដែលតម្រូវឲ្យមានអាកប្បកិរិយារំលោភទៅលើការបង្ហាញចេញដោយខ្លួនឯងដែលកំណត់ទៅតាមបរិបទនោះ គឺស៊ីគ្នាទៅនឹងគំនិតបែបនរវិទ្យាដែលថាវេទនា

អារម្មណ៍គឺជាគំនិតច្បាស់លាស់ គំនិតដែលឋប់ទៅលើអារម្មណ៍ ឋប់ក្នុងចិត្តថា«ខ្ញុំមានការជាប់ទាក់ទង» ។ ម្យ៉ាងទៀត ស្ថានភាពដែលធ្វើឲ្យខ្លួនជំពាក់ជំពិន គឺមានសារសំខាន់ណាស់ផ្នែកអារម្មណ៍ ។

បប ឌី វ៉ូស បានកត់សម្គាល់ថា ស្ទើរតែគ្រប់សង្គមមនុស្ស ចូលចុះទៅក្នុងសង្គមបានតាមរយៈអ្វីដែលគេហាមប្រាមមិនឲ្យប៉ះពាល់ ដើម្បីចៀសវាងការប្រឡោតដោយផ្ទាល់មកលើជនដែលដែលមានអត្តសញ្ញាណនិងចំណងសង្គមជាមួយគ្នា ។ ឌី វ៉ូស មានប្រសាសន៍ថា យើងមិនអាចបណ្តោយទៅតាមការប៉ះទង្គិចផ្នែកអារម្មណ៍ឬដូចពាក្យដែលខ្ញុំហៅថា«ការប៉ះទង្គិចផ្លូវអារម្មណ៍យ៉ាងធ្ងន់ធ្ងរ»ដែលកើតចេញពីការសម្លាប់នៅក្នុងចំណោមក្រុមសង្គមជាមួយគ្នាបានទេ ។ ដូចដែលយើងនឹងយល់នោះ គឺជាវិធីម្យ៉ាងក្នុងការធ្វើឲ្យមនុស្សម្នាក់លើកដៃសម្លាប់មនុស្សនៅក្នុងស្ថានភាពបែបនេះ ដើម្បីកំណត់សាជាថ្មីថាតើអ្នកណាខ្លះដែលស្ថិតក្នុងក្រុមនេះធ្វើដូច្នេះ ដើម្បីដកជនរងគ្រោះចេញពីក្រុមនិងដកសិទ្ធិជាមនុស្សដោយដាក់ងារថា«ខ្មាំង» ។ ប៉ុន្តែអ្វីដែលត្រូវកត់សម្គាល់គឺថា នៅពេលមនុស្សម្នាក់សម្តែងចេញក្នុងលក្ខណៈមួយដែលរំលោភទៅលើគំនិតខ្លួនឯងដែលត្រូវបានកំណត់ទៅតាមបរិបទនោះ (ដូចជាសម្លាប់មនុស្សម្នាក់ដែលមានអត្តសញ្ញាណដូចគ្នា) ជននោះនឹងហាក់បីដូចជាមានទម្រង់ផ្លូវអារម្មណ៍ម្យ៉ាងនៃការប៉ះទង្គិចផ្លូវអារម្មណ៍តាមការយល់ដឹង ។ ការឆ្លុះបញ្ចាំងជ្រៅបែបនេះបង្កើត គឺជាមូលដ្ឋានមួយនៃគំរូនៃការប៉ះទង្គិចផ្លូវអារម្មណ៍ផ្នែកចិត្តសាស្ត្រសង្គម ។

**ការរួមចំណែកតាមបែបនវវិទ្យាៈ គំរូមួយនៃការប៉ះទង្គិចផ្លូវអារម្មណ៍តាមចិត្តសាស្ត្រសង្គម**

តាមការពិនិត្យស៊ីជម្រៅបែបនវវិទ្យាឃើញថា ឥឡូវនេះយើងអាចរៀបចំបញ្ចូលសាជាថ្មីនូវទ្រឹស្តីនៃ«ការប៉ះទង្គិចផ្លូវអារម្មណ៍ដោយការដឹងពុ ឬយល់ឃើញ»របស់ អារ៉ូសុន ដូចខាងក្រោមនេះ÷

ការប៉ះទង្គិចផ្លូវអារម្មណ៍ដោយការដឹងពុ ឬយល់ឃើញកើតឡើងនៅពេលដែល(ភាគច្រើនជ្រាបតាមលក្ខណៈវប្បធម៌) ការលេចចេញដោយអារម្មណ៍ដឹងពុអំពី(ការជ្រាបតាមលក្ខណៈវប្បធម៌និងផ្អែកតាមបរិបទ) ខ្លួនឯងប្រឆាំងគ្នាទៅនឹងការដឹងពុ ឬយល់ឃើញដោយអារម្មណ៍មួយផ្សេងទៀតដែលផុសឡើងដោយអារម្មណ៍មួយក្រោយនេះជំរុញឲ្យមានអាកប្បកិរិយាក្នុងទម្រង់មួយដែលរំលោភលើគំនិតយល់ឃើញរបស់ខ្លួនឯងដែលផ្អែកតាមបរិបទជាក់ស្តែង ។ ដូចនេះ សុភាមីម បានជួបប្រទះនូវការប៉ះទង្គិចផ្លូវអារម្មណ៍បែបចិត្តសាស្ត្រសង្គមនៅពេលដែលម្តាយនាងទាមទារឲ្យនាងរៀបអាពាហ៍ពិពាហ៍ ដើម្បីបំពេញតួនាទីជា«កូនល្អ»(ដែលជាគំរូមួយបង្កើតជាការយល់ឃើញ


ទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៩

របស់នាងផ្ទាល់នៅក្នុងការទាក់ទងជាមួយគ្រួសារ) នោះចាប់ផ្តើមប្រឆាំងនឹងបំណងប្រាថ្នារបស់នាងក្នុងការសម្រេចគោលដៅជាអាជីពរបស់នាង ធ្វើជា«អ្នកនយោបាយវៃឆ្លាត»ជាគំរូមួយដែលប្រាប់នាងអំពីការបង្ហាញចេញដោយខ្លួនឯងនៅកន្លែងធ្វើការ ។ ដោយហេតុថាគំរូបដិបក្ខកន្លងមកនេះ បានលេចឡើងនៅក្នុង

បរិបទផ្សេងៗគ្នានោះ គំរូទាំងនេះក៏ស្ទួនគ្នា ហើយបង្កឲ្យមានការប៉ះទង្គិចផ្លូវអារម្មណ៍តាមរយៈចិត្តសាស្ត្រសង្គម ។ ដូច្នេះការប៉ះទង្គិចផ្លូវអារម្មណ៍តាមរយៈចិត្តសាស្ត្រសង្គមគឺជាផ្នែកមួយនៃការប៉ះទង្គិចផ្លូវអារម្មណ៍ដោយសារការដឹងពុំឬការយល់ឃើញ ពីព្រោះគ្រប់គំរូវប្បធម៌ទាំងឡាយគឺជាការយល់ឃើញឬការដឹងពុំដូចគ្នា ប៉ុន្តែការដឹងពុំឬការយល់ឃើញមិនមែនជាគំរូវប្បធម៌ទេ ។

កម្រិតរបស់ការប៉ះទង្គិចផ្លូវអារម្មណ៍គឺជាការលេចចេញ



ឡើងនូវអារម្មណ៍នៃការដឹងពុំឬយល់ឃើញ ។ ប្រសិនបើការក្លាយជា“កូនស្រីល្អ”មិនសំខាន់ណាស់ណាសម្រាប់ ស្បាមីម នោះម៉េះសមនាងបានត្រឹមតែទទួលការប៉ះទង្គិចផ្លូវអារម្មណ៍តាមរយៈចិត្តសាស្ត្រសង្គមក្នុងកម្រិតតិចតួចបំផុត នៅក្នុងខណៈដែលឪពុកម្តាយនាងលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ។ ក៏ប៉ុន្តែដោយសារតែធ្វើគំរូទាំងពីររវាងការធ្វើ“កូនស្រីល្អ”និងជា“អ្នកនយោបាយវៃឆ្លាត”សុទ្ធតែសំខាន់ចំពោះនាង ធ្វើឲ្យ ស្បាមីម ទទួលរងនូវការប៉ះទង្គិចផ្លូវអារម្មណ៍ដោយចិត្តសាស្ត្រសង្គមនេះយ៉ាងខ្លាំង ។ មនុស្សចង់កាត់បន្ថយការប៉ះទង្គិចផ្លូវអារម្មណ៍បែបនេះ ដោយហេតុថាការដឹងពុំឬយល់ឃើញដូចដែលលើកមកនិយាយនេះ បង្កើតជាគោលបំណងដែលតម្រូវឲ្យមានផ្លូវនានាដែលមានលក្ខណៈប្រទាំងប្រទើសនឹងគ្នា ។ នៅក្នុងករណីនេះ គោលបំណងរបស់ ស្បាមីម ក្នុងការរៀបអាពាហ៍ពិពាហណ៍ បង្កើតបានជាអាកប្បកិរិយាលំដាប់បន្តបន្ទាប់មួយដែលប្រទាំងប្រទើសដោយផ្ទាល់ទៅនឹងគោលបំណងរបស់នាងក្នុងការបង្កើនកម្រិតអាជីពជាអ្នកនយោបាយរបស់នាង ។ ខ្ញុំនឹងពិនិត្យមើលវិធីជាក់ស្តែងមួយចំនួនដែលមនុស្សប៉ុនប៉ងចង់កាត់បន្ថយការប៉ះទង្គិចផ្លូវអារម្មណ៍នេះនៅក្នុងវគ្គបន្ទាប់នេះ ។

**ទី១:** ខ្ញុំនឹងស្រាយបំភ្លឺឲ្យច្បាស់ថាតើគំរូនៃការប៉ះទង្គិចផ្លូវអារម្មណ៍ដោយចិត្តសាស្ត្រសង្គមនេះអាចអនុវត្តនៅក្នុងអំពើប្រល័យពូជសាសន៍តាមរបៀបមួយដោយយកប្រទេសកម្ពុជាមកធ្វើជាឧទាហរណ៍ជាក់ស្តែង ។ ដូចជាការកត់សម្គាល់របស់ ឌីវ៉ូស ដូចគ្នានេះដែរគឺថា នៅក្នុងសង្គមស្ទើរតែទាំងអស់មានអធិបញ្ញាប្រឆាំងនឹងការសម្លាប់សមាជិកនៃសហគមន៍ផ្សេងទៀត ។ ប៉ុន្តែក្នុងបរិបទមួយចំនួនការបំផ្លាញ“អ្នកដទៃ”តែងតែមានលក្ខណៈត្រឹមត្រូវទាំងតាមផ្លូវវប្បធម៌ និង/ឬ ផ្លូវច្បាប់ (ដូចជា យោធា ក្រុមព្រហ្មទណ្ឌ ខ្មាំងនយោបាយ) ។ ដោយសារបទដ្ឋានវប្បធម៌ប្រឆាំងនឹងការសម្លាប់ហាក់មានសន្ទុះខ្លាំងក្លាបុគ្គលមួយចំនួននៃអ្នកដែលសម្លាប់មនុស្សនោះនឹងទទួលរងនូវការប៉ះទង្គិចផ្លូវអារម្មណ៍ដោយចិត្តសាស្ត្រសង្គម ។ នៅក្នុងករណីមានអំពើប្រល័យពូជសាសន៍មានទ្រង់ទ្រាយធំ ការប៉ះទង្គិចផ្លូវអារម្មណ៍តាមចិត្តសាស្ត្រសង្គមមានសក្តានុពលនាំឲ្យមានលក្ខណៈធ្ងន់ធ្ងរ ពីព្រោះអំពើទាំងនេះច្រើនតែត្រូវបានប្រព្រឹត្តមកលើប្រជាជនដែលជាអតីតសមាជិកនៅក្នុងសង្គមតែមួយ ។ ម្យ៉ាងទៀត មានគំរូលេចធ្លោពីរទៀតដែលជំរុញឲ្យមានទំនាស់រវាងគោលបំណងពោលគឺ“សម្លាប់”និង“មិនសម្លាប់” ចាប់ផ្តើមស្ទួនគ្នានៅក្នុងបរិបទមួយដែលជាការធ្វើឲ្យ“ភ្នាក់ងារផ្តាច់ព្រលឹង”ទទួល

វេងនូវការប៉ះទង្គិចផ្លូវអារម្មណ៍យ៉ាងខ្លាំង ។ ប្រសិនបើរបបមួយចង់សម្រេចគោលដៅរបស់ខ្លួននៃការប្រល័យពូជសាសន៍ របបនោះត្រូវតែធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងបរិយាកាស ដែលនឹងកាត់បន្ថយយ៉ាងច្រើននូវកម្រិតនៃការប៉ះទង្គិចផ្លូវអារម្មណ៍ដោយចិត្តសាស្ត្រសង្គម ។

ជនដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទាំងនេះ នឹងផ្អែកទៅលើការឆ្លើយតប“ក្នុងកម្រិតរដ្ឋ” និងសម្រេចទៅតាមវិធីសាស្ត្រនានា“តាមគំនិតខ្លួនឯង” ដើម្បីកាត់បន្ថយការប៉ះទង្គិចផ្លូវអារម្មណ៍ និងឈានទៅសម្រេចបាននូវការស្រុះស្រួលផ្លូវអារម្មណ៍ជាមួយគំនិតចង់សម្លាប់មនុស្ស ។ នេះជាអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។

### ការប៉ះទង្គិចផ្លូវអារម្មណ៍ដោយចិត្តសាស្ត្រសង្គមដែលបានកើតឡើងជាក់ស្តែងៈ ករណីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

មនុស្សម្នាជាច្រើនបានចាប់អារម្មណ៍ទៅលើប្រជាជនកម្ពុជាទាំងអាកប្បកិរិយាខាងក្រៅនិងជម្រៅចិត្តខាងក្នុងខ្លួនដែលមិនសូវចេះឈ្លោះប្រកែកគ្នានៅក្នុងការរស់នៅប្រាស្រ័យទាក់ទងគ្នារាល់ថ្ងៃ ។ ដោយមានបរិយាកាសរស់នៅសុខដុមរមនាដែលជាការប្រពៃសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ជាការងាយណាស់ក្នុងការរំពុកថយក្រោយបន្តិចទាក់ទងនឹងអំពើឃោរឃៅនយោបាយដែលក្លាយជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាទៅហើយនោះ ។ អំពើឃោរឃៅបែបនេះបង្ហាញនូវអង្គហេតុពិតដែលថា នៅពេលដែលជីវិតប្រចាំថ្ងៃនៅតាមមូលដ្ឋានភូមិឃុំ (ដូចជាទំនាក់ទំនងជាមួយក្រុមគ្រួសារ អ្នកស្រុកអ្នកភូមិ ឬអង្គការ) ជារឿយៗត្រូវបានអន្តរាគមន៍ដោយគំរូវប្បធម៌ថ្នាក់លើដែលជំរុញឲ្យមានអាកប្បកិរិយាគាំទ្រសង្គមនោះ ទំនាក់ទំនងនយោបាយសង្គមកាន់តែធំ (ដូចជាទំនាក់ទំនងជាមួយ“ខ្លាំង” នៅក្នុងសកម្មភាពយោធា ការអនុវត្តច្បាប់ ឬនយោបាយជាតិ) ច្រើនតែត្រូវបានផ្តល់ព័ត៌មានដោយគំរូវប្បធម៌ដែលលេចធ្លោ តែមានលក្ខណៈបដិបក្ខនឹងគ្នាយ៉ាងខ្លាំងដែលធ្វើឲ្យកើនឡើងនូវភាពប្រទូសរ៉ាយ ។ គំរូទាំងពីរនេះហៅថា “សីលធម៌អហិង្សា” និង “សីលធម៌ហិង្សា”មានសារសំខាន់ណាស់នៅក្នុងបរិបទផ្សេងគ្នានៃការទំនាក់ទំនង ។ ដូច្នេះកម្រនឹងមានការប៉ះទង្គិចគ្នាណាស់នៅក្នុងប្រទេសកម្ពុជាមុនរបបកម្ពុជាប្រជាធិបតេយ្យ ។ ក៏ប៉ុន្តែលក្ខខណ្ឌនៃការប៉ះទង្គិចផ្លូវអារម្មណ៍ដោយចិត្តសាស្ត្រសង្គមកើតឡើងនៅពេលដែលសីលធម៌ហិង្សាត្រូវបានធ្វើទៅជាស្របច្បាប់នៅក្នុងការទាក់ទងប្រចាំថ្ងៃនៅក្នុងមូលដ្ឋានភូមិឃុំនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ លទ្ធផលគួរឲ្យសោកស្តាយគឺជាស្ថានភាពដែលក្នុងនោះអំពើឃោរឃៅបានកើតឡើងខុសពីធម្មតា ។

### សីលធម៌អហិង្សា

នៅពេលមានជម្លោះកើតឡើង ជាតិពន្ធុសាស្ត្រមួយចំនួនដែលត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាមុនសម័យកម្ពុជាប្រជាធិបតេយ្យ ធ្វើឲ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងតាមរយៈការពិពណ៌នាអំពីភាពសុខដុមរមនាជាទូទៅនៅក្នុងជីវិតរស់នៅតាមភូមិ ។ ជាក់ស្តែង ក្រោយពីចុះសិក្សាស្រាវជ្រាវអស់រយៈពេលជាង១ឆ្នាំ ម៉េ អេប៊ីហារ៉ា បានសង្កេតឃើញថាមានជម្លោះធំៗកើតឡើងតែពីរបីប៉ុណ្ណោះនៅក្នុងការទាក់ទំនងពីឃុំមួយទៅឃុំមួយ ។ កង្វះភាពចុះសម្រុងគ្នានេះគឺអាស្រ័យដោយមូលហេតុមួយចំនួន ។ សមាជិករបស់សហគមន៍មួយតែងតែមានគំនិតរួមទៅលើសាមគ្គីភាពរឹងមាំនៅក្នុងសង្គម ដែលគំនិតនេះត្រូវបានវិវឌ្ឍទៅមុខក្រោយពេលមានការសេពគប់អស់រយៈពេលរាប់ឆ្នាំ ការប្រវាស់ដៃធ្វើការ ការជួយគ្នាទៅវិញទៅមក មិត្តភាពដ៏លើសលប់ និងការភ្ជាប់សាច់ញាតិបងប្អូនសកម្មភាពនៅក្នុងមូលដ្ឋានភូមិឃុំ និងគំនិតនៃការយល់ចិត្តគ្នានិងភក្តីភាពជាមួយក្រុម ។

តាមការរស់នៅក្នុងសង្គមកម្ពុជាជាក់ស្តែងបានបង្ហាញថា នៅពេលមានការប្រាស្រ័យទាក់ទងគ្នានៅក្នុងសហគមន៍មួយ មនុស្សម្នាក់គួរតែខំព្យាយាម“រាប់អានរាក់ទាក់ជាមួយអ្នកដទៃ”ចៀសវាងបង្កជម្លោះជាមួយអ្នកដទៃ និងដើម្បីឲ្យមានទំនាក់ទំនងល្អជាមួយគ្នា ។ ប្រជាជនខ្មែរដែលរួសរាយរាក់ទាក់និងសុភាពរាបសាតែងទទួលបាននូវការគោរពពីអ្នកដទៃ ហើយការដែលគេគោរពច្រើននេះធ្វើឲ្យគាត់មានកិត្តិយស ។ ផ្ទុយមកវិញ បើអ្នកណាល្មើសនឹងរបៀបរបបរស់នៅក្នុងសង្គម នឹងត្រូវអ្នកផងនិយាយដើមពីក្រោយខ្នង និងរិះគន់យ៉ាងខ្លាំង រហូតដល់មិនចង់ជួបមុខទៀតផង ។ នៅក្នុងវប្បធម៌ដែលឲ្យតម្លៃទៅ

លើមុខមាត់ ការខ្វាចរអែង ខ្មាសគេ បានបង្ហាញអំពីការគ្រប់គ្រងដ៏មានប្រសិទ្ធភាពទៅលើអាកប្បកិរិយារបស់ខ្លួន ។

ព្រះពុទ្ធសាសនាក៏លើកតម្កើងអាកប្បកិរិយាគាំទ្រសង្គមនៅក្នុងចំណោមអ្នកស្រុកអ្នកភូមិដែរ ។ ឧទាហរណ៍វត្តអារាមជាកន្លែងពង្រឹងទំនាក់ទំនងសង្គម និងជាមជ្ឈមណ្ឌលសម្រាប់បម្រើឲ្យសកម្មភាពគ្រហស្ថ សកម្មភាពសាសនា និងអប់រំផ្នែកសីលធម៌សម្រាប់កុមារាកុមារី ។ ដោយសារជនានុជនមិនសូវយល់ដឹងអំពីភាពស្មុគស្មាញនៃទ្រឹស្តីព្រះពុទ្ធ ប៉ុន្តែដឹងច្បាស់អំពីបញ្ចសីល(សីលប្រាំ) ដែលហាមមិនឲ្យភូតភរ មិនឲ្យលួចទ្រព្យគេ មិនឲ្យលួចប្រពន្ធគេ មិនឲ្យសេពសុរា និងមិនឲ្យសម្លាប់សត្វ ។ បម្រាមទាំងប្រាំយ៉ាងនេះទាក់ទងគ្នាជាមួយការយល់ឃើញពីកម្មនិងផលដែលជំរុញឲ្យអ្នកស្រុកអ្នកភូមិរក្សាបាននូវទំនាក់ទំនងល្អជាមួយគ្នា ។

ទោះបីជាមានអំពើហិង្សាខ្លះនៅក្នុងគ្រួសារកើតឡើងក៏ដោយ ក៏ការទំនាក់ទំនងផ្ទៃក្នុងដូចជាជីវិតរួមរស់ជាមួយគ្នាជាទូទៅនៅតែមានសុខដុមរមនាដដែល ។ សមាជិកគ្រួសារត្រូវបានចងភ្ជាប់គ្នាដោយការរកទទួលទាន ទំនាក់ទំនងសង្គមរៀងរាល់ថ្ងៃ ការចែករំលែកគ្នា និងការចូលរួមក្នុងពិធីបុណ្យទានផ្សេងៗ ។ ភាពសុខដុមរមនាក៏បានជំរុញដោយអតិថិវិន័យដែរ ។ ដូចជាសង្គមខ្មែរទូទៅដែរ គ្រួសារបង្កើតជាឋានានុក្រមដែលជនជាតិខ្មែរត្រូវតែសម្តែងការគោរពក្នុងកម្រិតផ្សេងៗគ្នាទៅតាមអាយុនិងភេទ ។ រឿងព្រេងនិទាន កំណាព្យ ដែលមានលក្ខណៈប្រៀនប្រដៅនិងភាសាសីលធម៌ថ្លៃថ្នូរ បានជំរុញឲ្យមានគំរូអាកប្បកិរិយាសមរម្យ ។ អាកប្បកិរិយាសមរម្យថ្លៃថ្នូរនេះអាចរក្សាបាននូវទំនាក់ទំនងល្អនិងរំសាយជម្លោះ ។ ការខ្វាចក្រែងភូមិករឬព្រលឹងដូនតាអាចធ្វើឲ្យសមាជិកក្នុងគ្រួសារមានជំងឺតម្កាត់ នៅពេលកូនចៅឈ្លោះគ្នានោះ បានផ្តល់ជាកម្លាំងដ៏ធំមួយសម្រាប់ទប់ស្កាត់នូវអាកប្បកិរិយាមិនសមសួន ។ តម្លៃនិងការអនុវត្តជាក់ស្តែងទាំងនេះគឺជាផ្នែកមួយរបស់គំរូវប្បធម៌កម្រិតខ្ពស់ដែលជំរុញឲ្យមានការចង់ចិត្តទៅរកអាកប្បកិរិយាគាំទ្រសង្គមរស់នៅ (ដូចជា "សីលធម៌អហិង្សា"ជាដើម) នៅក្នុងបរិបទនៃការទំនាក់ទំនងប្រចាំថ្ងៃជាមួយសហគមន៍មួយនោះ ។

## សីលធម៌ហិង្សា

ប្រវត្តិសាស្ត្រកម្ពុជាទាក់ទងនឹងអំពើឃោរឃៅប្រឆាំងនឹងអ្នកដែលត្រូវបានចាត់ទុកថាជាសត្រូវរបស់សង្គមនយោបាយនោះ បានចាប់ផ្តើមឡើងតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យមកម្ល៉េះ ។ នៅក្នុងសម័យអង្គរ "ស្តេចដែលជាអាទិទេព" បានដឹកនាំកងទ័ពចូលច្បាំងក្នុងសមរភូមិប្រឆាំងនឹងរដ្ឋដទៃ ។ សត្រូវខាងក្រៅនិងអ្នកប្រឆាំងខាងក្នុងត្រូវបានចាត់ការយ៉ាងចាស់ដៃ ។ អំពើហិង្សានយោបាយបានរីករាលដាលក្នុងអំឡុងសតវត្សរ៍ទី១៩ ហើយបន្តរហូតដល់ពេលនៃការគ្រប់គ្រងរបស់បារាំង ។ ជាពិសេស ខ្មែរឥស្សរៈល្បីល្បាញខាងប្រើអំពើហិង្សាឥតក្តីមេត្តាជាមួយសត្រូវរបស់ខ្លួន ។ ការណ៍នេះជាប្រផ្នូលដល់ការអនុវត្តពីសំណាក់ខ្មែរក្រហម ។ ក្រោយពីទទួលបានឯករាជ្យហើយសម្តេច សីហនុ បានបង្កើតប្រពៃណីសាជាថ្មីដោយប្រើអំណាចផ្តាច់ការរបស់រាជវង្ស ។ ជនណាហ៊ានប្រឆាំងនឹងរាជបញ្ញត្រូវបានចាត់ទុកថា ជាជនក្បត់ជាតិ និងត្រូវដាក់ទណ្ឌកម្មទៅតាមទំហំនៃទោសកំហុស ។ ទង្វើរបស់កងទ័ព លន់ ណុល ក៏មិនសូវខុសគ្នាប៉ុន្មានទេ ។ ភស្តុតាងនេះបញ្ជាក់ឲ្យឃើញថា ក្នុងខណៈដែលមនុស្សម្នាក់ប្រហែលជាអាច"សុភាពរាបសា"នៅក្នុងសហគមន៍មួយនោះ សីលធម៌ផ្សេងទៀតភាគច្រើនមិនទាន់ប្រកាន់ភាពនឹងនទេ នៅក្នុងបរិបទនៃការទំនាក់ទំនងក្នុងសង្គមនយោបាយដែលមានលក្ខណៈធំទូលាយជាង ។

ដើមកំណើតនៃប្រពៃណីហិង្សាក្នុងសង្គមនយោបាយនោះអាចមានឫសគល់ចេញមកពីទ្រឹស្តីព្រហ្មនិយមទាក់ទងនឹងឋានៈនិងតួនាទី ។ "ភាពជាធម្មជាតិ"នៃតួនាទីសង្គមត្រូវបានបញ្ចូលនៅក្នុងធម៌ "ទ្រឹស្តីលោកធាតុទាក់ទងនឹងភារកិច្ច ដែលតាមទ្រឹស្តីនោះសត្វលោកគ្រប់ជំពូកនៅក្នុងពិភពលោកនេះ…មានសីលធម៌ម្យ៉ាងដើម្បីបំពេញនិងធម្មជាតិដែលត្រូវបញ្ចេញ ។ របស់ទាំងពីរយ៉ាងនេះគឺដូចគ្នា" ។ ភារកិច្ចនេះអាចប្រែប្រួលទៅតាមទីកន្លែងនិងពេលវេលា ។ បើនិយាយក្នុងបរិបទមួយអ្នកចម្បាំងត្រូវតែគោរពចៅហ្វាយនាយរបស់ខ្លួន ។ ចំណែកនៅក្នុងស្ថានភាពផ្សេងមួយទៀត ធម្មជាតិរបស់អ្នកចម្បាំងអាចនឹងតម្រូវឲ្យគាត់"កម្ទេចខ្មាំងដោយគ្មានរួញរា" ។

**អាឡិច ហ៊ីនតុន**

# នីតិវិធីសម្រាប់ការកំណត់យកភ័ស្តុតាង

### ក) ការធ្វើកសិណក្រោមពាក្យសម្បថឬពាក្យសច្ចា

សេចក្តីព្រាងបទបញ្ញត្តិគំរូរបស់អង្គការសហប្រជាជាតិ និងបទបញ្ញត្តិសម្រាប់ក្រុមការងាររបស់អង្គការសហប្រជាជាតិ ដែលបង្កើតឡើងតាមការចាំបាច់ស្តីពីប្រទេសឈីលី ចែងថា រាល់សាក្សីរដ្ឋាភិបាលទាំងអស់នឹងតម្រូវឲ្យធ្វើសម្បថមុនពេលធ្វើកសិណ ។ ទោះបីអង្គការសហប្រជាជាតិនិងអង្គការមិនមែនរដ្ឋាភិបាលខ្វះខាតអំណាចជាចៅក្រមនិងអំណាចកាត់ទោសក្តី គេជឿថា ការប្រកាន់ពាក្យសម្បថយ៉ាងហោចណាស់ក៏ធ្វើឲ្យសាក្សីមានចំណាប់អារម្មណ៍ទៅលើភាពប្រាកដប្រជានៃកសិណផ្ទាល់មាត់ដែរ ។

គណៈកម្មការស្វែងរកការពិតរបស់អង្គការក្រៅរដ្ឋាភិបាលកម្រនឹងធ្វើសម្ភាសន៍ដោយឲ្យសាក្សីស្បថណាស់ ហើយជាទូទៅមិនមានការប៉ុនប៉ងបង្កើតឲ្យមានបែបបទជានីតិវិធីរបស់តុលាការទេ ។ បែបបទនៃការប្រកាន់ពាក្យសម្បថអាចមានឥទ្ធិពលមិនល្អដល់ជនរងគ្រោះ សិទ្ធិមនុស្ស និងអ្នកផ្តល់ព័ត៌មានផ្សេងទៀតដែលមានការភ័យខ្លាចពីការសងសឹក ហើយជារឿយៗ ទាមទារឲ្យកសិណរបស់ខ្លួនមិនត្រូវបានយកមកបញ្ជាក់អត្តសញ្ញាណទេ ។ ហេតុនេះ គណៈកម្មការស្វែងរកការពិតរបស់អង្គការក្រៅរដ្ឋា-ភិបាល ជាទូទៅផ្អែកលើការស្ទាបស្ទង់ ការសាកសួរដ៏ទន់ភ្លន់ដើម្បីធានាឲ្យភាពដែលអាចជឿបាននៃកសិណផ្ទាល់មាត់ ។

### ខ) ការសាកសួរសាក្សីយ៉ាងប្រុងប្រយ័ត្ន

នីតិវិធីស្វែងរកការពិតជាអន្តររដ្ឋាភិបាល ជាទូទៅមានលក្ខណៈជាដំណើរការខ្លាំងជាងការខិតខំធ្វើដោយអង្គការក្រៅរដ្ឋាភិបាល ដែលការស៊ើបអង្កេតរបស់ខ្លួនចងក្រងការសម្ភាសន៍ច្រើនជាងការវិនិច្ឆ័យទៅលើការស្តាប់ចម្លើយ ។ ក្នុងរបៀបខ្លះអ្នកស្វែងរកការពិតរបស់អង្គការក្រៅរដ្ឋាភិបាលបានតាំងខ្លួនឯងដូចជាចៅក្រមណែនាំនៅក្នុងបណ្តាប្រទេសប្រើច្បាប់បារាំង ។ អ្នកសាកសួររបស់អង្គការក្រៅរដ្ឋាភិបាលមិនចាំបាច់ត្រូវបង្ហាញការពិតដល់អង្គការឯករាជ្យមួយចំនួន ដូចជាចៅក្រមឬក្រុមប្រឹក្សាចៅក្រម ប៉ុន្តែអ្នកទាំងពីរនេះសាកសួររួចហើយ យកចម្លើយមកវិភាគ ។ ដោយហេតុដូច្នេះហើយ អ្នកធ្វើសម្ភាសន៍អាចទទួលបានព័ត៌មានដែលមានន័យពេញលេញតាមវិធីសួរសមដូនកាលតាមរយៈការសាកសួរដោយប្រយោល ។ សំណួរនាំមុខឬសំណួររបៀបជាសំណើដ៏ទន់ភ្លន់ ត្រូវបានប្រើប្រាស់ដោយអង្គការរដ្ឋាភិបាលអន្តរជាតិដើម្បីជ្រើសរើសយកព័ត៌មានពីសាក្សី ហើយអាចត្រូវបានប្រើប្រាស់ដោយអង្គការក្រៅរដ្ឋាភិបាល ។ ទោះជាយ៉ាងណាក្តី នៅក្នុងឱកាសមួយចំនួនដូចជា ការសួរទៅលើតំណាងរបស់រដ្ឋាភិបាល អ្នកស្វែងរកការពិតរបស់អង្គការក្រៅរដ្ឋាភិបាល ចាំបាច់ត្រូវប្រើប្រាស់វិធីសាកសួរដោយមានលក្ខណៈបន្តិចខ្លះៗ ។

### វិធីសាស្ត្រនៃការវាយតម្លៃលើភាពដែលអាចជឿបាននៃភ័ស្តុតាង

#### ក) ការអះអាងបន្ថែម

អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិអះអាងបន្ថែមថាជាវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ជាទូទៅ និងយ៉ាងសំខាន់បំផុតសម្រាប់កំណត់នូវភាពដែលអាចជឿទុកចិត្តបាននៃព័ត៌មានស្តីពីសិទ្ធិមនុស្ស ។ ដោយជួបប្រទះអ្នកផ្តល់ព័ត៌មានដែលមិនអាចជឿទុកចិត្តបាន ឬអ្នកផ្តល់ព័ត៌មានដែលមានគំនិតនយោបាយ ហើយជាញឹកញាប់ជួបប្រទះនូវភ័ស្តុតាងដោយប្រយោល អង្គការក្រៅរដ្ឋាភិបាលព្យាយាមពិនិត្យយ៉ាងល្អិតល្អន់លើព័ត៌មានរបស់ខ្លួន ដើម្បីរកឲ្យឃើញទិន្នន័យដែលមានលក្ខណៈរួមនិងទិន្នន័យដែលមានលក្ខណៈបញ្ជាក់បន្ថែមចេញពីប្រភពឯករាជ្យ ។

ជួនកាល គណៈកម្មការទទួលបានភ័ស្តុតាងដែលមានលក្ខណៈបញ្ជាក់បន្ថែមលើរូបរាងកាយ ដូចជាស្នាមជាំ សម្លាក ឬក៏ភ័ស្តុតាងផ្សេងទៀតនៃការធ្វើទារុណកម្មលើរូបរាងកាយ ទោះបីជាពេលកន្លងផុតទៅធ្វើឲ្យភ័ស្តុតាងប្រភេទនេះពិបាកនឹងទទួលបានក្តី ។

ការចុះពិនិត្យដល់ទីកន្លែងអាចផ្តល់ឱកាសដើម្បីផ្ទៀងផ្ទាត់សេចក្តីពិពណ៌នារបស់សាក្សីអំពីអគារនិងបន្ទប់ជាដើម ។

### ខ) ការប្រើប្រាស់ភ័ស្តុតាងផ្ទាល់

ការចុះត្រួតពិនិត្យនីមួយៗ ពេលណាអាចធ្វើបានព្យាយាមផ្អែកលទ្ធផលរបស់ខ្លួនទៅលើភ័ស្តុតាងផ្ទាល់ ។ ទោះបីយ៉ាងណាក៏ដោយ អង្គការក្រៅរដ្ឋាភិបាលភាគច្រើនរាប់បញ្ចូលលទ្ធផលដែលផ្អែកលើកសិណដែលគ្រាន់តែឮគេនិយាយ (ពាក្យចចាមអារ៉ាម) ជាពិសេសរាប់បញ្ចូលកសិណណាដែលស្របទៅតាមភ័ស្តុតាងដទៃទៀតដែលអាចរកបានក្នុងពេលចុះត្រួតពិនិត្យ ។

ក្នុងករណីអវត្តមានភ័ស្តុតាងផ្ទាល់ ការចុះពិនិត្យរបស់អង្គការក្រៅរដ្ឋាភិបាលផ្អែកលើចំនួន លើការចោទប្រកាន់ទន្ទើទារុណកម្ម និងភាពប្រហាក់ប្រហែលគ្នានៃការចោទប្រកាន់ដើម្បីបង្កើតការយល់ឃើញជាលើកដំបូងទៅលើករណីប្រព្រឹត្តមិនគប្បី ។ ពេលដែលមានពាក្យបណ្តឹងអំពីការប្រព្រឹត្តមិនគប្បីចំនួន៥០ត្រូវបានទទួល ហើយពាក្យបណ្តឹងទាំងនោះពិពណ៌នាអំពីប្រភេទប្រហាក់ប្រហែលគ្នាទារុណកម្មនៅកន្លែងដូចគ្នា មានភាពគ្រប់គ្រាន់ដែលថា ការធ្វើទារុណកម្មទ្រង់ទ្រាយខ្លះកំពុងតែត្រូវបានប្រព្រឹត្ត ។ ការរកឃើញនៃការពិតផ្អែកលើភ័ស្តុតាងបែបនេះ បានបង្ហាញពីភាពដែលអាចឲ្យជឿបានពីអតីតកាល ។

### គ) ឥរិយាបថរបស់សាក្សី

ឥរិយាបថរបស់សាក្សីអាចចង្អុលបង្ហាញពីភាពខ្វាចញញើត ឬភាពក្លាហាន ដែលអ្នកស្វែងរកការពិតអាចសន្និដ្ឋានលើសច្ចភាពនៃពាក្យសម្តីដែលបាននិយាយ ឬប្រហែលថាបុគ្គលនោះមានជំហរមិនច្បាស់លាស់ ។ របាយការណ៍អំពីការស្វែងរកការពិតរបស់អង្គការរដ្ឋាភិបាលអន្តរជាតិនិងអង្គការក្រៅរដ្ឋា-ភិបាល ជាធម្មតាមិនបានអះអាងទៅលើសារសំខាន់នៃឥរិយាបថរបស់សាក្សី នៅក្នុងការវាយតម្លៃភាពដែលអាចជឿបានទេ ទោះជាការចុះទៅពិនិត្យដល់ទីកន្លែងត្រូវបានបំផុសឲ្យធ្វើឡើងទៅតាមកម្រិតខ្លះ ក្នុងបំណងចង់ជួបនិងស្តាប់សាក្សីក៏ដោយ ។

### ឃ) បន្ទុកនៃបន្ទាល់ និង ការបង្កើតភ័ស្តុតាង

ទស្សនៈរបស់បន្ទុកនៃបន្ទាល់ និងបន្ទុកនៃការបង្កើតភ័ស្តុតាងដើរតួដ៏សំខាន់នៅក្នុងការធានាភាពដែលអាចជឿទុកចិត្តបានលើការរកឃើញជាក់ស្តែង ដោយដាក់ការទទួលខុសត្រូវចំពោះការបង្កើតភ័ស្តុតាងទៅលើភាគីដែលគួរតែកាន់កាប់ភ័ស្តុតាង ឬមានការចាប់អារម្មណ៍ដ៏ខ្លាំងនៅក្នុងការបង្ហាញភ័ស្តុតាងនោះ និងដោយបង្កើតបន្ទុកនៃការទាក់ទាញឲ្យគេជឿតាមសម្រាប់អ្នកគាំទ្រចំពោះជំហរនោះ ។ វាអាចច្បាស់ថា អង្គការក្រៅរដ្ឋាភិបាលមួយដែលជាអ្នកស៊ើបអង្កេតផង និងជាអ្នកធ្វើសេចក្តីសម្រេចចិត្តផង ត្រូវមានបន្ទុកនៃការបង្កើតភ័ស្តុតាងទាំងអស់ដែលចាំបាច់សម្រាប់ទ្រទ្រង់ការរកឃើញរបស់ខ្លួន ។ ទោះបីជាយ៉ាងណាក្តី រដ្ឋាភិបាលដែលត្រូវបានចោទប្រកាន់ថា មានការចាប់អារម្មណ៍ដំណើរបង្កើតភ័ស្តុតាងនេះ និងមានលទ្ធភាពច្រើនបំផុតដើម្បីដាក់ជូននិងបង្ហាញឯកសារដែលពាក់ព័ន្ធ ។ គណៈកម្មការអន្តរជាតិអាមេរិកស្តីពីសិទ្ធិមនុស្ស ហាក់ដូចជាដាក់បន្ទុកនៃការបង្កើតភ័ស្តុតាងឲ្យទៅរដ្ឋាភិបាលដែលត្រូវស៊ើបអង្កេត ។ ដូចគ្នានេះដែរ ប្រសិនបើអង្គការក្រៅរដ្ឋាភិបាលយ៉ាងហោចណាស់អាចបង្កើតការពិនិត្យមើលជាដំបូងទៅលើសំណុំរឿងដែលថាការរំលោភសិទ្ធិមនុស្សបានកើតឡើង ពេលនោះអង្គការក្រៅរដ្ឋាភិបាលអាចទទូចសុំឲ្យរដ្ឋាភិបាលដកចេញនូវបន្ទុកនៃការបង្ហាញភ័ស្តុតាងដែលផុយពីនេះ ។ "បទបញ្ញត្តិ"នេះប្រហែលជាការពិពណ៌នាយ៉ាងល្អនូវការងាររបស់មតិសាធារណជន នៅពេលដែលអង្គការក្រៅរដ្ឋាភិបាលមួយបានរាយការណ៍ថា សិទ្ធិមនុស្សត្រូវបានរំលោភ ហើយរដ្ឋាភិបាលមិនបានបដិសេធចំពោះលទ្ធផលរកឃើញ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ ។

កម្រិតនៃភ័ស្តុតាងដែលត្រូវបានប្រើប្រាស់ដោយអង្គការក្រៅរដ្ឋាភិបាលមួយដែលអាចប្រែប្រួល អាស្រ័យលើឥទ្ធិពលនៃសកម្មភាពដែលអនុវត្តតាមកិច្ចប្រឹងប្រែងស្វែងរកការពិត ។ ឧទាហរណ៍ ប្រសិនបើអង្គការក្រៅរដ្ឋាភិបាលមួយគ្រាន់តែសុំផ្ញើលិខិតការទូតនៃការស៊ើបអង្កេតមួយទៅរដ្ឋាភិបាលអង្គការនោះអាចត្រូវការរបាយការណ៍បន្ទាប់បន្សំស្តីពីការរំលោភសិទ្ធិមនុស្សដែលអាចជឿបាន ។ ប្រសិនបើអង្គការនេះ បោះពុម្ពផ្សាយរបាយការណ៍ចម្បង គួរតែតម្រូវឲ្យមានភ័ស្តុតាងច្រើនថែមទៀតអំពីកំហុសឆ្គងនោះ ។

### ៧) ការផ្សព្វផ្សាយរបាយការណ៍

បញ្ហាចម្បងដែលទាក់ទងដល់ការផ្សព្វផ្សាយរបាយការណ៍នៃការរកឃើញការពិតគឺថា តើរបាយការណ៍នោះគួរតែដាក់ជូនទៅរាជរដ្ឋាភិបាលដែលពាក់ព័ន្ធឲ្យធ្វើអត្ថាធិប្បាយ ឬឆ្លើយតបមុនពេលផ្សព្វផ្សាយដល់សាធារណជនដែរឬទេ...។ (ហេតុផលមួយសម្រាប់ការអនុវត្តតាមវិធីនេះ) ផ្តល់ភ័ស្តុតាង ដែលមានលក្ខណៈជាការសន្និដ្ឋានតិចតួច ដែលនៅក្នុងភ័ស្តុតាងនោះ លទ្ធផលត្រូវបានផ្អែកលើភាពត្រឹមត្រូវតម្រូវឲ្យរដ្ឋាភិបាលមានឱកាសឆ្លើយតបចំពោះការសន្និដ្ឋាននោះ ។

អង្គការក្រៅរដ្ឋាភិបាលជាប្រចាំផ្តល់លទ្ធផលរបស់ខ្លួនទៅឲ្យ និង/ឬ ស្នើសុំភ័ស្តុតាងពីរដ្ឋាភិបាលដែលជាប់ពាក់ព័ន្ធ ។ ជារឿយៗ កិច្ចព្រមព្រៀងសម្រាប់ផ្តល់លទ្ធផលឲ្យនិងទទួលការអធិប្បាយពីរដ្ឋាភិបាល គឺជាលក្ខខណ្ឌដំបូងសម្រាប់ការអនុញ្ញាតការចុះពិនិត្យដល់ទីកន្លែង ។ បញ្ហាជាចម្បងចំពោះវិធីនេះ ត្រូវបានបដិសេធដោយរដ្ឋាភិបាលក្នុងការឆ្លើយតប ។

អង្គការក្រៅរដ្ឋាភិបាលមិនគួរប្តេជ្ញាចិត្តថានឹងមិនផ្សព្វផ្សាយរបាយការណ៍ទេ ដរាបណាមិនបានទទួលការឆ្លើយតបពីរដ្ឋាភិបាល ។ ពេលវេលាដែលត្រូវកំណត់សម្រាប់ការឆ្លើយតប គួរតែកំណត់នៅពេលរបាយការណ៍ត្រូវបានបញ្ជូនទៅរដ្ឋា-ភិបាល ដោយមានចែងថា របាយការណ៍ពេញលេញ នឹងត្រូវបោះពុម្ពផ្សាយជាសាធារណៈ បន្ទាប់ពីអធិប្បាយជាសាធារណៈដែលរៀបចំដោយរដ្ឋាភិបាល ។

**អេលីហ្សាប៊ែត ម៉ាន់ស្តាក់**



ក្រុមអ្នកស្រាវជ្រាវនិងសារព័ត៌មាន កំពុងធ្វើសម្ភាសន៍កុមារដែលជាជនរងគ្រោះសម្រាប់តុលាការឆ្នាំ១៩៧៩

# គ្មានយុត្តិធម៌សម្រាប់ជនរងគ្រោះក្នុងរបបខ្មែរក្រហម




តុលាការឧក្រិដ្ឋកម្មអន្តរជាតិនឹងចាប់បដិសន្ធិឆាប់ៗខាងមុខនេះ ។ ប្រព័ន្ធថ្មីមួយនៃយុត្តិធម៌ ឧក្រិដ្ឋកម្មអន្តរជាតិ ដែលត្រូវបានបង្កើតឡើងអស់រយៈពេលជាង៥០ឆ្នាំមកហើយនឹងត្រូវកកើតឡើង ។ ជនដែលប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មសង្គ្រាម នឹងមិនអាចប្រាស្រ័យលើវប្បធម៌នៃភាពរួចទោសបានទៀតទេ ។

ដូច្នេះការបញ្ឈប់ការចរចារបស់អង្គការសហប្រជាជាតិជាមួយរដ្ឋាភិបាលកម្ពុជា អំពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ជារឿងមួយគួរឲ្យភ្ញាក់ផ្អើលខ្លាំងណាស់ ។

ដើមឡើយ អង្គការសហប្រជាជាតិសំណូមពរបង្កើតតុលាការអន្តរជាតិឯករាជ្យមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែនៅពេលដែលដឹងច្បាស់ថាតុលាការបែបនេះពុំអាចបង្កើតបាន អ្វីដែលអង្គការសហប្រជាជាតិត្រូវពិចារណានោះគឺថា តើខ្លួនអាចចូលរួមក្នុងតុលាការជាតិដែលត្រូវបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជាបានឬទេ ហើយក្នុងលក្ខខណ្ឌបែបណា ។

នៅពេលដែលបានដឹងថា អង្គការសហប្រជាជាតិកំពុងតែត្រូវបង្ខំឲ្យចូលរួមក្នុងតុលាការមួយដែលពុំគោរពតាមបទដ្ឋានអន្តរជាតិទៅលើឯករាជ្យភាព ភាពយុត្តិធម៌ និងវិស័យភាព លោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិក៏បញ្ឈប់ការចរចាតែម្តង ។

លោកអគ្គលេខាធិការយល់ថា អង្គការសហប្រជាជាតិមិនគួរចូលរួមក្នុងតុលាការមួយដែលពុំអាចផ្តល់នូវយុត្តិធម៌ដែលជនរងគ្រោះនៃរបបខ្មែរក្រហមសមនឹងទទួលទេ ។ លើសពីនេះ វត្តមានរបស់អង្គការសហប្រជាជាតិនៅក្នុងតុលាការបែបនេះ នឹងក្លាយទៅជាឧទាហរណ៍មួយនៃការបន្ទាបបទដ្ឋានអន្តរជាតិទៅថ្ងៃអនាគត ។

ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ខ្មែរក្រហមបានធ្វើឲ្យប្រជាជនកម្ពុជាជិត២លាននាក់ ឬមួយភាគបួននៃប្រជាជនក្នុងសម័យនោះ ស្លាប់បាត់បង់ជីវិត ។ ក្នុងឆ្នាំ១៩៩៧ រដ្ឋាភិបាលកម្ពុជាបានសំណូមពរឲ្យអង្គការសហប្រជាជាតិជួយដោះស្រាយ ។ ចាប់ពីពេលនោះមក អង្គការសហប្រជាជាតិបានព្យាយាមយ៉ាងពេញទំហឹង ដើម្បីបង្កើតតុលាការកម្ពុជាមួយដែលមានលក្ខណៈអន្តរជាតិ ហើយគោរពតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ។

នៅទីបញ្ចប់ ភាគីទាំងសងខាងមិនចុះសម្រុងគ្នានៅលើចំណុចសំខាន់ៗជាច្រើន ។ អង្គការសហប្រជាជាតិបានស្នើឲ្យមានការចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងដើម្បីបង្កើតលក្ខខណ្ឌរួមមួយចំនួនសម្រាប់ប្រតិបត្តិការណ៍របស់តុលាការ ។ ចំណែករដ្ឋាភិបាលកម្ពុជាវិញ ទាមទារឲ្យច្បាប់ក្នុងស្រុកដែលអនុម័តដោយសភារបស់ខ្លួន ជាមូលដ្ឋានចម្បងក្នុងការបង្កើតតុលាការខ្មែរក្រហម ។ ដោយច្បាប់ក្នុងស្រុកអាចត្រូវកែប្រែដោយសភាបានគ្រប់ពេល ការពន្យារពេល ឬឥទ្ធិពលពីកត្តានយោបាយ និងជាបញ្ហាពុំអាចចៀសវាងបាន ដោយមូលហេតុថា ប្រព័ន្ធតុលាការក្នុងស្រុកនៅទន់ខ្សោយនៅឡើយ ការបង្អែបង្អង់ដែលបញ្ចេញដោយភាគីកម្ពុជាក្នុងដំណើរការនៃការចរចា និងភាពស្ទាក់ស្ទើររបស់មន្ត្រីជាន់ខ្ពស់មួយចំនួននៅក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម លោកអគ្គលេខាធិការយល់ថា ឥទ្ធិពលនយោបាយប្រាកដជាកើតមាន ។

ការយល់ព្រមតាមសំណើរបស់រដ្ឋាភិបាលកម្ពុជានឹងធ្វើឲ្យអង្គការសហប្រជាជាតិក្លាយទៅជាជំនួយការបច្ចេកទេសក្នុងតុលាការនេះ ចៀសវាងជាតួអង្គក្នុងការផ្តល់យុត្តិធម៌ទៅវិញ ។ ក្នុងលក្ខខណ្ឌបែបនេះ អង្គការសហប្រជាជាតិនឹងមានឈ្មោះថាបានចូលរួមក្នុងដំណើរការក្តីដែលខ្លួនស្ទើរតែគ្មាន ឬគ្មានឥទ្ធិពលចំពោះការផ្តល់យុត្តិធម៌ ។

**ហេន កូរ៉ែល**

# អតីតយុទ្ធនារីខ្មែរក្រហម សុំទោសប្រជាជនកម្ពុជា

"ខ្ញុំសុំទោសដែលខ្ញុំបានចូលរួមបម្រើរបបខ្មែរក្រហម ដែលជារបបកាប់សម្លាប់និងធ្វើបាបប្រជាជន" ។ នេះគឺជាសម្ដីក្លាហានរបស់ ដែង ពល់ អតីតយុទ្ធនារីខ្មែរក្រហម ។ ដែង ពល់ បានចូលរួមបម្រើខ្មែរក្រហមនៅឆ្នាំ១៩៧២ ក្នុងអាយុ១៥ឆ្នាំ តាមការអូសទាញរបស់ តាសារឹម កម្មាភិបាល ស្រុកសន្ទុក ខេត្តកំពង់ធំ ។

មន្ទីរសន្តិសុខនោះមាននាទីឃុំឃាំងនិងសួរចម្លើយអ្នកទោស ។ ប្រជាជនដែលត្រូវប្រធានមន្ទីរសន្តិសុខសម្រេចថាយកទៅសម្លាប់ត្រូវរុំមុខបណ្ដើរចេញទៅព្រៃចម្ការកៅស៊ូ រួចរុញទម្លាក់រណ្ដៅតែម្ដង ។ ការសម្លាប់អ្នកទោសធ្វើឡើងទាំងនៅពេលថ្ងៃនិងពេលយប់ ។ ប្រសិនបើត្រូវសម្លាប់អ្នកទោសនាពេលថ្ងៃខ្មែរក្រហមតែងតែចាក់មេក្រូបំពងសំឡេង ដើម្បីកុំឲ្យប្រជាជនធ្វើការនៅ



ដែង ពល់

នៅក្នុងតួនាទីជាប្រធានភូមិត្រពាំងបេងនិងប្រធានរោងចក្រកាត់ដេរនៅចម្ការកៅស៊ូចម្ការអណ្ដូង ដែង ពល់ បានដឹងអំពីការចាប់ខ្លួនប្រជាជនយកទៅឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខដែលស្ថិតនៅក្នុងភូមិត្រពាំងបេង និងការសម្លាប់ប្រជាជនរាប់ពាន់នាក់នៅក្នុងព្រៃចម្ការកៅស៊ូ ។ ដែង ពល់ បានបញ្ជាក់ថា នៅក្នុងភូមិដីងត្នោ ។ ដែង ពល់ បន្តថា ប្រជាជនដែលត្រូវសម្លាប់នៅក្នុងព្រៃចម្ការកៅស៊ូ អណ្ដូងតាហុងនិងព្រៃតាប៉ុម ភាគច្រើនជាប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញ និងមួយចំនួនទៀតជាប្រជាជនក្នុងខេត្តកំពង់ធំនិងខេត្តកំពង់ចាម ។ ការសម្លាប់ក្នុងព្រៃចម្ការកៅស៊ូនេះ បានកើតឡើងចាប់តាំងពីពាក់កណ្ដាលឆ្នាំ

១៩៧៥ និងបន្តរហូតដល់ចុងឆ្នាំ១៩៧៨ ប៉ុន្តែការសម្លាប់បានថយចុះទៅវិញ បន្ទាប់ពីគណៈ៨៧០ ចេញសារាចរណែនាំទប់ស្កាត់ការសម្លាប់ប្រជាជននៅចុងឆ្នាំ១៩៧៨ ។ ផែង ពល់ ក៏ទទួលបានសារាចររបស់គណៈ៨៧០ដែរ ។ គាត់នៅចាំខ្លឹមសាររួមរបស់សារាចរ គឺហាមឃាត់ការសម្លាប់ប្រជាជនបន្តទៀត ។

ចាប់ពីឆ្នាំ១៩៧៤ដល់ឆ្នាំ១៩៧៨ ផែង ពល់ ធ្វើជាតំណាងយុទ្ធនារីតំបន់ និងធ្លាប់បានថ្លែងបិទវគ្គសិក្សានយោបាយក្រោមអធិបតីភាពសមមិត្តនារី ខៀវ ប៉ុណ្ណារី នៅឆ្នាំ១៩៧៤ ។ ពីឆ្នាំ១៩៧៨-១៩៧៩ ផែង ពល់ ធ្វើជាប្រធានភូមិត្រពាំងបេង និងប្រធានរោងចក្រកាត់ដេរនៅចម្ការកៅស៊ូចម្ការអណ្ដូង ។

ផែង ពល់ សុំទោសប្រជាជនកម្ពុជាគ្រប់រូប ចំពោះតួនាទីជាកម្មាភិបាលខ្មែរក្រហមរបស់គាត់ ដែលបានដឹងឮអំពើរំលោភធ្វើបាបនិងកាប់សម្លាប់ប្រជាជន ។ ផែង ពល់ អះអាងថាការសម្លាប់ប្រជាជនក្នុងរបបខ្មែរក្រហមកើតឡើងដោយសារគោលនយោបាយឆ្គួតលីលារបស់មេដឹកនាំខ្មែរក្រហម ។ ផែង ពល់ នៅចាំគោលនយោបាយដែលផ្សព្វផ្សាយដោយសមមិត្តនារី ខៀវ ប៉ុណ្ណារី ក្នុងវគ្គសិក្សានយោបាយដល់នារីទូទាំងតំបន់ក្នុងឆ្នាំ១៩៧៤ ដែលកាលនោះ ខៀវ ប៉ុណ្ណារី និយាយថា វណ្ណៈសក្តិភូមិនាយទុន គឺជាវណ្ណៈជិះជាន់កេងប្រវ័ញ្ចលើវណ្ណៈកសិករ-កម្មករ ដូច្នេះយើងត្រូវតែលុបបំបាត់វណ្ណៈសក្តិភូមិនិងនាយទុន ។ ផែង ពល់ បន្តថា “កាលណោះ យើងអត់មានដឹងផែនការលុបបំបាត់វណ្ណៈនិងត្រូវចាប់ពួកសក្តិភូមិនាយទុនយកទៅវៃចោលទេ ។ កាលពីឆ្នាំ១៩៧៣-១៩៧៤ ដូចជាមិនទាន់មានការកាប់សម្លាប់កើតឡើងទេ តែដល់ចូលឆ្នាំ១៩៧៥ និងបន្តបន្ទាប់មកចាប់ផ្ដើមតែម្ដង ។ ខ្ញុំដឹងអំពីការសម្លាប់មនុស្សនៅក្នុងភូមិឃុំខ្ញុំ ប៉ុន្តែមិនដឹងធ្វើម៉េច ។ ការងារផ្សេងគ្នា យើងលូកលាន់ការងាររបស់គេអត់បានទេ ។ ខ្មែរក្រហមនៅថ្នាក់ក្រោមសុទ្ធតែធ្វើតាមបញ្ជាបក្សដាក់ចុះ បើគ្នាមិនធ្វើក៏មិនបានដែរ” ។

ផែង ពល់ សុំទោសជាពិសេសចំពោះប្រជាជនរស់នៅក្នុងភូមិត្រពាំងបេង និងចម្ការកៅស៊ូចម្ការអណ្ដូង ។ ដើម្បីការផ្សះផ្សាបង្រួបបង្រួមជាតិ និងការអភិវឌ្ឍប្រទេស ផែង ពល់ បានផ្ដាំផ្ញើដល់អតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមឯទៀត ឲ្យសុំទោសប្រជាជនដូចគាត់ដែរ ។ ផែង ពល់ និយាយថា “ខ្លាចអីយើងធ្វើខុស យើងត្រូវតែហ៊ានសុំទោសគេ ហើយពន្យល់ប្រាប់គេពីរឿងហ្នឹងឲ្យច្បាស់ ។ អ្នកដែលបានធ្វើខុសត្រូវតែហ៊ានទទួលខុសត្រូវចំពោះមុខច្បាប់ ។ ដើម្បីស្រុកយើងសុខសប្បាយ កុំឲ្យចេះតែខឹងគ្នា យកគ្នាជាសត្រូវមិនចេះចប់មិនចេះហើយ” ។

**អៀម៉េងត្រី**

# ត្រូវទាយថា បងប្រុសខ្ញុំនៅរស់

បងស្រី ទិត្យ ណារី ហៅ គ្រី អាយុ៤៣ឆ្នាំ មុខរបរធ្វើស្រែចម្ការមានស្រុកកំណើតនៅភូមិស្រីជ័យ បច្ចុប្បន្នរស់នៅភូមិហន់ហេង ឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ ។ ទិត្យ ណារី ជាប្អូនស្រីរបស់អ្នកទោសគុកទួលស្លែងម្នាក់ឈ្មោះ ណុប នួន។ នៅមុនពេលក្លាយជាអ្នកទោស ណុប នួន គឺជាយុទ្ធជនស្ទួរចម្លើយនៅមន្ទីរស-២១ឬគុកទួលស្លែងនេះ ។ តាមសម្ដីរបស់ ទិត្យ ណារី បានឲ្យដឹងថា÷

ឪពុករបស់គាត់ឈ្មោះ ទិត្យ ណុប ម្ដាយឈ្មោះ ឌី តែម (ស្លាប់) មានបងប្អូន៤នាក់ៈ បងទី១ឈ្មោះ ទិត្យ ឈន បងទី២ ទិត្យ សារឿង បងទី៣ ទិត្យ នួន (ណុប នួន) និងទី៤គឺរូបគាត់ (ទិត្យ ណារី) ។ ទិត្យ ណារី រៀបរាប់ថា កាលពីរស់នៅជាមួយគ្នា នួន មានអត្តចរិតស្លូតបូត ចេះស្រឡាញ់បងប្អូន មិនដែលឈ្លោះប្រកែកគ្នាទេ ហើយក៏មិនចេះរករឿងនរណាម្នាក់ដែរ ។ នួន រៀនពូកែណាស់ កាលពីសង្គមចាស់រៀននៅសាលាវត្តជម្ពូវង្ស ខេត្តតាកែវ ។ ក្រៅពីកិច្ចការសាលា នួន តែងឆ្លៀតពេលជួយធ្វើស្រែឪពុកជានិច្ច ។

រហូតមកដល់ឆ្នាំ១៩៧០ ពេលដែល លន់ ណុល ធ្វើរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ សាលារៀនត្រូវបិទទ្វារ ហេតុនេះ

ការសិក្សារបស់ នួន ត្រូវបញ្ឈប់នៅពាក់កណ្តាលទី ។ ដូនពេលខ្មែរក្រហមត្រូវការយុទ្ធជនដើម្បីការពារប្រទេសជាតិ នួន បានស្ម័គ្រចិត្តធ្វើជាកងទ័ពបដិវត្តន៍ ។ ពីដំបូង នួន បានធ្វើជាឈ្លបនៅឃុំផបឹងត្រាញ់ ខេត្តតាកែវ ។ បានរយៈពេលប្រហែលមួយឆ្នាំ



ទិត្យ ណារី

ទើបបន្តទៅធ្វើកងទ័ពជាមួយមិត្តភក្តិ៣នាក់ទៀត ដែលមកពីភូមិផ្សេងៗគ្នា ។ សព្វថ្ងៃអ្នកទាំង៣នាក់នោះក៏បាត់ដំណឹងដែរ ។ ក្រោយមកទៀត បានឮដំណឹងថា នួន ត្រូវបានបញ្ជូនទៅអ្នកលឿង ដើម្បីប្រយុទ្ធជាមួយពួកទាហាន លន់ ណុល ។ បងស្រីបានទទួលដំណឹងនេះតាមរយៈសំបុត្រមួយច្បាប់ដែល នួន បានផ្ញើតាម ពូនិន មកឲ្យឪពុកគាត់ថា "កូនបានទៅដល់អ្នកលឿងហើយ" ។ កាលណោះ ពូនិន បានចេញទៅធ្វើទ័ពនៅអ្នកលឿងដែរ ។ ក្រោយមក ពូនិន បានស្លាប់នៅពេលខ្មែរក្រហមវាយបែកអ្នកលឿង ។ ទិត្យ ណារី បានទទួលដំណឹងនេះតែម្តងគត់ តាំងពីនោះមកក៏បាត់ដំណឹងបងប្រុសសូន្យឈឹង ។

ក្រោយថ្ងៃរំដោះទីក្រុងភ្នំពេញ ឆ្នាំ១៩៧៩ ទិត្យ ណារី បានតាមសើបសួរដំណឹងបងប្រុសរបស់គាត់តាមរយៈអ្នកដែលធ្លាប់ធ្វើទ័ពជាមួយគ្នា និងផ្ញើសំបុត្ររហូតដល់ស្រុកសំឡូត ក៏នៅតែគ្មានដំណឹង ។ ទិត្យ ណារី មិនអស់ចិត្តក៏បានរកគ្រូទាយមើល ។ គ្រូទាយទាំងនោះចេះតែនិយាយថា "នៅឆ្ងាយ ដើងលេខដឹងថានៅឆ្ងាយ ប៉ុន្តែមិនដឹងនៅឯណា" ។ គ្រូទាយប្រាប់ទៀតថា មិនយូរមិនឆាប់គង់ជួបគ្នា ។ ចំណែកឪពុករបស់បងស្រីវិញ តែងតែទិញបន្ទងធ្វើបុណ្យបញ្ជូនកុសលទៅឲ្យកូន ព្រោះគិតថា កូនទៅបាត់ហើយ បើកូននៅរស់ចេះតែទទួល តែបើកូនស្លាប់ កូនអាចទទួលផលបុណ្យដែលគាត់បានបញ្ជូនទៅឲ្យ ។

សព្វថ្ងៃនេះ ទិត្យ ណារី នៅតែអាលោះអាល័យនិងចិញ្ចឹមចិត្តចាំមើលផ្លូវបងប្រុសត្រឡប់មកវិញជានិច្ច ទោះបីជាចិត្តនោះគិតថាគាត់មិនបានជួយអ្វីដល់គ្រួសារគាត់ក៏ដោយ ក៏យ៉ាងហោចណាស់ គាត់អាចរស់នៅបានជួបជុំបងប្អូន និងបានធ្វើបុណ្យទានជាមួយគ្នាដែរ ។ ទិត្យ ណារី និយាយថា "ខ្ញុំមិនប្រាកដថាស្លាប់ ហើយក៏មិនទាន់ប្រាកដថារស់ដែរ ។ ក្នុងចិត្តរបស់ខ្ញុំរាល់ថ្ងៃមានអារម្មណ៍ថា ថ្ងៃណាមួយបានជួបគ្នាវិញ" ។

ទិត្យ ណារី បានរៀបរាប់ទៀតថា គាត់ខំបំភ្លេចរឿងរ៉ាវក្នុងរបបខ្មែរក្រហមឲ្យអស់ពីក្នុងខួរក្បាល ព្រោះថារឿងខ្មែរក្រហមជូរចត់ណាស់ ម្យ៉ាងទៀតការបំភ្លេចនេះគឺគាត់មិនចង់ឲ្យរបបនេះកើតឡើងសាជាថ្មីចំពោះគាត់ឡើយ ។

យោងតាមឯកសារចម្លើយសារភាពនិងបញ្ជីកម្មេចអ្នកទោស ទើបនឹងរកឃើញពេលក្រោយនេះ បានបញ្ជាក់ថា ណុប នួន (ទិត្យ នួន) ត្រូវអង្គការសម្លាប់បាត់ទៅហើយ ។

**(សូមអានអត្ថបទអំពី ណុប នួន នៅទំព័រទី២)**

**លី សុផល**

## ពាក្យស្លោកខ្មែរក្រហម

◆ **រៀនសូត្រថែបំប៉នលើកតម្កើងនៃចរិតអង្គការចាត់តាំង ចរិតវិន័យដោយសកម្ម និងចរិតបដិវត្តដោយសកម្ម តាមស្មារតីលិទ្ធិម៉ាក្ស–ឡេនីន ដើម្បីផ្ចាលផ្ចាញ់នូវលទ្ធិសេរីនិយមបក្ខជន មិនសកម្ម សតិអារម្មណ៍គ្មានអង្គការគ្មានវិន័យ។**

(សេចក្តីណែនាំរបស់៨៧០ ទំព័រទី៤ កំណត់ហេតុលេខ០៤៣)

# ជីវិតលោកគ្រូ លៀង ក្នុងរបបខ្មែរក្រហម

លោកគ្រូ ហុង គីមលៀង អាយុ៥៥ឆ្នាំ បច្ចុប្បន្នជានាយករងនៃអនុវិទ្យាល័យបែកចាន ក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល ។ ប្រពន្ធឈ្មោះ ទឹម តេង អាយុ៥៣ឆ្នាំ មានមុខរបរធ្វើស្រែនិងលក់ដូរបន្តិចបន្តួចនៅក្នុងអនុវិទ្យាល័យបែកចាន ។ លោកគ្រូ គីមលៀង មានកូន៥នាក់នៅក្នុងបន្ទុក (កូនប្រុស២នាក់ កូនស្រី៣នាក់) ។

ឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ លោកគ្រូ គីមលៀង ធ្លាប់រស់នៅជិតវត្តទួលក្រសាំង ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងភ្នំពេញ ធ្វើការនៅធនាគារឥណទានជាតិនៅខាងជើងផ្សារចាស់ ។

ក្រោយថ្ងៃ១៧ មេសា ១៩៧៥ លោកគ្រូ លៀង ត្រូវអង្គការជម្លៀសចេញពីទីក្រុងភ្នំពេញធ្វើដំណើរតាមអូរបែកក្អមកាត់តាមត្រពាំងថ្លឹង រួចឆ្លងកាត់តាមផ្លូវបំបែកតម្រង់ឆ្ពោះមកផ្លូវជាតិលេខ៤ ។ នៅពេលធ្វើដំណើរគាត់មានម៉ូតូហុងដា“ម៉ាកសេហ្សេស” សណ្តោងរទេះរ៉ឺម៉កដាក់បង្ហុចខោអាវនិងសម្ភារហូបចុកបន្តិចបន្តួច រួមជាមួយម្តាយចាស់ កូនតូចៗ២នាក់ ប្រពន្ធនិងកូនទី៣ដែលមានអាយុ៤ខែ ។ នៅពេលធ្វើដំណើរមកដល់វត្តគោកបញ្ញាន់ កងទ័ពខ្មែរក្រហមមួយក្រុមបានយកកាំភ្លើងអាកាភ្ជង់គាត់ឲ្យឈប់ដើម្បីឆែកឆេរក្រែងមានលាក់របស់នៅក្នុងខ្លួន រួចវាដកយកម៉ូតូ និងនាឡិកាដៃអស់ ។ នៅពេលនោះលោកគ្រូលៀង តក់ស្លុតយ៉ាងខ្លាំង និយាយរដាក់រដុបទៅកាន់កងទ័ពទាំងនោះថា លោកមិត្តយកអីក៏យកទៅតាមតែលោកត្រូវការ ។ បន្ទាប់ពីកងទ័ពដកហូតយកម៉ូតូ លោកគ្រូ លៀង ត្រូវប្រើកម្លាំងរបស់គាត់អូសរទេះដែលផ្ទុកអីវ៉ាន់ ព្រមទាំងម្តាយចាស់និងកូនតូច២នាក់ទៀត ។ ចំណែកប្រពន្ធគាត់បីកូនតូចដើរពីក្រោយរទេះ ។ ក្រុមគ្រួសារលោកគ្រូ លៀង ធ្វើដំណើរកាត់តាមចោមចៅឆ្ពោះទៅទិសខាងលិចសំដៅមកផ្ទះរបស់គាត់ដែលនៅភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ។ មកដល់មុខផ្ទះ គ្រូលៀងឃើញកងទ័ពខ្មែរក្រហមនៅពាសពេញក្រោមផ្ទះរបស់គាត់ ។


គ្រូលៀង និង ក្រុមគ្រួសារ

ពេលដែលគ្រូលៀង ដើរចូលក្នុងរបងផ្ទះកងទ័ពខ្មែរក្រហមបានភ្ជង់កាំភ្លើងមករកគាត់ព្រមទាំងសួរថា “មករកអី?” ។ គ្រូលៀង បានឆ្លើយតបទៅវិញថា

«មកមើលផ្ទះ» ។ កងទ័ពខ្មែរក្រហមស្រែកដាក់គាត់ថា «គ្មានផ្ទះអ្នកណាទេ គិតប្រយ័ត្នដាក់ឲ្យចាំផ្ទះឥឡូវ» ។ គ្រូលៀង ដើរត្រឡប់ទៅក្រោយវិញទាំងអារម្មណ៍ភិតភ័យ ។

គ្រូលៀង បានអូសរទេះបន្តដំណើរទៅទិសខាងលិចតាមបណ្តោយផ្លូវជាតិលេខ៤ តម្រង់មកភូមិកំណើតរបស់គាត់ គឺនៅភូមិព្រៃពួច ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ។ គ្រួសារ គ្រូលៀង មកស្នាក់នៅលើព្រះវិហារក្នុងវត្តព្រៃពួច ជាមួយអ្នកជម្លៀសផ្សេងទៀតអស់រយៈពេល១៥ថ្ងៃ ទើបអង្គការបញ្ជូនឲ្យទៅនៅភូមិក្តីចាស់ ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ គ្រួសាររបស់ គ្រូលៀង រស់នៅភូមិក្តីចាស់អស់រយៈពេលមួយខែកន្លះ អង្គការក៏បានស្រាវជ្រាវប្រវត្តិរូបរកអ្នកដែលធ្វើការរដ្ឋការ ។ អង្គការដឹងថា គ្រូលៀង ជាអ្នកធ្វើការរដ្ឋការក៏បានបញ្ជូនទៅរស់នៅព្រៃឫស្សី ម្តុំស្រះសម្តេចសង្ឃ ជួន ណាត ក្នុងភូមិសុភី ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ នៅក្នុងព្រៃឫស្សី គ្រូលៀង និងអ្នកជម្លៀសផ្សេងទៀត ត្រូវបានអង្គការដាក់ទិសឲ្យកាប់គាស់រុករានព្រៃឫស្សីដើម្បីយកដីធ្វើស្រែចម្ការ ។

ដូច្នេះអ្នកជម្លៀសប្រុសៗទាំងអស់ត្រូវអង្គការឲ្យគាស់គុម្ពឫស្សី ម្នាក់ត្រូវគាស់ឲ្យបាន៣គុម្ពក្នុងមួយព្រឹក ។ ប្រុសៗទាំងអស់នោះត្រូវទឹមនង្គ័លជំនួសគោក្របីដើម្បីភ្ជួររាស់ដីថ្មីនេះសម្រាប់ធ្វើស្រែចម្ការ ។ គ្រូលៀង បានបញ្ជាក់ថា ដោយមានការភ័យខ្លាច គ្មានអ្នកណាម្នាក់ហ៊ានតវ៉ាប្រឆាំងទាស់ចំពោះទិសដៅរបស់អង្គការឡើយ ។ ក្រុមរបស់គាត់ត្រូវតែធ្វើឲ្យទាល់តែបានដើម្បីប្តូរយកការរស់រានមានជីវិត ។ គ្រួសារ គ្រូលៀង រស់នៅព្រៃឫស្សីមិនបានប៉ុន្មានខែផង អង្គការជម្លៀសឲ្យចេញទៅរស់នៅក្នុងភូមិស្តៅ ឃុំរកាត ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ នៅក្នុងឆ្នាំ១៩៧៥ ។

គ្រូលៀង បានបញ្ជាក់ថា នៅចុងឆ្នាំ១៩៧៥ អង្គការបានប្រកាសថា សម្តេចឪយាងមកស្រុកវិញហើយ ប្រជាជនណានៅស្រុកណាទៅស្រុកហ្នឹងវិញ ។ គ្រួសារ គ្រូលៀង និងប្រជាជនទាំងអស់ មិនត្រូវបានអង្គការបញ្ជូនមកស្រុកកំណើតវិញតាមដែលអង្គការប្រកាសទេ ផ្ទុយទៅវិញ ត្រូវអង្គការបញ្ជូនមកនៅភូមិដូនអី ឃុំដូនអី ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។ បច្ចុប្បន្នភូមិដូនអី នៅក្នុងឃុំចំរើនផល ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។

ការរស់នៅក្នុងខេត្តពោធិ៍សាត់នេះ គ្រូលៀង ត្រូវអង្គការឲ្យមកធ្វើការនៅការដ្ឋានលើកោះក្នុងឃុំដូនអី ។ ការងារមុនដំបូងរបស់ គ្រូលៀង គឺអង្គការឲ្យរែកទឹកពីមាត់ស្ទឹងលាច មកដាក់រោងបាយមួយព្រឹកឲ្យបានពី៣០ទៅ៤០អំរែក ។ ចំណែករបបហូបចុកមានតែបបររាវកក្លុក គឺមួយខ្ទះត្នោតដាក់អង្ករពីរកំប៉ុងលាយជាមួយគមត្នោតពីរគមនិងផ្ទីអាចម៍មាន់បីកញ្ជ្រែង ។ ជួនកាលបបរគ្មានដាក់អង្ករទេ ដាក់តែស្លឹកដំឡូងលាយជាមួយមើមដំឡូងបន្តិចបន្តួចប៉ុណ្ណោះ ។ ប្រពន្ធរបស់ គ្រូលៀង ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការនៅការដ្ឋានស្រែសម្រាប់កងកូនខ្ចីគឺដកស្ទូង ។ ដោយសារការហូបចុកមិនគ្រប់គ្រាន់ ប្រពន្ធគាត់ផ្កាក់ខ្លួនឈឺស្គមរីងរៃនិងទាស់អត់ទឹកដោះឲ្យកូនបៅ ។ នៅចុងឆ្នាំ១៩៧៥ កូនពីរនាក់របស់ គ្រូលៀង ត្រូវអង្គការស្នើយកទៅដាក់នៅក្នុងកងកុមារតូចៗ ។ ដោយគ្មានការថែទាំនិងហូបមិនគ្រប់គ្រាន់ កូនរបស់គាត់ទាំងពីរក៏ឈឺហើមដៃហើមជើង ខ្លួនស្គមសល់តែឆ្អឹង ។ ក្រោយមកប្រធានការដ្ឋានលើកោះ ឈ្មោះ ស៊ិន បានប្រាប់គ្រូលៀងថា «លៀងឯងស្អែកអង្គការឲ្យទៅវាយថ្មនៅកំពែងក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់» ។ គ្រូលៀង បានបញ្ជាក់ថា គាត់ត្រូវបានអង្គការចាត់តាំងឲ្យទៅវាយថ្មនិងច្រៀកចាំងឈើហ៊ុប ដើម្បីយកទៅទប់ដីនៅទំនប់ឈើគោក ។ ការធ្វើទំនប់នេះគឺចាប់ធ្វើការពីថ្ងៃរះរហូតដល់ថ្ងៃត្រង់ទើបសម្រាកបន្តិចហើយចាប់ផ្តើមធ្វើបន្តរហូតដល់ម៉ោង៥ល្ងាច ។ នៅពេលយប់ត្រូវជញ្ជូនដីចាក់លើទំនប់រហូតដល់ម៉ោង១១យប់ ទើបគណៈភូមិភាគឲ្យឈប់សម្រាក ។

គ្រូលៀង បានប្រាប់ថា ការធ្វើទំនប់ឈើគោកនេះគឺជាការងារដែលសម្រុកខ្លាំងនិងធ្ងន់ធ្ងរបណ្តាលឲ្យអ្នកធ្វើការបាក់កម្លាំងឈឺស្លាប់ ដោយសារហូបមិនគ្រប់គ្រាន់ ខ្លះឈឺស្លាប់ដោយជំងឺគ្រុនចាញ់ គ្មានថ្នាំព្យាបាល ។ សមមិត្ត លេខ ជាគណៈភូមិភាគទទួលបន្ទុកបច្ចេកទេសខាងទំនប់នានានៅភូមិភាគពាយ័ព្យ ។

បន្ទាប់ពីធ្វើការនៅទំនប់ឈើគោកនេះអស់រយៈពេល៣ខែ គ្រូលៀង ក៏បានសុំច្បាប់ប្រធានទំនប់មកលេងផ្ទះម្តង ។ ពេល

គាត់មកដល់ផ្ទះ កូនតូចទាំងពីររបស់គាត់មានជំងឺហើមដើរលែងរួច ចំណែកឯប្រពន្ធគាត់ឈឺហើមនិងគ្រុនញាក់ទៀត ។ ប្រពន្ធរបស់គាត់ខំត្រដរទាំងឈឺទៅធ្វើការនៅការដ្ឋានស្រែ ដើម្បីយករបបដែលមានតែទឹកបបរលាយគ្រាប់អង្ករបន្តិចបន្តួចមកឲ្យកូន ។ ជាអកុសល កូនទី១និងទី២របស់គាត់បានស្លាប់ជាបន្តបន្ទាប់ ។ ដោយសារបានទឹកបបរពីប្រពន្ធរបស់គាត់ ទើបកូនស្រីរបស់គាត់ម្នាក់បានរស់មកដល់សព្វថ្ងៃនេះ ។ នៅក្នុងឆ្នាំ១៩៧៥ ប្រជាជនថ្មី(ប្រជាជន១៧មេសា)ទាំងក្មេងទាំងចាស់ ដែលជម្លៀសមករស់នៅលើកោះភូមិដូនអី មានចំនួន៦៣៧នាក់ ប៉ុន្តែរហូតមកដល់ឆ្នាំ១៩៧៧ នៅសល់តែ១៣នាក់រួមទាំងគ្រួសារគាត់៣នាក់ផង ។ មូលហេតុដែលប្រជាជនថ្មីស្លាប់ច្រើន គឺបណ្តាលមកពីប្រជាជនទាំងនោះត្រូវអង្គការបង្ខំឲ្យធ្វើការហួសកម្លាំង ផ្តល់អាហារមិនគ្រប់គ្រាន់ និងយកទៅសម្លាប់ចោល ដោយសារអ្នកខ្លះជាប់ខ្សែស្រឡាយជាកូនចៅចិន និងអ្នកខ្លះមានកំហុសឆ្គងក្នុងពេលធ្វើការងារ ដូចជាភ្ជួរដីធ្វើឲ្យបាក់នង្គ័ល ឬក៏ភ្ជួរខុសគន្លងស្ទូងឲ្យហើបគល់សន្ទូង ខ្លះទៀតអង្គការចោទថាជាសេ.អ៊ី.អាកា.ហ្សេ.បេ ពួកសក្តិភូមិពួកជាប់កម្មែលចក្រពត្តិ តាមតែអង្គការនឹកឃើញ ។ គ្រូលៀង និយាយថា “ខ្ញុំធ្លាប់អង្គការចោទថាជាស័ក្តិបីយោធា ទទួលបន្ទុកខាងសេដ្ឋកិច្ចនៅភ្នំពេញ” ។ ពេលនោះអង្គការបានហៅប្រពន្ធ គ្រូលៀង ទៅសួរនាំពីរឿងហ្នឹង ប្រពន្ធគាត់ឆ្លើយថា គាត់ជាកម្មករធ្វើនំបុ័ងនៅភ្នំពេញ មិនមែនស័ក្តិ៣ឯណាទេ ។ ក្រោយពីអង្គការសួរនាំប្រពន្ធរបស់គ្រូលៀងមកអង្គការបានតាមដានមើលគោលជំហររបស់ គ្រូលៀង ដកពិសោធន៍គាត់ ដោយឲ្យគាត់កាន់នង្គ័លភ្ជួរស្រែនិងធ្វើជាងសំណង់ទំនប់ទឹក ។ គាត់បន្ថែមទៀតថា “កាលនោះ ប្រសិនបើខ្ញុំធ្វើខុសអីតែបន្តិច ប្រហែលជាមិនរស់មកដល់សព្វថ្ងៃនេះទេមើលទៅ” ប៉ុន្តែដោយសារគាត់អាចធ្វើការទាំងអស់បានល្អ ហើយរួមផ្សំគាត់ មានសម្បុរខ្មៅផង អង្គការក៏ជឿទុកចិត្តលែងតាមដានសួរនាំតទៅទៀត ។ ចាប់តាំងពីពេលនោះមក គាត់ខំធ្វើការមិនឲ្យខុសឆ្គងទេ ។ គាត់រស់នៅក្នុងសភាពភិតភ័យក្រែងថ្ងៃណាមួយគាត់ធ្វើអ្វីខុសដោយមិនដឹងខ្លួន ហើយត្រូវអង្គការយកទៅរៀនសូត្រ ។ “ពាក្យថារៀនសូត្ររបស់អង្គការគឺយកទៅសម្លាប់ចោល” ។

នៅឆ្នាំ១៩៧៧ អង្គការបានដក គ្រូលៀង ឲ្យមកភ្ជួរស្រែនៅអាចម៍ក្អែក នៅពេជ្រកោង និងទៅភ្ជួរនៅលលកសម្ពុំទួលវែងជិតបាក់ត្រាក្នុងសហករណ៍បាក់ចិញ្ចៀន ក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។ នៅថ្ងៃមួយក្រោយពេលឡើងពីភ្ជួរនៅពេជ្រកោង គ្រូលៀង ក៏លែងគោពីនឹមឲ្យដើរស៊ីស្មៅតាមព្រៃជាប់មាត់បឹងពេជ្រកោង ។ ពេលគាត់កំពុងដើរតាមរកគោ គាត់បានឃើញកងឈ្លបមួយក្រុមមានគ្នា៣ទៅ៤នាក់កំពុងបណ្តើរមនុស្សចូលទៅក្នុងព្រៃ ។ កងឈ្លបទាំងនោះបានឃើញគាត់ ហើយសួរគាត់ថា“មិត្តឯងមករកអីទីនេះ?” គាត់ឆ្លើយថា “ខ្ញុំមករកគោមិត្តបង” ។ ឆ្លើយរួចគាត់ក៏ដើរចេញយ៉ាងលឿនទាំងភ័យរន្ធត់ញាប់ញ័រ ។

នៅក្នុងព្រៃខាងត្បូងជាប់មាត់បឹងពេជ្រកោង គ្រូលៀង បានឃើញខោអាវនៅរាយប៉ាយពេញព្រៃ និងរណ្តៅកប់ខ្មោចរាប់រយនាក់នៅថ្មីៗ ។ ដោយបានឃើញផ្ទាល់នឹងភ្នែកនូវការបណ្តើរមនុស្សយកទៅសម្លាប់បែបនេះ គ្រូលៀង មានការតក់ស្លុតនិងបារម្ភអំពីជីវិតខ្លួនឯងនិងក្រុមគ្រួសារយ៉ាងខ្លាំង ។

នៅក្នុងឆ្នាំ១៩៧៧ អង្គការដក គ្រូលៀង ឲ្យមកការដ្ឋានចម្ការវិញ ដើម្បីភ្ជួរដីដាំឪឡឹក សណ្តែកដី ល្ង និងថ្នាំជក់ ។ នៅថ្ងៃមួយ គាត់ចុកពោះខ្លាំងពេកក៏សុំប្រធានការដ្ឋានឈ្មោះ តាអ៊ិនមកសម្រាកលើអង្រឹងបាវដើម្បីស្អំពោះនឹងទឹកក្តៅ ។ ពេលកំពុងស្អំពោះ ដោយមានការងឿយហត់ពេក គាត់ក៏លង់លក់ទៅ ។ ទឹកក្តៅដែលស្អំពោះនោះកំពប់រលាកក្រលៀនទាំងសង្ខាង ក្លាយជាដំបៅដើរលែងរួច ។ អង្គការចោទគាត់ថាកើតរោគសង្គម “រោគស្វាយ” បម្រុងយកគាត់ទៅសម្លាប់ចោល ។ គាត់បានដឹងមុនក៏ពឹងអ្នកធ្វើការជាមួយគ្នាឲ្យទៅប្រាប់ប្រធាននារីឈ្មោះ ភោគនៅការដ្ឋានលើកោះក្នុងភូមិដូនអីឲ្យគាត់មកជួយអង្វរ តាអ៊ិនដែលជាប្រធានចម្ការថាគាត់ (គ្រូលៀង) រលាកទឹកក្តៅមិនមែនកើតរោគសង្គមទេ ។ បងភោគ យកប្រេងដូងលាយកំបោរឲ្យ គ្រូលៀង លាបរបួស ។ កន្លះខែក្រោយមក ទើបដំបៅគាត់បានជាស្បើយ ។ គ្រូលៀង អាចទៅធ្វើការនៅឯចម្ការបានវិញ ។ តាអ៊ិន ក៏លែងរករឿងយកគាត់ទៅសម្លាប់ចោល ។

នៅក្នុងឆ្នាំ១៩៧៨ អង្គការបានឲ្យគាត់មកនៅការដ្ឋានដីកោះក្នុងភូមិដូនអីវិញ ។ នៅក្នុងឆ្នាំ១៩៧៨ កើតមានការកាប់សម្លាប់ប្រជាជនយ៉ាងខ្លាំងក្លា ។ ក្នុងខណៈនោះ មានការចាប់ក្រុមជាងធ្វើទំនប់ទឹកទ្វារទឹកនៅដីលិង កងធ្វើស្រែនៅអាចម៍ក្អែក នៅវាលប្រហុកនៅបឹងពេជ្រកោង នៅអូររកា និង នៅចម្ការកោះក្នុងភូមិរលាប ឃុំលលកស ស្រុកភ្នំក្រវាញ រាប់ពាន់នាក់ត្រូវចាប់យកទៅសម្លាប់ចោលនៅតាមព្រៃជិតបឹងរុននិងនៅក្នុងបឹងរុនក្នុងសហករណ៍បាក់ចិញ្ចៀនក្នុងស្រុកភ្នំក្រវាញ ។

គ្រូលៀង បានឲ្យដឹងថា នៅថ្ងៃមួយប្រធានការដ្ឋានឈ្មោះ ហ៊ិន បាននាំគាត់ទៅកាប់ដើមរុននៅម្តុំបឹងរុនយកមកក្រងសម្រាប់ប្រក់ផ្ទះស្បូវ ។ ពេលដែលដើរទៅជិតដល់បឹងរុន ធុំក្លិនស្អុយខ្មោចឆាប់ គាត់ក៏ក្រឡេកមើលទៅក្នុងបឹងនិងព្រៃជាប់មាត់បឹង ឃើញសុទ្ធតែសាកសពរាប់រយនាក់គរពីលើគ្នា ។ គ្រូលៀង ក៏សួរទៅ ហ៊ិន ថា«បងខ្មោចឆាប់អីក៏ច្រើនម្ល៉េះ?» ។ ហ៊ិន ឆ្លើយថា ពួកទាំងអស់នេះត្រូវអង្គការយកមកវៃចោល ព្រោះអ្នកទាំងអស់នេះជាពួកបូព៌ាក្បត់នឹងអង្គការ ។ ហ៊ិន បានប្រាប់គាត់ទៀតថា «ការសម្លាប់ចោលរបៀបនេះមាននៅសហករណ៍យើងតិចតួចទេ ។ នៅសហករណ៍បាក់ចិញ្ចៀន អ្នកទោសត្រូវបានដឹកទាំងរថយន្តៗយកទៅសម្លាប់ចោល ។ ដោយហេតុថា ពួកទាំងអស់នោះត្រូវអង្គការចោទថា ជាពួកក្បត់ចូលដៃជើងជាមួយពួកបូព៌ាមានទំនាក់ទំនងជាមួយយួន ។» ហ៊ិន បានគំរាមគាត់ថា «លៀង ឯងកុំនិយាយតទៅទៀត ប្រយ័ត្នឆាប់ណ៎ា» ។ គ្រូលៀង កាប់ដើមរុនបណ្តើរគិតក្នុងចិត្តបណ្តើរខ្លាចក្រែងថ្ងៃណាមួយគាត់ត្រូវអង្គការយកទៅសម្លាប់ ។ នៅចុងឆ្នាំ១៩៧៨ សភាព-ការណ៍ នៅតាមព្រំដែនកម្ពុជា-វៀតណាមមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំង ។ ពេលនេះការងារនៅតាមការដ្ឋានសហករណ៍នានាមិនសូវសម្រុកទេ របបហូបចុកមានការធូរស្បើយ «មានបាយហូបឆ្អែត» ។ គណៈសហករណ៍បានបញ្ជាឲ្យប្រជាជនដឹកជញ្ជូនស្រូវយកទៅទុកនៅជង្រុកនៅក្នុងវត្តភ្នំក្រវាញ ។ ការដឹកជញ្ជូនស្រូវគឺមួយថ្ងៃត្រូវដឹកជញ្ជូនឲ្យបានពីរជើង ចម្ងាយផ្លូវពីសហករណ៍ទៅកន្លែងទុកស្រូវប្រហែល៩ទៅ១០គីឡូម៉ែត្រ ។ ពេលនោះកើតមានសភាពការណ៍ច្របូកច្របល់ជាខ្លាំង ឈ្លបនិងកម្មាភិបាលខ្មែរក្រហមភិតភ័យតក្កមា ដោយដឹងថាកងទ័ពវៀតណាមកំពុងតែវាយដណ្តើមកាន់កាប់យកទីក្រុងភ្នំពេញ ។

នៅខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សនិងកងទ័ពវៀតណាមបានចូលរំដោះទូទាំងប្រទេស ។ នៅទីរួមខេត្តពោធិ៍សាត់ក៏ត្រូវបានរំដោះ ។ ប៉ុន្តែតំបន់ គ្រូលៀង រស់នៅនិងតំបន់ដាច់ស្រយាលមួយចំនួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅឡើយ ។

នៅខែមេសា ឆ្នាំ១៩៧៩ គ្រួសាររបស់គ្រូលៀង និងប្រជាជនចំនួន១៧គ្រួសារទៀត បាននាំគ្នារត់គេចពីខ្មែរក្រហមនៅពេលយប់ ។ គ្រូលៀង ដាក់អំរែកម្ខាងរែកកូន និងម្ខាងទៀតដាក់ឆ្នាំងចាននិងបង្វេចខោអាវ រត់តម្រង់មកដីរំដោះនៃទីរួមខេត្តពោធិ៍សាត់ ។ ប្រហែលម៉ោង៣ជិតភ្លឺទើបមកដល់ដីរំដោះ ។ គ្រូលៀង និងប្រជាជនទាំង១៧គ្រួសារ រំភើបពេកសើចសប្បាយទាំងទឹកភ្នែក ។

រឿងរ៉ាវរបស់លោកគ្រូ ហុង គីមលៀង គឺជារឿងពិតដែលប្រជាជនខ្មែរទូទៅបានជួបប្រទះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងអំឡុងពេលជិតបួនឆ្នាំ(១៩៧៥-១៩៧៩) ប្រជាជនខ្មែរជាងពីរលាននាក់បានស្លាប់បាត់បង់ជីវិតក្រោមអំពើអយុត្តិធម៌បំផុត គឺស្លាប់ដោយមិនទាំងដឹងថាខ្លួនបានធ្វើអ្វីខុសផង ។ ចំណែកអ្នកដែលមានជីវិតនៅរស់ក៏ទទួលរងនូវការឈឺចាប់ធ្ងន់ធ្ងរទាំងរូបរាងកាយនិងស្មារតី ។ ការបាត់បងបង់ទាំងអស់នេះត្រូវតែសងមកវិញដោយអំពើយុត្តិធម៌និងច្បាប់ទើបវិញ្ញាណក្ខន្ធរបស់ជនរងគ្រោះបានទៅដល់សុគតិភព ។ អ្នកដែលប្រព្រឹត្តអំពើឃោរឃៅនិងអមនុស្សធម៌នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចលើកលែងទោសឲ្យបានឡើយ ។

**ឃួយ ទិសាលមុនី**

◆ ***ប្រតិកិរិយា:*** ការចម្រើនថយក្រោយហួសសម័យប្រាសដើង ។

◆ ***សក្តិភូមិ:*** នាហ្មឺនមន្ត្រី ស្តេចដែលមានអំណាចរឹបជាន់ប្រជាជនមានដីស្រែរាប់ម៉ឺនហិកតា ។

(កំណត់ហេតុរបស់សមមិត្ត អ៊ីវ)

*ប្រលោមលោកបដិវត្ត*

# ស្មារតីឈ្លាសវៃរបស់កុមារឃ្វាលក្របីក្នុងការកំទេចខ្មាំង

**(តចប់)**

ពេលនោះកុមារឃ្លានបាយជាខ្លាំង ព្រោះកុមារហូបបាយតែមួយពេលតាំងពីព្រលឹមម៉្ងៃះ ។ កុមារអង្គុយសញ្ជឹងគិតមួយភ្លែត តើចូលភូមិឬទៅពួនដេកក្នុងព្រៃ ។ ពេលនោះកុមារស្រមៃឃើញគ្រប់ទិដ្ឋភាពនៃអំពើឃោរឃៅព្រៃផ្សៃរបស់ទាហានពួកអាធិរាជ ដែលវាបានប្រព្រឹត្តមកលើប្រជាជនយើងនៅម៉្តុំនេះកាលពីពេលមុន ។ កុមារស្រមៃឃើញហាក់ដូចជាពួកវាកំពុងធ្វើទារុណកម្មយ៉ាងសាហាវយង់ឃ្នងទៅលើប្រជាជនក្នុងភូមិនិងឪពុកម្តាយបងប្អូនខ្លួន ។ កុមារក្តាប់ដៃខាំធ្មេញក្រឹតដោយកំហឹងឆ្អួលឆេះពេញដើមទ្រូង ។ កុមារស្ទុះងើបដើរតម្រង់ទៅភូមិភ្លាមមួយរំពេច ។ ទៅដល់ផ្ទះភ្លាម កុមារឃើញពួកទាហានអាធិរាជដើរឆ្វេចឆ្វាចពេញភូមិនិងមុខផ្ទះខ្លួន ។ កុមារក៏តាំងយំលំអុកឲ្យម្តាយដាំបាយវេចខ្ចប់ឲ្យភ្លាមៗ ដើម្បីទៅតាមក្របីបាត់ ។ ម្តាយឪពុកកុមារក៏ភ័យស្រឡាំងកាំង តែក៏សុខចិត្តធ្វើតាមសំណូមពរកូនភ្លាមដែរ ។ កុមារយំមិនតិចតួច យំទាល់តែឮផ្អើលដល់ពួកអាធិរាជ ។ អាមេវាក៏មកសួរដំណើរដើមទង ។ កុមារឃើញដូច្នេះក៏ស្ទុះទៅយំអោបដៃអោបជើងវាផង និយាយសាស័ព្ទប្រាប់វាផងថា "ថ្ងៃនេះក្របីវាដោយញីដោយឈ្មោល វាចំប្រាវដាច់ខ្សែកន្ទុះអស់ រួចវាផ្អើលរត់បាត់អស់ចាប់មិនបាន ។ ឥឡូវខ្ញុំសុំឲ្យឪពុកខ្ញុំគាត់ជូនទៅរកក្របីទាំងយប់នេះ ព្រោះបើចាំស្អែកវាទៅកាន់តែឆ្ងាយទៅៗមុខជាបាត់អស់ហើយ ។ តែឪពុកខ្ញុំប្រកែកមិនព្រមទៅ ដោយខ្លាចអស់លោកមិនឲ្យចេញទៅ..." ។ ថារួចហើយកុមារក៏ទៅនិយាយសុំអាមេវាអនុញ្ញាតឲ្យឪពុកខ្លួនទៅរកក្របីយប់នេះភ្លាមទើបទាន់ ។

ដោយពួកអាចោរឈ្លានពានទាំងនេះវាកំពុងតែត្រូវការក្របីកាប់ស៊ីផង ព្ធដូច្នេះវាក៏យល់ព្រមអនុញ្ញាតឲ្យឪពុកនិងកូនចេញទៅរកក្របីទាំងយប់ តែវាដាក់កំហិតថា ឲ្យរកឲ្យឃើញក្របី ហើយនាំមកភូមិវិញទាំងយប់នេះ បើពុំបានក្របីមកឲ្យវាទេវានឹងសម្លាប់ចោលទាំងឪពុកទាំងកូន ។ ព្ធដូច្នេះកុមារក៏សុខចិត្តទទួលលក្ខខណ្ឌនេះភ្លាម ហើយយកដៃជូតទឹកភ្នែកទឹកសំបោររួចក៏ទៅយកកញ្ចប់បាយមកស្ពាយ ហើយអូសដៃឪពុកចេញទៅភ្លាម ។ ដើរចេញបានផុតឆ្ងាយពីភូមិបន្តិច ទើបកុមារនិយាយពីផែនការរបស់ខ្លួនជំរាបពុក ។ ឪពុកនិងកូនក៏យល់ស្របគ្នាភ្លាម ។ រួចហើយនាំគ្នាដើរផងរត់ផងសំដៅទៅរកជំរំកងឈ្លប ។

បន្តិចក្រោយមកទើបឪពុកនិងកូនបានទៅដល់ជំរំកងឈ្លប ។ ឪពុកនិងកូននាំគ្នារាយការណ៍ប្រាប់កងឈ្លបសព្វគ្រប់អំពីរឿងទាហានពួកអាធិរាជដែលចូលទៅបោះដេកក្នុងភូមិយប់នេះ ។ ព្ធដូច្នេះកងឈ្លបយើង ក៏រៀបចំប្រញាប់ប្រញាល់ចេញទៅរកស្ទាក់វាយពួកវានៅតាមផ្លូវដែលវានឹងត្រឡប់ទៅវិញ ។

ឪពុកនិងកូនលាកងឈ្លបត្រឡប់មករកក្របីវិញ ។ លុះរកឃើញក្របីហើយ គាត់ចាប់ក្របី៣ក្បាលចងទុក រួចក៏នាំគ្នារុះបាយកញ្ចប់ហូបយ៉ាងឃ្លីតៗគ្មានបន្ទឹបន្ទាន់អ្វីឡើយ ។ ពេលនោះម៉ោងប្រហែលជា១រំលងអធ្រាត្រហើយតាមការប៉ាន់ប្រមាណមើលផ្កាយ ។ ឪពុកនិយាយទៅកាន់កូនថា "យើងកុំអាលចូលភូមិភ្លាម តែខំពួកអាចោរវាកាប់ក្របីយើងស៊ីអស់ហើយ ។ ចាំម៉ោង៤ជិតភ្លឺសឹមយើងត្រឡប់ចូលភូមិវិញ ។ តែភ្លឺស្រាងៗពួកវាដកថយទៅវិញហើយ ដូច្នេះវាកាប់ក្របីស៊ីមិនទាន់ទេ ។ កងឈ្លបយើងមានលទ្ធភាពវាយដណ្តើមយកក្របីទាំង៣ក្បាលនេះពីវាវិញបាន ។ កុមារក៏យល់ស្របតាមឪពុក ។ ហូបបាយហើយក៏ប្រាសដេកនៅក្រោមព្រៃគុម្ពោតលក់បាត់ទៅ ។ ចំណែកឯឪពុកនៅអង្គុយយាមភ្លឺៈៗ រហូតដល់ម៉ោងជិត៤ភ្លឺទើបដាស់កូនរួចនាំគ្នាដឹកក្របីដើរចូលភូមិវិញយ៉ាងធម្មតា ។ ពេលនោះពួកអាធិរាជវាក្រោកចាប់មាន់ទាជ្រូករបស់ប្រជាជនយើងលាន់ពុកងរំពងខ្ញៀវខ្ញាពេញទាំងភូមិ ដើម្បីរៀបចំដំណើរចេញទៅវិញ ។ គ្រាន់តែក្រឡេកឃើញឪពុកនិងកូនដឹកក្របីចូលដល់ពួកវាត្រេកអរណាស់ ។ អាខ្លះស្ទុះមកកញ្ឆក់

ខ្មែរក្របីពីដៃឪពុកនិងកូន អាខ្វះមកស្ទាបអង្អែលក្បាលកុមារ សរសើរថាឆ្លាតមែនទើបរកក្របីឃើញវិញ ។ ពួកវាប្លន់យកក្របីទាំង៣ក្បាលនេះ ទាំងជ្រូកមាន់ទានៅក្នុងភូមិទាំងអស់ដែលប្រជាជនមាន ។

នៅម៉ោង៥ភ្លឺស្រាង១ ពួកវាក៏នាំគ្នាធ្វើដំណើរចេញពីភូមិត្រឡប់ទៅស្រុកវាវិញអស់ ។ នៅប្រហែលជាម៉ោង៦ភ្លឺ ស្រាប់តែឮសូរកាំភ្លើងផ្ទុះប្រាវៗលាយឡំនឹងសូរគ្រាប់បែកដៃយ៉ាងកក្រើកមេឃកក្រើកដី ។ ប្រជាជននៅក្នុងភូមិម្តុំនោះទាំងអស់ទាំងចាស់ទាំងក្មេង ទាំងស្រីទាំងប្រុស មានការត្រេកអរជាខ្លាំង ព្រោះយល់ច្បាស់ថាកងឈ្លបយើងនឹងផ្តន្ទាទោសពួកអាចោរព្រៃនគរពុំខានឡើយ ។ តែគ្មាននរណាម្នាក់ដឹងពីផែនការរបស់ឪពុកនិងកូនពីយប់មិញឡើយ ។ដោយបានរៀបចំទីតាំងប្រយុទ្ធតាំងពីយប់មិញយ៉ាងហ្មត់ចត់ជាមុនស្រេច វាយតែក្នុងរយៈ១៥នាទីកងឈ្លបយើងក៏កំទេចទាហានអាធិរ១កងអនុសេនាតូចនេះបានទាំងស្រុង ហើយរឹបអូសយកកាំភ្លើងគ្រប់ធុននិងគ្រាប់រំសេវរបស់វាបានទាំងអស់ ។ រីឯក្របីទាំង៣ក្បាលដែលពួកវាប្លន់យកទៅពីភូមិ ក៏ផ្អើលរត់ខ្ចាត់ខ្ចាយរួចអស់ ។ ក្រោយពេលប្រយុទ្ធទើបកងឈ្លបយើងដេញចាប់ក្របីទាំង៣ក្បាលនេះយកមកជូនប្រជាជនភូមិវិញ ។ ប្រជាជនក្នុងភូមិទាំងអស់ចេញទៅទទួលអបអរកងឈ្លបយើងដោយទឹកចិត្តរំភើបរីករាយឥតឧបមា ។ នៅពេលនោះហើយ ទើបប្រជាជនទាំងអស់គ្នាបានដឹងអំពីផែនការដ៏ជោគជ័យរបស់ឪពុកនិងកូនកាលពីយប់មិញអំពីកងឈ្លបយើងមកវិញ ។

ទាំងអស់គ្នាក៏សរសើរស្មារតីឈ្លាសវៃរបស់កុមារ ផាត ក្នុងការស្វែងរកកម្មុចខ្មាំង ហើយប្រាប់ឲ្យកុមារដទៃទៀតរៀនសូត្រតាមគំរូរបស់វរើកនេះ ។

ដោយស្មារតីភ្ញាក់រលឹកបដិវត្តន៍ខ្ពស់និងស្មារតីប្តូរផ្តាច់ជាមួយខ្មាំង ការពារស្រុកភូមិ ការពារទឹកដីនៃមាតុភូមិជាទីស្នេហារបស់ប្រជាជនយើងទាំងស្រីទាំងប្រុស ទាំងចាស់ទាំងក្មេងដោយឯកភាពគ្នាជាធ្លុងមួយយ៉ាងនេះ នៅក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់អង្គការបដិវត្តន៍ ទើបស្រុកកំចាយមារក៏ដូចស្រុកភូមិនានានៅតាមព្រំដែន ត្រូវបានរំដោះជាស្ថាពរហើយមានសុខសន្តិភាពគ្រប់គ្រាន់ អាចបង្កបង្កើនផលលើកទំនប់ជីកប្រឡាយដោះស្រាយបញ្ហាទឹកធ្វើស្រែបានទាំងវស្សាទាំងប្រាំងដោយឯករាជ្យម្ចាស់ការ ។ ឥឡូវភូមិ-ឃុំយើងនៅម្តុំនោះមានមុខមាត់ថ្មីស្រឡាង ហើយប្រជាជនក៏មានជីវភាពធូរធារសមរម្យសមឋានៈជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ ម្ចាស់វាសនាអនាគតរបស់ខ្លួនហើយ ។ សព្វថ្ងៃបងប្អូនកំពុងប្រយុទ្ធលើកទំនប់ជីកស្រះត្រពាំង ជីកប្រឡាយ ដោះស្រាយបញ្ហាទឹកជាបន្តទៀត និងខំប្រឹងប្រែងធ្វើស្រែប្រាំងយ៉ាងមមាញឹក ដើម្បីបង្កបង្កើនផលឲ្យបានពី១០០ទៅ២០០ភាគរយ សំរាប់កែប្រែជីវភាពខ្លួនផងនិងឧបត្ថម្ភទៅសមរភូមិមុខឲ្យបានជាអតិបរមាផង ។

# "អ្វីដែលខ្ញុំបានដឹងបានឮ"

ខ្ញុំឈ្មោះ គីម ឡាយ ជាជនជាតិខ្មែរដែរ សព្វថ្ងៃរស់នៅប្រទេសបារាំង ធ្លាប់បានរស់នៅនិងស្គាល់ភាពជូរចត់ក្រៃលែងនៃរបបខ្មែរក្រហម ហើយមានភ័ព្វវាសនាបានរួចរស់រានរហូតមកដល់សព្វថ្ងៃ ។ ខ្ញុំបានឃើញពត៌មានមួយតាមរយៈប្រព័ន្ធអាំងទែរណែតដែលស្តីអំពីប្រតិកម្មរបស់ស្ថានទូតចិនទៅលើពត៌មានមួយដែលស្តីអំពីថា ប្រទេសចិន (បុគ្គលិកជនជាតិចិន) បានបង្ហាត់បង្រៀនក្រុមពេជ្ឈឃាតខ្មែរក្រហមនៅមន្ទីរឃុំឃាំងស-២១ ឬគុកទួលស្លែង ឲ្យចេះធ្វើយ៉ាងដូចម្តេចចាប់ចង រួចសម្លាប់ជនជាតិខ្លួនដែលមានមន្ទិលសង្ស័យថា ក្បត់អង្គការរបស់ខ្លួននោះ... ។

ការដែលខ្ញុំសរសេរសំបុត្រនេះមកជម្រាបលោក គឺមានគោលបំណងចង់ប្រាប់លោកឲ្យដឹងអំពីអ្វីដែលខ្ញុំបានដឹងបានឮ

កាលខ្ញុំនៅរស់នៅយ៉ាងវេទនាព្រៃផ្សៃ សឹងស្លាប់សឹងរស់ កាលជំនាន់របបឃាតមនុស្សនេះ ។ ប្រហែលជាលោកបានជ្រាបមក ហើយអ្វីដែលខ្ញុំនឹងជម្រាបសួរដូចតទៅនេះ÷

ទី១) ប្រជាពលរដ្ឋដូចយើងខ្ញុំ ដែលកាលនោះគេហៅថា "ពួក១៧ មេសា" គឺបានដឹងឮ ហើយខ្លះបានទាំងឃើញផងថា មានជនជាតិចិនដើរប្រតិបត្តិការ មើលសកម្មភាពការងារនៅប្រទេសកម្ពុជា ក្នុងរយៈដែលខ្មែរក្រហមកំពុងបង្អត់ចំណីអាហារ ស្គមស្គាំង ហើយបង្ខំឲ្យធ្វើការជាងសត្វទៅទៀត ។ សេចក្ដីទុក្ខវេទនាទាំងផ្លូវកាយនិងផ្លូវចិត្ត រស់នៅថោកជាងសត្វតិរច្ឆានទៅទៀត បានបង្ខំឲ្យពលរដ្ឋខ្មែរខ្លះលួចទៅខ្សឹបនិយាយប្រាប់ជនជាតិចិន (ដែលជាអ្នកបច្ចេកទេស) កំបាំងពីភ្នែកកម្មាភិបាលខ្មែរក្រហមអំពីការរស់នៅយ៉ាងវេទនារបស់ខ្លួន ។ តើបុគ្គលិកចិនទាំងនោះមានអាកប្បកិរិយាយ៉ាងណាដែរចំពោះពាក្យបណ្ដឹងរបស់ពលរដ្ឋដ៏អភ័ព្វទាំងនោះ? គឺមហាចិនទាំងនេះធ្វើមិនដឹងមិនឮតែម្ដង ។ សូមបញ្ជាក់ថា អ្នកដែលទៅនិយាយប្រាប់អ្នកឯកទេសចិននោះគឺជាជនជាតិចិនដែរ ដែលគ្នាបានសុំអង្វរឲ្យរដ្ឋាភិបាលចិនជួយមើលសុខទុក្ខរបស់ពួកគេផង ពីព្រោះខ្មែរក្រហមកំពុងកាប់សម្លាប់រៀងរាល់ថ្ងៃទៅលើជនស្លូតត្រង់ឥតមើលមុខ ។ តើនេះមិនគឺចិនកំពុងឈរឱបដៃមើលខ្មែរក្រហមសម្លាប់ជនជាតិឯងដែរឬទេ? ។ ទី២) ប្រជាពលរដ្ឋខ្មែរដូចយើងខ្ញុំបានសម្គាល់ឃើញ (តាមពាក្យនិយាយពីមាត់មួយទៅមាត់មួយ) ថា ចិនទាំងនេះមានបុកពារក្រអឺតក្រទមខ្លាំងណាស់ ។ វាមិនព្រមដឹកទឹកដូងដែលខ្មែរឡើងទៅបេះឲ្យដោយទម្លាក់ផ្លែដូងមកដីទេ ។ គេព្រមដឹកទាល់តែពាំផ្លែដូងយកមកដីថ្នមៗ មិនឲ្យជ្រុះដល់ដីឡើយ ។ ក្រុមខ្មែរយើងដែលមានតែស្បែកគ្របដណ្ដប់ឆ្អឹង បាននាំគ្នាលួចនិយាយថា ហ៊ឺះ! ពួកអាចិនអាណានិគមថ្មីនេះ មានបុកក្រអឺតក្រទមជាងអាណានិគមអាមេរិកនិយមទៅទៀត! ។ តើហ្នឹងហើយឬដែលហៅថាកុម្មុយនិស្តវណ្ណៈអធននិយមនោះ? *Proletariat commusim*? ។

ចំពោះពត៌មានដែលខ្ញុំបានរៀបរាប់ដូចខាងលើនេះ ដែលជាពត៌មានដ៏តិចតួចបំផុត ទោះបីពុំមានភស្ដុតាងអ្វីសម្រាប់ជាការចោទប្រកាន់នៅក្នុងតុលាការនោះក៏ដោយ ខ្ញុំយល់ថាជារឿងទាក់ទងទៅនឹងអ្វីដែលហៅថា "ការទទួលខុសត្រូវទៅនឹងផ្លូវចិត្ត moral responsibility" ។ លើពិភពលោកសព្វថ្ងៃគេយល់ថា ការដែលឈរឱបដៃមើលពុំមានប្រតិកម្មចំពោះឧក្រិដ្ឋកម្មព្រៃផ្សៃ គឺពុំមែនជាមនុស្សទេ inactive-passive standing before criminal is no longer humanism ។ សូមឲ្យលោកឯកអគ្គរដ្ឋទូតចិនជ្រាបពីរឿងនេះផង ។ ដោយសារតែរឿងនេះហើយដែលនិស្សិតខ្មែរនៅភ្នំពេញចង់ទាមទារឲ្យរដ្ឋាភិបាលចិនចេញសេចក្ដីថ្លែងការណ៍ "សោកស្ដាយ" ចំពោះមុខរាស្ត្រខ្មែរផង ។ វាខុសគ្នាសែនឆ្ងាយរវាងទស្សនកិច្ចលោក គ្លីនតុន នៅប្រទេសវៀតណាម ហើយនិងទស្សនកិច្ចរបស់លោក ហ្សាង ហ្សេមិញ នៅប្រទេសកម្ពុជា ។ នៅប្រទេសវៀតណាម ប្រជាពលរដ្ឋវៀតណាមចុះស្រមកទទួលលោក គ្លីនតុន ដោយស្ម័គចិត្ត ឯនៅប្រទេសខ្មែរ រដ្ឋាភិបាលកេណ្ឌមនុស្សឲ្យមកទទួលលោក ហ្សាង ហ្សេមិញ... ។

ខ្ញុំសូមបញ្ចប់សេចក្ដីរបស់ខ្ញុំត្រឹមតែប៉ុណ្ណេះសិន ដោយសូមផ្ញើសេចក្ដីស្ងើចសរសើររបស់ខ្ញុំក្នុងការដែលលោកខំព្យាយាមរកសេចក្ដីពិត យុត្តិធម៌ មកជូនជនជាតិខ្មែរយើងដែលរងគ្រោះដោយអំពើចង់កែប្រែធាតុមនុស្សឲ្យមកជាសត្វវិញនោះ ។ នេះហើយដែលខ្ញុំយល់ថាជាអំពើប្រឆាំងនឹងមនុស្សជាតិនោះ ។

សូមលោកទទួលនូវសេចក្ដីគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ផ្ញើនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០០

ហត្ថលេខា៖ យឹម គឹមឡាយ

## ចម្រៀងខ្មែរក្រហមៈ

# អត្តភាពបដិវត្តកម្ពុជា ចាំងខ្ពស់ត្រដែតត្រដឹមក្នុងលោក

| | | |
|---|---|---|
| នារីៈ | ជោគជ័យមេសាភ្លឺថ្លាចាំងចែង | កម្ពុជាថ្មីទែងចាំងចោលរស្មី |
| | ពាសពេញទីក្រុងជនបទទាំងឡាយ | ពិដោរឈ្ងុយសាយពេញក្នុងលោក ។ |
| យុវជនៈ | ប្រទេសមួយតូចប្រជាជនតិច | ខ្វះខាតពន់ពេកខ្វះខាតសព្វមុខ |
| | តែហ៊ានវាយឈ្នះមេខ្លាំងក្នុងលោក | ឃោរឃៅបំផុតអាវុធសំបូរបែប ។ |
| នារីៈ | ៣០ឆ្នាំសង្គ្រាមលោកលើកទី២ | នេះជារឿងថ្មីរឿងមួយដោយឡែក |
| | ប្រជាជនមួយតូច តែរឹងបែសដូចដែក | អាគាំងចេញខ្ទេចគ្មានសល់ម្នាក់សោះ ។ |
| យុវជនៈ | យើងដណ្តើមជ័យដាច់ខាតល្អណាស់ | វាយខ្លាំងដូចរន្ទះគ្មានសម្រួលសម្រុះ |
| | គឺគ្មានចរចា គ្មានរាថយសោះ | វាយលុះត្រាតែរំដោះតាមទិសកំណត់ ។ |
| នារីៈ | យើងដណ្តើមបានជោគជ័យទាំងស្រុង | ល្អស្អាតផូរផង់ដូចកែវមរកត |
| | អត្តភាពជាតិយើងលេចធ្លោបរិសុទ្ធ | ប្រជាជនជាមិត្តក្នុងលោកអបអរ ។ |
| យុវជនៈ | កម្ពុជាថ្មីល្បីល្បាញអស្ចារ្យ | ចាំងដូចសូរិយាជាងសម័យអង្គរ |
| | សង្គមបរិសុទ្ធហ្មត់ហ្មងបវរ | កម្មករកសិករធ្វើម្ចាស់វាសនា ។ |
| នារីៈ | នេះគឺដោយសារមាគ៌ាថ្លៃថ្លា | បដិវត្តប្រពៃឯករាជ្យម្ចាស់ការ |
| | ខ្លួនឧបត្ថម្ភខ្លួនទ្រាំទ្រអស្ចារ្យ | ប្រយុទ្ធគ្មានរាដាច់ខាតសម្រុកជាប់ ។ |
| យុវជនៈ | នេះគឺដោយសារវីរភាពបដិវត្ត | ខ្ពង់ខ្ពស់បំផុតប្រជាជននិងកងទ័ព |
| | ហ៊ានលះបង់ខ្ពស់ គ្មានគិតរឿងស្លាប់ | ដើម្បីអត្តភាពជាតិត្រដឹមស្កឹមស្កៃ ។ |
| នារីៈ | សព្វថ្ងៃអត្តភាពបដិវត្តកម្ពុជា | ផ្សព្វផ្សាយគន្ធាចោលឈ្ងុយឈ្ងប់ឆ្ងាយ |
| | ប្រជាជនក្នុងទ្វីបទាំង៥រីករាយ | យកគំរូថ្លាថ្លៃនៃបដិវត្តយើង ។ |
| យុវជនៈ | នេះជាគំរូថ្លៃថ្លាបំផុតប្រជាជន | មួយក្រុមខ្សត់កាន់អាវុធក្រោកឈរឡើង ។ |
| រួមៈ | យើងខ្ញុំប្រជាជនកម្ពុជាគ្រប់គ្នា | មោទនភាពរាបសា ប្រយុទ្ធខ្ជាប់ខ្ជួន |
| | ពង្រឹងពង្រីកអត្តភាពជាតិខ្លួន | ឲ្យបានសមស្មួននឹងពលិកម្មមិត្តទាំងឡាយ |
| | យើងខ្ញុំប្តេជ្ញា ប្តេជ្ញាវាយសម្រុក | ការពារភូមិស្រុក កសាងកម្ពុជាថ្មី |
| | ខ្លួនឧបត្ថម្ភខ្លួនទៅតាមប្រពៃណី | យកជោគយកជ័យថ្មីៗធំថែមទៀត ។ |
| | ខ្លួនឧបត្ថម្ភខ្លួនប្រពៃណីថ្លាថ្លៃ | សាងកម្ពុជាថ្មីចាំងចែងក្នុងលោកិយអើយ ។ |

*ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា*

*ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល*

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 31, July 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; the Royal Danish Government; Swedish International Development Co-operation Agency(Sida); and the Royal Netherlands Government, *The Hague*.